ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ព្រឹត្តិបត្រស្រាវជ្រាវអប់រំ



## ភាគទី ០៣

បោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិអប់រំ
២០១៧

# មាតិកា


បុព្វកថា ii

អារម្ភកថា iii

អត្ថបទស្រាវជ្រាវ

០១ សមត្ថភាពនាយកសាលាកម្ពុជា ធៀបនឹងស្តង់ដានាយកសាលាអាស៊ាន ០១

០២ ទស្សនៈរបស់មន្ត្រីអប់រំស្តីពីអធិការកិច្ចអប់រំជាប្រព័ន្ធ ១៤

០៣ គុណភាពនៃការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅប្រទេសកម្ពុជា ២៧

០៤ កត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រនៅមធ្យមសិក្សាទុតិយភូមិក្នុងប្រទេសកម្ពុជា ៤១

# បុព្វកថា

បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់វិស័យអប់រំ ដែលជាជ្រុងមួយដ៏សំខាន់នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ការបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពពេញលេញប្រកបដោយសីលធម៌វិជ្ជាជីវៈល្អ គឺជាការរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិផ្អែកលើសង្គមពុទ្ធិ និងវិបុលភាព។

ដោយឈរលើមូលដ្ឋានសសរស្តម្ភ៥ គឺគ្រូបង្រៀនៈ កម្មវិធីសិក្សា អធិការកិច្ច វង្វាយតម្លៃការសិក្សា និងឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានពង្រីកកម្មវិធីកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡារហូតដល់ ១៥ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុ ការពង្រាយគ្រូបង្រៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន គុណវុឌ្ឍិគ្រូបង្រៀន អធិការកិច្ច វង្វាយតម្លៃលទ្ធផលសិក្សា ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ កម្មវិធីសិក្សា អគារសិក្សា ឧត្តមសិក្សា វិស័យកីឡា គោលនយោបាយយុវជន ការអប់រំបច្ចេកទេស សាលាបង្រៀនជំនាន់ថ្មី និងគន្លងអាជីព។

ដើម្បីសម្រេចបេសកកម្មដ៏ថ្លៃថ្លានេះ វិទ្យាស្ថានជាតិអប់រំ ដែលជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំធ្វើការសិក្សាស្រាវជ្រាវស្វែងរកចំណុចវិជ្ជមាន និងចំណុចគួរកែលម្អ ព្រមទាំងបញ្ហាប្រឈមដែលកំពុងជួបប្រទះនៅតាមវិទ្យាល័យនានា ដើម្បីផ្តល់យោបល់មួយចំនួនសម្រាប់ការអនុវត្តការងារកាន់តែមានភាពល្អប្រសើរឡើង។

ក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា កិច្ចការស្រាវជ្រាវនេះ ជាមូលដ្ឋានសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ក្នុងការបង្រៀននិងរៀន របស់គ្រូនិងសិស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃសង្គមសាកលភាវូបនីយកម្ម។

នៅទីបញ្ចប់ ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ដៃគូអភិវឌ្ឍនានា ដែលបានជួយឧបត្ថម្ភជាបច្ចេកទេស និងថវិកាដល់វិទ្យាស្ថានជាតិអប់រំ និងសូមកោតសរសើរដល់ក្រុមសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថានជាតិអប់រំទាំងអស់ ដែលបានចំណាយពេលវេលា កម្លាំងកាយ កម្លាំងចិត្ត និងស្មារតីដើម្បីឱ្យការងារស្រាវជ្រាវនេះទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**បណ្ឌិត ហង់ជួន ណារ៉ុន**

# អារម្ភកថា

ក្នុងក្របខណ្ឌសកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងការលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពសំខាន់ៗដូចជា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលជាទុនក្នុងការអភិវឌ្ឍប្រទេសជាតិ។

ដើម្បីរួមចំណែកសម្រេចបេសកកម្មដ៏ថ្លៃថ្លានេះ វិទ្យាស្ថានជាតិអប់រំដែលជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទសំខាន់ៗចំនួនបួនៈ (១) សមត្ថភាពនាយកមធ្យមសិក្សាទុតិយភូមិធៀបទៅនឹងស្តង់ដាអាស៊ាន (២) កំណែទម្រង់គុណភាពគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា (៣) ទស្សនៈរបស់អធិការអប់រំលើការបណ្តុះបណ្តាលអធិការកិច្ចថ្មី និង (៤) កត្តាដែលជះឥទ្ធិពលដល់លទ្ធផលសិក្សាសិស្សផ្នែកគណិតវិទ្យានិងវិទ្យាសាស្ត្រនៅមធ្យមសិក្សាទុតិយភូមិ។

លទ្ធផលស្រាវជ្រាវទាំងបួនប្រធានបទនេះ ជាមូលដ្ឋាននៃការរៀបចំគោលនយោបាយអប់រំដើម្បីធ្វើកំណែទម្រង់វិស័យអប់រំ និងចក្ខុវិស័យនាពេលអនាគតឱ្យកាន់តែល្អប្រសើរ ឈានទៅរកសង្គមពុទ្ធិ និងវិបុលភាព។

នៅទីបញ្ចប់ ក្រុមស្រាវជ្រាវយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំក្រសួងគ្រប់លំដាប់ថ្នាក់ ដែលបានផ្តល់ឱកាសដល់ក្រុមយើងខ្ញុំបានចុះប្រមូលទិន្នន័យតាមគោលដៅរហូតបានសម្រេចការងារស្រាវជ្រាវប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៧

**ក្រុមស្រាវជ្រាវរបស់វិទ្យាស្ថានជាតិអប់រំ**

# សមត្ថភាពនាយកសាលាកម្ពុជា ធៀបនឹងស្តង់ដានាយកសាលាអាស៊ាន

*សៀង សុវណ្ណា នី វដ្ឋា ប៊ុន សុជានី ម៉ៅ សារឿន ប៉ូ ប៊ុន្ណូន ខែក សំណាង ធី សាវរិន គួយ សូគាន ផែន សារិត ឈូក ណាស្រស់*

វិទ្យាស្ថានជាតិអប់រំ

សារអេឡិចត្រូនិចទំនាក់ទំនង៖ siengsovannanie@gmail.com

***មូលន័យសង្ខេប៖*** *ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែទម្រង់ជាច្រើន ដើម្បីធានានូវការពង្រឹងគុណភាពអប់រំ ឲ្យសមស្របទៅនឹងនិន្នាការអប់រំរបស់ពិភពលោក និងតំបន់អាស៊ាន សម្រាប់ធ្វើឱ្យសម្រេចបាននូវគោលដៅនៃការអប់រំ សម្រាប់ទាំងអស់គ្នានៃសហស្សវត្សរ៍ថ្មី។ ឯកសារគតិយុត្តជាច្រើន ត្រូវបានបង្កើតឡើង ក្នុងន័យជួយសម្រួលការគ្រប់គ្រងរដ្ឋបាល និងសាលារៀនឱ្យមានលក្ខណៈល្អប្រសើរ។ ប្រសិទ្ធភាព នៃការគ្រប់គ្រងអង្គភាពសាលារៀន ត្រូវបានឆ្លុះបញ្ចាំងតាមរយៈសមត្ថភាពរបស់នាយកសាលា និងការចូលរួមយ៉ាងទូលំទូលាយរវាងនាយក និងបុគ្គលិកក្រោមឱវាទ។ ក្នុងន័យនេះ នាយកសាលាត្រូវមានសមត្ថភាពលើផ្នែក៖ កសាងផែនការយុទ្ធសាស្ត្រ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ភាពជាអ្នកដឹកនាំលើការបង្រៀននិងរៀន ការធ្វើទំនាក់ទំនងជាមួយភាគីដែលពាក់ព័ន្ធ និងត្រូវមានក្រមសីលធម៌ជាអ្នកដឹកនាំ។ សមត្ថភាពទាំងនេះ ជាស្តង់ដានាយកសាលារៀននៅអាស៊ីអាគ្នេយ៍ (អាស៊ាន)។ ដោយឡែកសមត្ថភាពរបស់នាយកសាលារៀននៅកម្ពុជា មិនទាន់អាចបញ្ជាក់បានច្បាស់លាស់នៅឡើយទេ ថាមានវិសាលភាពប៉ុណ្ណា ដើម្បីធានានូវគុណភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រងក៏ដូចជាធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ។ ដូច្នេះការស្រាវជ្រាវនេះ កើតឡើងក្នុងគោលបំណង៖ (១) រកឱ្យឃើញនូវសមត្ថភាពរបស់នាយកសាលា លើផ្នែកកសាងផែនការយុទ្ធសាស្ត្រ និង (២) ភាពជាអ្នកដឹកនាំលើការរៀន និងបង្រៀន ធៀបទៅនឹងស្តង់ដាសមត្ថភាពនាយកសាលាអាស៊ាន។ ការស្រាវជ្រាវនេះ ក៏នឹងផ្តល់ផងដែរនូវសារៈប្រយោជន៍ ក្នុងការលើកកម្ពស់គុណភាពអប់រំ តាមរយៈសមត្ថភាពរបស់នាយកសាលា។ វិធីសាស្ត្រ នៃការស្រាវជ្រាវនេះ គឺការធ្វើសម្ភាស ដោយប្រើប្រាស់កម្រងសំណួរទៅលើនាយក នាយិកា នាយករង នាយិការង បុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀនមួយចំនួន ក្នុងខេត្តចំនួនប្រាំ នៅទូទាំងប្រទេសកម្ពុជា។ កម្រងសំណួរត្រូវបានបង្កើតឡើង សម្រាប់ធ្វើការសម្ភាសទៅលើសមត្ថភាពនាយកសាលា ដោយផ្តោតតែទៅលើពីរចំណុចប៉ុណ្ណោះគឺ (១) ការរៀបចំផែនការយុទ្ធសាស្ត្រនិងការបង្កើតថ្មី និង (២) ការដឹកនាំលើការរៀននិងបង្រៀន។ កម្រងសំណួរបើក ត្រូវបានបញ្ចូលបន្ថែមសម្រាប់ការសម្ភាសនាយក។ កម្រងសំណួរ ត្រូវបានរៀបចំសម្រាប់វាយតម្លៃសមត្ថភាពនាយកដោយផ្អែកលើមាត្រដ្ឋាន Likert ១-៥ ដែល ១=តិចណាស់ ៥=ច្រើនណាស់។ ទិន្នន័យបានពីការធ្វើសម្ភាស ត្រូវបានវិភាគស្ថិតិ Independent T-Test និង Analysis of Variance (One-Way ANOVA) ដោយប្រើកម្មវិធី IBM SPSS Statistics 20។ សំណាកសរុបចំនួន៥០៨ ដែលក្នុងនោះសំណាកទទួលបានពីការសម្ភាសនាយក និងនាយករង មានចំនួន៩៤នាក់ និង៤១៤នាក់ បានពីការសម្ភាសបុគ្គលិកបង្រៀន និងមិនបង្រៀន ហើយត្រូវបានប្រមូលពីវិទ្យាល័យសរុបចំនួន៣៩ក្នុងចំណោមខេត្តប្រាំ រួមមាន៖ កំពង់ចាម បាត់ដំបង កំពត កំពង់ឆ្នាំង និងមណ្ឌលគិរី។ លទ្ធផលបានបង្ហាញឲ្យឃើញថា សមត្ថភាពរបស់នាយកវិទ្យាល័យ នៅប្រទេសកម្ពុជា នៅមានកម្រិតទាបជាងស្តង់ដាសមត្ថភាពនាយកសាលាអាស៊ាន ដោយសមត្ថភាពលើផ្នែកកសាងផែនការយុទ្ធសាស្ត្រទទួលបានមធ្យមពិន្ទុប្រហាក់ប្រហែល៣.៣៧ និងផ្នែកដឹកនាំការបង្រៀននិងរៀនប្រហាក់ប្រហែល៣.៥៤ បើធៀបទៅនឹងស្តង់ដាសមត្ថភាពនាយកសាលាអាស៊ាន (៥.០០)។ តាមរយៈលទ្ធផល នៃការស្រាវជ្រាវនេះ នឹងផ្តល់ព័ត៌មានត្រឡប់ដល់នាយកសាលា មន្ត្រីគ្រប់គ្រង និងភាគីពាក់ព័ន្ធក្នុងវិស័យអប់រំ ហើយក៏បានឆ្លុះបញ្ចាំងឱ្យឃើញថា នាយកវិទ្យាល័យនៅកម្ពុជា ទាមទារឱ្យមានការបណ្តុះបណ្តាលលើសមត្ថភាពផ្នែកកសាងផែនការយុទ្ធសាស្ត្រ និងភាពជាអ្នកដឹកនាំលើការរៀន និងបង្រៀនឱ្យមានលក្ខណៈជាការបណ្តុះបណ្តាលអាជីពនាពេលអនាគត។*

***ពាក្យគន្លឹះ៖*** *ស្តង់ដាសមត្ថភាពនាយកសាលា ការរៀបចំផែនការយុទ្ធសាស្ត្រនិងការបង្កើតថ្មី ការដឹកនាំលើការរៀននិងបង្រៀន*

## ១. សេចក្តីផ្តើម

ការអប់រំសម្រាប់ទាំងអស់គ្នា ជាគោលដៅរួមរបស់ពិភពលោក ក្នុងការលុបបំបាត់អនក្ខរភាពនៅសហស្សវត្សរ៍ថ្មី និងដើម្បីធានាបាននូវការអប់រំប្រកបដោយនិរន្តរភាព(គោលដៅអភិវឌ្ឍសហស្សវត្សរ៍ របស់អង្គការសហប្រជាជាតិ ក្រោយឆ្នាំ២០១៥)។ ជាមួយគ្នានេះ សហគមន៍អាស៊ាន(២០១៥) បានផ្តោតទៅលើសហគមន៍សេដ្ឋកិច្ច ក្នុងនោះរួមមានលំហូរសេវាកម្ម កម្លាំងពលកម្ម និងធនធានមនុស្ស។

ដើម្បីឆ្លើយតបនិន្នាការអប់រំពិភពលោក និងតំបន់ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដែលក្នុងនោះមុំទី៤ បានផ្តោតទៅលើការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ជាពិសេសយុវជនឱ្យក្លាយទៅជាពលរដ្ឋពេញលេញ មានជំនាញវិជ្ជាជីវៈច្បាស់ លាស់

សម្រាប់រួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជាតិ ពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្ន ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ (យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី៣)។

ដើម្បីសម្រេចបានគោលដៅខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ ដោយមានគោលនយោបាយធំៗចំនួនបី ក្នុងនោះគោលនយោបាយមួយផ្ដោតទៅលើការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីគ្រប់គ្រងសម្រាប់ធ្វើវិមជ្ឈការ និងបានដាក់ចេញនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅចំនួន១៥ចំណុច ដែលមានចំណុចមួយស្ដីពីការបង្កើតគន្លងអាជីព និងការបណ្ដុះបណ្ដាលនាយកសាលា។

ដើម្បីឱ្យដំណើរការនៃការគ្រប់គ្រង អាចអនុវត្តទៅបានដោយជោគជ័យ អ្នកគ្រប់គ្រងគ្រប់រូប ជាពិសេសនាយកសាលា ត្រូវចេះរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់អភិវឌ្ឍសាលារៀនរបស់ខ្លួន។ ជាងនេះទៅទៀតនាយកសាលា ចាំបាច់ត្រូវមានសមត្ថភាពដឹកនាំការរៀន និងបង្រៀន សម្រាប់ធ្វើឱ្យសម្រេចបាននូវលទ្ធផលសិក្សារបស់សិស្ស។ ជាក់ស្ដែងដើម្បីលើកកម្ពស់ការគ្រប់គ្រងការរៀន និងបង្រៀនឱ្យទទួលបានលទ្ធផលល្អ នាយកសាលា ត្រូវយកចិត្តទុកដាក់ទៅលើការរៀបចំការដឹកនាំ ការអនុវត្ត និងការត្រួតពិនិត្យតាមដាននិងវាយតម្លៃផែនការយុទ្ធសាស្ត្រដែលបានគ្រោងទុក។

ភាពជាអ្នកដឹកនាំរបស់នាយកសាលា ត្រូវបានគេចាត់ទុកថាជាតួនាទីដ៏សំខាន់មួយ ក្នុងការគ្រប់គ្រងសាលារៀន។ ការជួយយុវជនឆ្ពោះទៅរកការសម្រេចបាននូវសក្ដានុពលពេញលេញ ក៏ជាតួនាទីជាយុទ្ធសាស្ត្រ របស់នាយកសាលាផងដែរ (Burrup,1962)។ នេះសបញ្ជាក់ឱ្យឃើញថា នាយកសាលាដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការសាលារៀនប្រកបដោយប្រសិទ្ធភាព (Bradfield, 1964)។ ស៊ីមេអូអ៊ីណូតិច (SEAMEO INNOTECH) ដែលមានសមាជិកអាស៊ានទាំង១០ បានបង្កើតនូវស្តង់ដាសមត្ថភាពនាយកសាលា ដើម្បីធានាគុណភាពនៃការអប់រំរបស់ប្រទេសក្នុងតំបន់ សម្រាប់សម្រេចបាននូវសហគមន៍មួយវាសនាតែមួយ។ ស្តង់ដាសមត្ថភាពនោះ រួមមាន៖(១) ការគិតប្រកបដោយយុទ្ធសាស្ត្រ និងការបង្កើតថ្មី (២)ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង (៣) ភាពជាអ្នកដឹកនាំលើការរៀន និងបង្រៀន (៤) ក្រមសីលធម៌របស់អ្នកដឹកនាំ និង (៥) ការធ្វើទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ។

ប្រទេសកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតនូវឯកសារគតិយុត្តជាច្រើនដើម្បីធានានូវគុណភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រងស្ថាប័នអប់រំ។ ឯកសារគតិយុត្តទាំងនោះរួមមាន៖ (១) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ) (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១១) (២) ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ (ភាពជាអ្នកដឹកនាំ ការងាររដ្ឋបាល សកម្មភាពសិក្សា អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ សម្ភាររូបវន្ត និងក្រមសីលធម៌វិជ្ជាជីវៈ (MoEYS, 2010) (៣) តួនាទី និងការទទួលខុសត្រូវរបស់នាយក នាយករង និងលេខាធិការវិទ្យាល័យ (MoEYS, 2011)។

នៅក្នុងចំណុច(៣) បានបង្ហាញលម្អិតអំពីលក្ខខណ្ឌនៃការតែងតាំងនាយក នាយករង និងលេខាធិការវិទ្យាល័យ ដែលលក្ខខណ្ឌទាំងនោះរួមមាន៖ គុណវុឌ្ឍិ បទពិសោធការងារ និងក្រមសីលធម៌វិជ្ជាជីវៈ។ នាយកវិទ្យាល័យ ត្រូវបានតែងតាំង ពីក្នុងចំណោមអ្នកដែលមានសញ្ញាបត្រទាបបំផុត កម្រិតបរិញ្ញាបត្រ មានបទពិសោធ ជានាយករងយ៉ាងតិច៤ឆ្នាំ មានចំណេះដឹងផ្នែកគ្រប់គ្រង ការងារបុគ្គលិក ភាពជាអ្នកដឹកនាំ មានចំណេះដឹងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងមានវិន័យការងារ សីលធម៌ល្អ និងមានភាពអំណត់។ រីឯ ការតែងតាំងនាយករង ក៏តម្រូវឱ្យមានលក្ខណៈវិនិច្ឆ័យប្រហាក់ប្រហែលគ្នា ទៅនឹងការតែងតាំងនាយកផងដែរ ដោយខុសគ្នាត្រង់មានបទពិសោធការងារជាប្រធានក្រុមបច្ចេកទេស ឬលេខាធិការយ៉ាងតិច៤ឆ្នាំ។ ដោយឡែកចំពោះការតែងតាំងតួនាទីជាលេខាធិការ ពុំសូវផ្ដោតខ្លាំងទៅលើសមត្ថភាពគ្រប់គ្រង ភាពជាអ្នកដឹកនាំ បទពិសោធ ការងារ និងគុណវុឌ្ឍិដូចការតែងតាំងនាយក និងនាយករងនោះទេ។

បើឆ្លុះបញ្ចាំងអំពីតួនាទី និងទំនួលខុសត្រូវរបស់នាយក នាយករងវិទ្យាល័យ ដែលបាន និងកំពុងអនុវត្តមាន៖ (១)ការគ្រប់គ្រងរដ្ឋបាលសាលា (២)ការកសាងចក្ខុវិស័យ បេសកកម្ម និងផែនការសកម្មភាព (៣)ការផ្សព្វផ្សាយផែនការសកម្មភាព (៤)ការធ្វើអធិការកិច្ចលើការរៀន និងបង្រៀន (៥)ការរៀបចំក្រុមបច្ចេកទេស ក្រុមប្រឹក្សានានា និងគណៈកម្មការផ្សេងៗ (៦)ការដោះស្រាយបញ្ហាផ្សេងៗជាយថាហេតុ និង(៧)ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយសេចក្ដីសម្រេចចិត្តជាដើម (MoEYS, 2011)។

ប៉ុន្តែតាមស្ថានភាពជាក់ស្តែង សមត្ថភាពគ្រប់គ្រងរបស់នាយកសាលានៅកម្ពុជាមួយចំនួន នៅមានកម្រិតនៅឡើយ ជាពិសេសការធ្វើផែនការអប់រំ ការអភិវឌ្ឍកម្មវិធីសិក្សា ការគ្រប់គ្រងការរៀននិងបង្រៀន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងសាលារៀន និងការធ្វើគោលនយោបាយអភិវឌ្ឍសាលារៀនជាដើម (Ly, 2010) ដោយសារពួកគាត់ត្រូវបានជ្រើសរើស និងតែងតាំងឡើងតាមរយៈបទពិសោធនៃការរៀន និងបង្រៀន ដោយមិនបានឆ្លងកាត់វគ្គបណ្តុះបណ្តាលដំបូងលើផ្នែកដឹកនាំ និងគ្រប់គ្រងណាទេ។ លើសពីនេះទៅទៀត កម្រិតវប្បធម៌របស់នាយកសាលានៅមានកម្រិតគឺជាកត្តាមួយដែលធ្វើឱ្យប៉ះពាល់ទៅដល់គុណភាពនៃការអប់រំនៅកម្ពុជាផងដែរ(របាយការណ៍គម្រោង EEQP, ២០១៣-២០១៤)។

ទន្ទឹមពេលជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតកម្មវិធីវិក្រិតការជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រង និងដឹកនាំដល់គណៈគ្រប់គ្រងសាលា ជាពិសេសនៅតាមបណ្តាវិទ្យាល័យនានាក្នុងទូទាំងប្រទេស។ ប៉ុន្តែបើទោះបីជាមានការធ្វើវិក្រិតការជាបន្តបន្ទាប់យ៉ាងនេះក្តី ក៏សមត្ថភាពមន្ត្រីគ្រប់គ្រងទាំងនោះនៅពុំទាន់ឆ្លើយតបទៅនឹងការកែទម្រង់របស់ក្រសួងដែរ ហើយរហូតមកដល់ពេលនេះក៏នៅមិនទាន់មានការសិក្សាណាមួយបានបង្ហាញពីស្តង់ដាសមត្ថភាពរបស់នាយកសាលានៅកម្ពុជាធៀបទៅនឹងសមត្ថភាពនាយកសាលាអាស៊ាននៅឡើយ។

ការសិក្សានេះ គឺផ្តោតទៅលើការប្រៀបធៀបសមត្ថភាពរបស់នាយកសាលានៅកម្ពុជា ធៀបទៅនឹងស្តង់ដានាយកសាលានៅអាស៊ានលើផ្នែក (១) ការរៀបចំផែនការយុទ្ធសាស្ត្រ និង (២) ការដឹកនាំការរៀន និងបង្រៀន ហើយមានវត្ថុបំណង៖ (១) រកឱ្យឃើញពីសមត្ថភាពនាយកវិទ្យាល័យនៅកម្ពុជា លើការរៀបចំផែនការយុទ្ធសាស្ត្រ និងការដឹកនាំការរៀននិងបង្រៀន និង(២) ប្រៀបធៀបសមត្ថភាពនាយកវិទ្យាល័យនៅប្រទេសកម្ពុជា ជាមួយសមត្ថភាពនាយកសាលាអាស៊ាន។

ដើម្បីសម្រេចវត្ថុបំណងខាងលើ ការស្រាវជ្រាវនេះផ្តោតលើសំណួរស្រាវជ្រាវដូចខាងក្រោម៖ (១) តើនាយកវិទ្យាល័យនៅកម្ពុជាមានសមត្ថភាពរៀបចំផែនការយុទ្ធសាស្ត្របានកម្រិតណា ធៀបនឹងស្តង់ដាសមត្ថភាពនាយកសាលាអាស៊ាន? (២) តើនាយកវិទ្យាល័យនៅកម្ពុជាមានសមត្ថភាពដឹកនាំការរៀន និងបង្រៀនបានកម្រិតណាធៀបនឹងស្តង់ដាសមត្ថភាពនាយកសាលាអាស៊ាន?

## ២.វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ ប្រើទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរបិទ។ រីឯទិន្នន័យតាមបែបគុណវិស័យ ត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរបើក។ ទិន្នន័យទាំងពីរប្រភេទខាងលើត្រូវបានប្រមូលពីនាយក នាយិកា នាយករង នាយិការង សាលាសរុបចំនួន៩៤នាក់ ប្រធានក្រុមបច្ចេកទេស និងបុគ្គលិកអប់រំសរុបចំនួន៤១៤នាក់ ហើយសំណាកទាំងនោះត្រូវបានជ្រើសរើសចេញពីខេត្តចំនួនប្រាំ ក្នុងនោះខេត្តតូចចំនួន០១ ខេត្តមធ្យមចំនួន០២ និងខេត្តធំចំនួន០២ (នាយកដ្ឋានផែនការ, ២០០៩) ដែលអាចជាតំណាងឱ្យសំណាកទូទាំងប្រទេសបាន។

ដោយឡែក កម្រងសំណួរត្រូវបានបែងចែកជាពីរប្រភេទ ដែលមួយប្រភេទសម្រាប់នាយក នាយិកា នាយករង នាយិការង និងមួយប្រភេទទៀតសម្រាប់ប្រធានក្រុមបច្ចេកទេស និងបុគ្គលិកអប់រំបំពេញ។ កម្រងសំណួរទាំងនោះ ផ្តោតទៅលើខ្លឹមសារចំនួនពីរចំណុច ដែលបង្ហាញពីសមត្ថភាពរបស់នាយកសាលាគឺ៖ (១) ការរៀបចំផែនការយុទ្ធសាស្ត្រ និងការបង្កើតថ្មី និង(២) ការដឹកនាំលើការរៀន និងបង្រៀន។ ចំពោះកម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស និងបុគ្គលិកអប់រំ សំណួរបើកមិនត្រូវបានបញ្ចូលទេ ប៉ុន្តែកម្រងសំណួរសម្រាប់នាយក នាយិកា នាយករង នាយិការង សំណួរបើក ត្រូវបានបញ្ចូលបន្ថែមទៅលើសំណួរបែបបរិមាណវិស័យ។

ទិន្នន័យ ដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះ ទាំងបរិមាណវិស័យ និងគុណវិស័យ ត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន លើសមត្ថភាពអនុវត្តជាក់ស្តែងរបស់នាយក នាយិកាសាលាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងការដឹកនាំការរៀន និងបង្រៀន។ ចំពោះការវិភាគតាមបែបគុណវិស័យ ការវិភាគប្រេកង់ និងមធ្យមពិន្ទុត្រូវបានប្រើប្រាស់ ដើម្បីពិនិត្យទៅលើសមត្ថភាពរបស់នាយក នាយិកា ដោយធ្វើការប្រៀបធៀបសមត្ថភាពទាំងនោះទៅតាមភេទ អាយុ តំបន់ បទពិសោធ និងកម្រិតវប្បធម៌។ ស្ថិតិ Independent T-Test និង Analysis of Variance (One-Way ANOVA) ក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការវិភាគនេះដែរ តាមរយៈកម្មវិធី IBM SPSS Statistics 20។

ការវិភាគទិន្នន័យបែបគុណវិស័យនេះ ត្រូវបានចាត់ថ្នាក់ជាក្រុម និងដាក់ចំណងជើងដោយផ្អែកទៅលើ ទស្សនៈ

និងអត្ថន័យនៃប្រយោគទាំងឡាយណា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ដើម្បីចាត់ថ្នាក់ និងអត្ថន័យនៃប្រយោគដូចបានរៀបរាប់ខាងលើ អ្នកស្រាវជ្រាវបានអាន និងវិភាគខ្លឹមសារនៃប្រយោគនីមួយៗយ៉ាងល្អិតល្អន់។ បន្ទាប់មក ទើបអ្នកស្រាវជ្រាវធ្វើការបរិយាយ និងពន្យល់តាមគោលគំនិតនីមួយៗ។

## ៣. លទ្ធផលស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានផ្តោតទៅលើសមត្ថភាព សំខាន់ៗចំនួនពីររបស់នាយក នាយិកាសាលាគឺ៖ (១)ការរៀបចំផែនការយុទ្ធសាស្ត្រ និង(២)ការដឹកនាំការរៀននិងបង្រៀន។ ចំពោះសមត្ថភាពដែលផ្តោតទៅលើការរៀបចំផែនការយុទ្ធសាស្ត្រ អ្នកស្រាវជ្រាវបានវិភាគទៅលើចំណុចអាទិភាពចំនួនបីរួមមាន៖ (១)ការរៀបចំផែនការយុទ្ធសាស្ត្ររបស់សាលា (២)ការផ្សព្វផ្សាយសេចក្តីសម្រេចចិត្ត និង(៣)ការដឹកនាំផ្លាស់ប្តូរ និងច្នៃប្រឌិត។ ចំណែកឯសមត្ថភាពការដឹកនាំការរៀន និងបង្រៀន បានផ្តោតទៅលើចំណុចសំខាន់ៗចំនួនបួន៖ (១)ការដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា (២)ការបង្កើតបរិស្ថានសិក្សាសិស្សមជ្ឈមណ្ឌល (៣)ការពិនិត្យកែលម្អ និងការវាយតម្លៃការងាររបស់គ្រូបង្រៀន និង(៤)ការសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុក។ ចំណុចទាំងពីរផ្នែកខាងលើនេះ មានចែងនៅក្នុងស្តង់ដាសមត្ថភាពនាយកសាលាអាស៊ាន (ASEAN INNOTECH) ដែលកម្ពុជាក៏ជាសមាជិកមួយនៅក្នុងសមាគមន៍នេះដែរ (Cambodia-Asean Membership, 1999)។

### *៣.១ បរិយាយទិន្នន័យ*

ទិន្នន័យដែលទទួលបានពីកម្រងសំណួរ បង្ហាញពីអ្នកចូលរួមបំពេញ ដោយធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទ ស្ថិតិបែបពណ៌នាមានដូចជា៖ ភេទ អាយុ កម្រិតវប្បធម៌ តំបន់ តួនាទីបច្ចុប្បន្ន បទពិសោធការងារ និងការបណ្តុះបណ្តាលរបស់នាយកសាលា។

ក្រាបទី១ខាងលើ បង្ហាញពីអ្នកចូលរួមបំពេញកម្រងសំណួរសម្រាប់នាយក ដែលរួមមានភេទប្រុស ៨៣.៩% ភេទស្រី១៦.១% ទីប្រជុំជន៣៥.៩% និងជនបទ៦៤.១% ក្នុងនោះអ្នកមានតួនាទីជានាយក នាយិកា ៣៣.៣% និងនាយករង នាយិការង៦៦.៧%។ ចំពោះអ្នកធ្លាប់បានទទួលការបណ្តុះបណ្តាលមាន៦៦.៣% និងអ្នកមិនធ្លាប់បានទទួលការបណ្តុះបណ្តាលមាន៣៣.៧%។ អ្នកដែលមានបទពិសោធក្នុងតួនាទីបច្ចុប្បន្នតិចជាង៥ឆ្នាំមាន ៣០.៩% ចន្លោះពី៥ទៅ១០ឆ្នាំមាន៣៩.៤% និងច្រើនជាង ១០ឆ្នាំមាន ២៩.៥%។ រីឯអ្នកដែលមានអាយុតិចជាង៣០ឆ្នាំមាន ៤.៣% ចន្លោះពី៣០ទៅ៤០ឆ្នាំមាន២២.៣% ចន្លោះពី៤០ទៅ៥០ឆ្នាំមាន៦០.៦% និងច្រើនជាង៥០ឆ្នាំមាន ១២.៨%។

ក្រាបទី១៖ សំណាកនាយកសាលា




ក្រាបទី២៖ សំណាកប្រធានក្រុមបច្ចេកទេស




ក្រាបទី២ បង្ហាញពីអ្នកចូលរួមបំពេញកម្រងសំណួរសម្រាប់គ្រូ ដែលមានភេទប្រុស៧៣.៣% ភេទស្រី ២៦.៧% ទីប្រជុំជន ៣៦.៨% ជនបទ ៦៣.២% ដោយបុគ្គលិកបង្រៀនមាន៩១.៦% និងមិនបង្រៀនមាន ៨.៤%។ ចំពោះអ្នកដែលមានបទពិសោធក្នុងវិស័យអប់រំតិចជាង៥ឆ្នាំមាន២៤.២% ចន្លោះពី៥ទៅ១០ឆ្នាំមាន២៧.៤% ច្រើនជាង ១០ឆ្នាំមាន៤៨.៤%។ ចំណែកឯអ្នកដែលមានអាយុតិចជាង ៣០ឆ្នាំមាន១៧.៩% ចន្លោះពី៣០ទៅ៤០ឆ្នាំមាន៤៤.២% ចន្លោះពី៤០ទៅ៥០ឆ្នាំមាន៣៣.៧% និងច្រើនជាង៥០ឆ្នាំមាន៤.២%។

### ៣.២ ភាពជឿជាក់នៃឧបករណ៍ស្រាវជ្រាវ

ដូចបានរៀបរាប់ខាងដើម ក្នុងការសិក្សាស្រាវជ្រាវ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរពីរ។ កម្រងសំណួរនីមួយៗត្រូវបានធ្វើតេស្ត ដើម្បីពិនិត្យកម្រិតជឿទុកចិត្តដោយប្រើស្ថិតិ Cronbach's alpha។ ជាលទ្ធផលកម្រងសំណួរទី១ (កម្រងសំណួរសម្រាប់នាយក) មានកម្រិតនៃភាពជឿទុកចិត្ត ០.៩៦ និងកម្រងសំណួរទី២ (កម្រងសំណួរសម្រាប់គ្រូ) មានកម្រិតនៃភាពជឿទុកចិត្ត ០.៩៨។ តួលេខនេះជាតម្លៃល្អបំផុត ដែលបញ្ជាក់ថាកម្រងសំណួរអាចប្រើប្រាស់បានក្នុងការស្រាវជ្រាវ។ ទិន្នន័យដែលទទួលបានតាមរយៈការបំពេញកម្រងសំណួរនេះ អាចប្រើប្រាស់ដើម្បីវិភាគតាមបែបបរិមាណវិស័យបាន។

### ៣.៣ សមត្ថភាពនាយកតាមអថេរផ្សេងៗ

តាមលទ្ធផលវិភាគស្ថិតិ T-Test ទាំងទិន្នន័យនាយក នាយិកា ទិន្នន័យបុគ្គលិកបង្រៀន និងមិនបង្រៀនលើអថេរ ភេទ និងអថេរការបណ្តុះបណ្តាល បង្ហាញថាសមត្ថភាពទាំងពីរខាងលើរបស់នាយកសាលា គឺមិនមានភាពខុសគ្នាទេ (No Significant)។ មានន័យថា នាយក និងនាយិកាសាលានៅកម្ពុជាមានកម្រិតសមត្ថភាពប្រហាក់ប្រហែលគ្នា។ តាមចម្លើយរបស់នាយក និងនាយិកាដែលបានបំពេញក្នុងកម្រងសំណួរ វគ្គបណ្តុះបណ្តាលភាគច្រើន ផ្តោតទៅលើការគ្រប់គ្រង ការដឹកនាំ ការបង្រៀននិងរៀន និងការរៀបចំផែនការ។ ក៏ប៉ុន្តែ លទ្ធផលគួរឱ្យចាប់អារម្មណ៍បានបង្ហាញថា សមត្ថភាពនាយក នាយិកាសាលា ដែលធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាល និងមិនធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលលើផ្នែកទាំងនោះមិនមានអ្វីខុសប្លែកគ្នានោះទេ។

ដូចគ្នាដែរ ចំពោះការវិភាគស្ថិតិ One Way ANOVA លើអថេរអាយុ និងតំបន់ទាំងទិន្នន័យនាយក នាយិកា ទាំងទិន្នន័យគ្រូ និងបុគ្គលិកមិនបង្រៀនក៏មិនមានអ្វីខុស គ្នាដែរ។ នេះមានន័យថា នាយក នាយិកាដែលមានអាយុច្រើន និងអាយុតិច មានកម្រិតសមត្ថភាពប្រហាក់ប្រហែលគ្នានៅគ្រប់តំបន់ទាំងអស់។

**អថេរភេទ**

បើវិភាគទៅលើការប្រៀបធៀបសមត្ថភាពនាយក និងនាយិកាដោយផ្អែកទៅលើភេទ ឃើញថា នាយកមានមធ្យមពិន្ទុខ្ពស់ជាងនាយិកាស្ទើរគ្រប់សមត្ថភាពទាំងអស់ លើកលែងតែការដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា (B1) មួយប៉ុណ្ណោះ ដែលនាយិកាមានមធ្យមពិន្ទុខ្ពស់ជាងនាយក (ក្រាបទី៣)។ តាមលទ្ធផលនេះនាយកទំនងជាមានសមត្ថភាពខ្ពស់ជាង បើប្រៀបធៀបជាមួយសមត្ថភាពរបស់នាយិកា។ ក៏ប៉ុន្តែលទ្ធផលនេះបង្ហាញតែក្នុងចំនួនសំណាករបស់កម្រងសំណួរនៃការស្រាវជ្រាវនេះប៉ុណ្ណោះ មិនអាចទាញយកការសន្និដ្ឋានជារួមចំពោះសមត្ថភាពរបស់នាយក នាយិកាទាំងអស់នៅទូទាំងប្រទេសកម្ពុជាបានទេ ពីព្រោះលទ្ធផលនៃការវិភាគ T-Test ទៅលើអថេរភេទនេះបង្ហាញថាគ្មានភាពខុសគ្នាទេរវាងសមត្ថភាពនាយក និងសមត្ថភាពនាយិកា (no significant difference)។

ក្រាបទី៣៖ អថេរភេទ




*សម្គាល់៖ A: ការរៀបចំផែនការយុទ្ធសាស្ត្រ*

*A1: ការរៀបចំផែនការយុទ្ធសាស្ត្រសាលា*

*A2: ការផ្សព្វផ្សាយសេចក្តីសម្រេចចិត្ត*

*A3: ការដឹកនាំផ្លាស់ប្តូរ និងច្នៃប្រឌិត*

*B: ការដឹកនាំការរៀន និងបង្រៀន*

*B1: ការដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា*

*B2: ការបង្កើតបរិស្ថានសិក្សាសិស្សមជ្ឈមណ្ឌល*

*B3: ការពិនិត្យកែលម្អ និងការវាយតម្លៃការងាររបស់គ្រូបង្រៀន*

*B4: ការសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុក*

**អថេរការបណ្តុះបណ្តាល**

តាមរយៈការបំពេញកម្រងសំណួររបស់នាយក នាយិកាស្តីអំពីវគ្គបណ្តុះបណ្តាលផ្សេងៗ ដែលពួកគាត់ធ្លាប់បានឆ្លងកាត់កន្លងមក ភាគច្រើនផ្តោតទៅលើការគ្រប់គ្រង ការដឹកនាំការរៀន និងបង្រៀន និងការរៀបចំផែនការ។ ក៏ប៉ុន្តែលទ្ធផលគួរឱ្យចាប់អារម្មណ៍នៃការវិភាគ T-Test បានបង្ហាញថា សមត្ថភាពនាយក នាយិកាសាលាដែលធ្លាប់ឆ្លងកាត់ និងមិនធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលលើផ្នែកទាំងនោះមិនមានអ្វីខុសប្លែកគ្នានោះទេ (no significant)។ កត្តានេះអាចបណ្តាលមកពីវគ្គបណ្តុះបណ្តាលទាំងនោះ មានរយៈពេលខ្លីពេក ឬខ្លឹមសារមិនទាន់ឆ្លើយតបពេញលេញទៅនិងតម្រូវការជាក់ស្តែងរបស់នាយក នាយិកា និងបរិស្ថានរបស់

សាលារៀននីមួយៗ ឬការចូលរួមរបស់ពួកគាត់មិនបានយកចិត្តទុកដាក់ខ្ពស់នៅក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាល ឬអាចបណ្តាលមកពីសមត្ថភាពគ្រូឧទ្ទេសដែលទៅបង្រៀននោះនៅមានកម្រិត។

**អថេរខេត្ត**

ការវិភាគទិន្នន័យ One Way ANOVA ជាទូទៅសមត្ថភាពនាយក និងនាយិកាគឺប្រហាក់ប្រហែលគ្នា។ ពិនិត្យទិន្ន ន័យ ដែលទទួលបានពីនាយក បានបង្ហាញថា សមត្ថភាពរបស់នាយកសាលា ពិតជាមានភាពខុសគ្នា (significant difference) លើផ្នែកការកសាងផែនការយុទ្ធសាស្ត្រ (A) តែមិនមានភាពខុសគ្នាទេ (no significant) លើផ្នែកការដឹកនាំការរៀននិងបង្រៀន (B) ពីខេត្តមួយទៅខេត្តមួយទៀត។ ម្យ៉ាងទៀត បើមើលទៅលើទំនោរនៃសមត្ថភាពនាយកសាលាទៅតាមខេត្តនីមួយៗ ក្នុងចំណោមខេត្តទាំងប្រាំឃើញថាសមត្ថភាពនាយកនៅខេត្តទាំងនោះហាក់មានភាពខុសគ្នាខ្លាំងពីខេត្តមួយទៅខេត្តមួយ។ ខេត្តបាត់ដំបងមានមធ្យមពិន្ទុខ្ពស់ជាងខេត្តផ្សេងៗលើគ្រប់ផ្នែកទាំងអស់ បន្ទាប់មកគឺខេត្តកំពត កំពង់ចាម កំពង់ឆ្នាំង និងមណ្ឌលគីរី (ក្រាបទី៤)។ នេះបង្ហាញថា សមត្ថភាពរបស់នាយកសាលានៅខេត្តបាត់ដំបងលើផ្នែក៖ ការកសាងផែនការយុទ្ធសាស្ត្រ និងការដឹកនាំការរៀន និងបង្រៀនមានកម្រិតខ្ពស់ជាងខេត្តផ្សេងៗទៀត។ ចំពោះខេត្តមណ្ឌលគីរី ទំនោរបង្ហាញថាសមត្ថភាពរបស់នាយកលើផ្នែក ការរៀបចំផែនការយុទ្ធសាស្ត្រ (A) ហាក់មានកម្រិតទាបខ្លាំង (ជាង៣.០០)។ ប៉ុន្តែសមត្ថភាពផ្នែកការដឹកនាំការរៀន និងបង្រៀន(B) មានមធ្យមពិន្ទុខ្ពស់(៣.៧៥)។ បើធ្វើការប្រៀបធៀបពីសមត្ថភាពទាំងពីរផ្នែក ឃើញថា គ្រប់ខេត្តទាំងអស់ សមត្ថភាពរបស់នាយកសាលាលើផ្នែកការកសាង និងកែលម្អកម្មវិធីសិក្សា (B1) ទទួលបានមធ្យមពិន្ទុល្អប្រសើរ (ច្រើនជាង៣.៧៥) ជាងផ្នែកផ្សេងៗទៀត។ កត្តានេះទំនងជានាយក នាយិកាទាំងអស់មានការយល់ដឹងខ្ពស់ទៅលើដំណើរការនៃការកសាង និងកែលម្អកម្មវិធីសិក្សា ឬពួកគាត់បានចូលរួមដឹកនាំប្រចាំនៅក្នុងការផលិត និងកែលម្អកម្មវិធីសិក្សាជាមួយគ្រូបង្រៀន ឬអាចបណ្តាលមកពីពួកគាត់មានបទពិសោធន៍ច្រើនខាងការបង្រៀនមុនពេលក្លាយជានាយកសាលា។

បើពិនិត្យមើលទៅលើ ទិន្នន័យដែលបានពីការបំពេញកម្រងសំណួររបស់គ្រូ បានបង្ហាញពីភាពខុសគ្នាខ្លះ និងដូចគ្នាខ្លះជាមួយកម្រងសំណួរ ដែលបំពេញដោយនាយកសាលា។ ទិន្នន័យ One Way ANOVA បង្ហាញថា សមត្ថភាពរបស់នាយកសាលានៅតាមខេត្តនីមួយៗ ពិតជាមានភាពខុសគ្នា (significant different) ។ ទំនោររបស់ខេត្តទាំងប្រាំបង្ហាញថា ខេត្តបាត់ដំបងនៅតែទទួលបានមធ្យមពិន្ទុល្អ ប្រសើរជាងគេ បន្ទាប់មកគឺខេត្តមណ្ឌលគីរី កំពត កំពង់ឆ្នាំង និងកំពង់ចាម (រូបទី៥)។

ក្រាបទី ៤ ៖ អថេរខេត្ត (នាយកវាយតម្លៃ)




លទ្ធផលនេះហាក់បីដូចជាផ្ទុយនឹងលទ្ធផលដែលទទួលបានពីនាយកសាលា ចំពោះខេត្តបីគឺកំពត កំពង់ចាម និងមណ្ឌលគីរី។ ចំពោះខេត្តកំពង់ចាមក្រុមគ្រូបង្រៀនបានផ្តល់មធ្យមពិន្ទុទាបចំពោះសមត្ថភាពរបស់នាយកសាលាលើផ្នែកទាំងពីរ (ក្រោម ៣.៥០) នេះប្រហែលជាវិទ្យាល័យភាគច្រើនដែលស្ថិតក្នុងភាគសំណាកនេះ ក្រុមគ្រូបង្រៀន ហាក់ខ្វះការសហការគ្នាជាមួយនាយកសាលាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងការដឹកនាំការបង្រៀន និងរៀន ឬទំនងជានាយកសាលាខ្លះនៅក្នុងខេត្តនេះ (កំពង់ចាម) មិនបានធ្វើការផ្សព្វផ្សាយនូវសេចក្តីសម្រេចចិត្ត ការដឹកនាំការផ្លាស់ប្តូរ និងផ្នែប្រឌិត ការបង្កើតបរិស្ថានសិក្សាសិស្សមជ្ឈមណ្ឌល និងការពិនិត្យការកែលម្អ និងការវាយតម្លៃការងារឱ្យបានជាប្រចាំនៅក្នុងផែនការអភិវឌ្ឍសាលារបស់ខ្លួន។ ម្យ៉ាងទៀតទំនងជាក្រុមគ្រូបង្រៀនខ្លះបានបង្ហាញភាពមិនចុះសម្រុងគ្នាក្នុងការធ្វើការជាមួយនាយកសាលា(ទំនាស់ផលប្រយោជន៍) ដែលជាហេតុធ្វើឱ្យពួកគាត់ (គ្រូបង្រៀន) វាយតម្លៃមធ្យមពិន្ទុទាបទៅលើសមត្ថភាពរបស់នាយក។

បើទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលទិន្នន័យលើ អថេរខេត្តអាចធ្វើការពិភាក្សាបានតែនៅក្នុងសំណាកនៃការស្រាវជ្រាវនេះតែប៉ុណ្ណោះ មិនអាចឆ្លុះបញ្ចាំងទៅលើសមត្ថភាពរបស់ នាយកសាលានៅទូទាំងប្រទេសកម្ពុជាបានឡើយ ពី ព្រោះការវិភាគ One Way ANOVA បង្ហាញថាសមត្ថភាពរបស់នាយកសាលាតាមអថេរខេត្ត គឺមិនមាន

ភាពខុសគ្នានោះទេ (no significant difference) ឬខុសគ្នាតិចតួច (<1)។

ក្រាបទី ៥៖ អថេរខេត្ត (ប្រធានក្រុមបច្ចេកទេសវាយតម្លៃ)




### អថេរតំបន់

ការស្រាវជ្រាវនេះបានបែងចែកជាពីរតំបន់ គឺ៖ តំបន់ទីប្រជុំជន (វិទ្យាល័យនៅទីរួមខេត្ត) និងតំបន់ជនបទ (វិទ្យាល័យនៅតាមស្រុក)។ ទំនោរនៃអថេរតំបន់បានបង្ហាញថា សមត្ថភាពទាំងពីរផ្នែករបស់នាយកសាលានៅតាមតំបន់ទីប្រជុំជន និងតំបន់ជនបទមានភាពខុសគ្នាលើគ្រប់ផ្នែកទាំងអស់។ រូបទី៦បានបង្ហាញថា សមត្ថភាពនាយកវិទ្យាល័យនៅតាមតំបន់ទីប្រជុំជនមានមធ្យមពិន្ទុខ្ពស់(ច្រើនជាង៣.៧៥) ជាងសមត្ថភាពរបស់នាយកវិទ្យាល័យនៅតំបន់ជនបទ (ក្រោម ៣.៧៥)។

ក្រាបទី ៦៖ អថេរតំបន់(នាយកវាយតម្លៃ)




ការវិភាគ T-Test ដែលទទួលបានពីការសម្ភាសគ្រូក៏បានបង្ហាញថា ពិតជាមិនមានភាពខុសគ្នានៃសមត្ថភាពនាយកវិទ្យាល័យនៅតាមតំបន់ទីប្រជុំជន និងសមត្ថភាពនាយកវិទ្យាល័យនៅតាមតំបន់ជនបទ។ រូបភាពទី៧បង្ហាញពីទំនោរអថេរតំបន់ទីប្រជុំជន និងទីជនបទ។ សមត្ថភាពរបស់នាយកនៅតំបន់ទីប្រជុំជន មានមធ្យមពិន្ទុច្រើនជាង ៣.៧៥។ ចំណែកឯ សមត្ថភាពរបស់នាយកសាលា នៅតំបន់ជនបទទទួលបាន មធ្យមពិន្ទុខ្ពស់បំផុតតែ៣.៥០ ប៉ុណ្ណោះ។ ផ្អែកតាមលទ្ធផលនេះនាំឱ្យមានការពិភាក្សាមួយថា ប្រហែលជានាយកសាលានៅតាមតំបន់ទីប្រជុំជនមានការគាំទ្រ ផ្អែកស្មារតីក្នុងការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ និងទទួលបាន ព័ត៌មានគ្រប់ជ្រុងជ្រោយជាងនាយកសាលានៅតាមតំបន់ជនបទដែលជាហេតុធ្វើ ឱ្យពួកគាត់មានសមត្ថភាពជាងនាយកវិទ្យាល័យនៅតំបន់ជនបទ។ ប៉ុន្តែ បើផ្អែកតាមទិន្នន័យនៃការវិភាគតាម រយៈទិន្នន័យការវិភាគ T-Test ពីនាយកបានបង្ហាញថា មិនមានភាពខុសគ្នាទេ (no significant) រវាងសមត្ថភាពនាយកនៅតំបន់ទីក្រុង និងនាយកនៅតាមតំបន់ជនបទ។ ព្រោះមានគម្លាតតូចបំផុត (ចំពោះនាយក៣.៦៦ ចំពោះគ្រូ៣.៣៧)។

ក្រាបទី ៧៖ អថេរតំបន់ (ប្រធានក្រុមបច្ចេកទេសវាយតម្លៃ)




ក្រាបទី ៨៖ អថេរសញ្ញាបត្រ




### អថេរសញ្ញាបត្រ

បើធ្វើការពិភាក្សាលើទិន្នន័យអថេរសញ្ញាបត្រ ឃើញថា សមត្ថភាពរបស់នាយកសាលាមានភាពខុសគ្នារវាងនាយកដែលមានសញ្ញាបត្រទាប និងនាយកដែលមានសញ្ញាបត្រខ្ពស់។ ការសិក្សានេះបានបែងចែកសញ្ញាបត្រនាយកជាពកម្រិត មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) សញ្ញាបត្របរិញ្ញាបត្រ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។ នាយក ដែលមានសញ្ញាបត្រត្រឹមធ្យមសិក្សាទុតិយភូមិមានមធ្យមពិន្ទុទាបជាង នាយកដែលមានសញ្ញាបត្របរិញ្ញាបត្រ ហើយនាយកសាលា ដែលមានតែសញ្ញាបត្របរិញ្ញាបត្រមានមធ្យមពិន្ទុទាបជាងនាយកមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត)(ក្រាបទី៨)។

**អថេរបទពិសោធន៍ការងារ**

ការសិក្សាប្រៀបធៀប សមត្ថភាពរបស់នាយកវិទ្យាល័យដោយផ្អែកទៅលើបទពិសោធការងារ(បទពិសោធតិចជាង៥ឆ្នាំ ចន្លោះពី៥ទៅ១០ឆ្នាំ និងច្រើនជាង១០ឆ្នាំ) បង្ហាញថា ទំនោរសមត្ថភាពលើបទពិសោធការងារនីមួយៗ មិនមានភាពខុសគ្នានោះទេ។ ក្រាបទី៩បង្ហាញឲ្យឃើញថា នាយកវិទ្យាល័យ ដែលមានបទពិសោធតិចជាង៥ឆ្នាំមានមធ្យមពិន្ទុ៣.៧៥ លើសមត្ថភាពផ្នែកការរៀបចំផែនការយុទ្ធសាស្ត្រសាលា (A1) ខ្ពស់ជាងគេ។ ចំណែកឯសមត្ថភាពផ្នែកការដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា (B1) វិញ នាយកសាលាដែលមានបទពិសោធច្រើនជា១០ឆ្នាំមានមធ្យមពិន្ទុខ្ពស់ (៣.៧៥) ។ ទំនោរនេះបានបង្ហាញថានាយកដែលមានបទពិសោធតិច និងនាយកសាលាដែលមានបទពិសោធការងារច្រើនមិនមានភាពខុសគ្នាទាំងលើផ្នែកការរៀបចំផែនការយុទ្ធសាស្ត្រ និងសមត្ថភាពលើការដឹកនាំការរៀន និងបង្រៀន (ក្រាបទី៩)។ ទិន្នន័យ One Way ANOVA ក៏បានបង្ហាញជារួមផងដែរថាសមត្ថភាពរបស់នាយកវិទ្យាល័យនៅទូទាំងប្រទេសមិនមានការខុសគ្នាទេ ទាំងលើផ្នែកការរៀបចំផែនការយុទ្ធសាស្ត្រ ទាំងលើផ្នែកការដឹកនាំការរៀន និងបង្រៀន(no significant)។

ក្រាបទី ៩៖ អថេរបទពិសោធន៍ក្នុងវិស័យអប់រំ




**អថេរអាយុ**

ការសិក្សាស្រាវជ្រាវ ក៏បានផ្ដោតផងដែរទៅលើសមត្ថភាពរបស់នាយកវិទ្យាល័យទៅតាមអាយុ ដោយបែងចែកជាបីក្រុមអាយុគឺៈ អាយុតិចជាង៣០ឆ្នាំ ចន្លោះពី៣០ទៅ៤០ឆ្នាំ និងចន្លោះពី៤០ទៅ៥០ឆ្នាំ។ ទំនោរបង្ហាញថា នាយកវិទ្យាល័យដែលមានអាយុតិចជាង៣០ឆ្នាំមានមធ្យមពិន្ទុខ្ពស់ជាងក្រុមអាយុផ្សេងទៀតទាំងផ្នែកការកសាងផែនការយុទ្ធសាស្ត្រ និងផ្នែកការដឹកនាំការបង្រៀន និងរៀន (ច្រើនជាង៣.៨០) ស្របពេលនាយកសាលាដែលមានអាយុចន្លោះពី ៤០ទៅ៥០ឆ្នាំមានមធ្យមពិន្ទុទាបជាងគេ(៣.២០) ហើយអាយុចន្លោះពី៣០ទៅ៤០ឆ្នាំ មានមធ្យមពិន្ទុប្រហែល ៣.៦០ លើផ្នែកការដឹកនាំការរៀន និងបង្រៀន (B1)។ ដូចគ្នាដែរ ចំពោះការវិភាគទិន្នន័យតាម One Way ANOVA លើអថេរអាយុ និងតំបន់ ទាំងទិន្នន័យនាយក នាយិកា ទិន្នន័យគ្រូ និងបុគ្គលិកមិនបង្រៀនក៏មិនមានអ្វីខុសគ្នាដែរ។ នេះមានន័យថា នាយក នាយិកាដែលមានអាយុច្រើន និងអាយុតិច មានកម្រិតសមត្ថភាពប្រហាក់ប្រហែលគ្នានៅគ្រប់តំបន់ទាំងអស់។

ក្រាបទី ១០៖ អថេរអាយុ




ក្រាបទី ១១៖ អថេរសមត្ថភាពនាយកតាមបទពិសោធន៍ជានាយក




### ***៣.៤ សមត្ថភាពការរៀបចំផែនការយុទ្ធសាស្ត្រ***

ផ្អែកលើស្តង់ដាអាស៊ាននាយកសាលាត្រូវមានសមត្ថភាព ក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់សាលាធ្វើការផ្សព្វផ្សាយ សេចក្តីសម្រេចចិត្ត និងធ្វើការដឹកនាំផ្លាស់ប្តូរនិងច្នៃប្រឌិត។ នៅក្នុងមាត្រដ្ឋាន ១-៥ ដែលកំណត់ជាស្តង់ដាក្នុងការស្រាវ ជ្រាវនេះ នាយកសាលាទទួលបានពិន្ទុនៅចន្លោះ ៣.២៨ ទៅ៣.៤២។ តួលេខនេះមានន័យថា សមត្ថភាព របស់នាយកលើការរៀបចំផែនការយុទ្ធសាស្ត្រ គឺស្ថិតនៅទាបជាងស្តង់ដារបស់អាស៊ាន។

តាមទិន្នន័យស្វ័យវាយតម្លៃ របស់នាយកសមត្ថភាព ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ របស់សាលាជាបញ្ហាប្រឈមខ្លាំងជាងគេ ក្នុងចំណោមសមត្ថភាពរងទាំងបីនៃការរៀបចំផែន ការយុទ្ធសាស្ត្រ។ ក្រាបខាងក្រោមនេះបង្ហាញពីសមត្ថភាពទាំងនោះ។

ក្រាបទី១២៖ កម្រិតសមត្ថភាពនាយកលើ ផ្នែកផែនការយុទ្ធសាស្ត្រ (នាយកស្វ័យវាយតម្លៃ)




*សម្គាល់: ការវាស់វែងផ្អែកលើមាត្រដ្ឋាន likert ១-៥ ដែល ១ = តិចតួចណាស់ និង ៥ = ច្រើនណាស់។*

*A: ការរៀបចំផែនការយុទ្ធសាស្ត្រ*

*A1: ការរៀបចំផែនការយុទ្ធសាស្ត្រសាលា*

*A2: ការផ្សព្វផ្សាយសេចក្តីសម្រេចចិត្ត*

*A3: ការដឹកនាំផ្លាស់ប្តូរ និងច្នៃប្រឌិត*

តាមក្រាបខាងលើបង្ហាញថា ការរៀបចំផែនការយុទ្ធសាស្ត្រមានកម្រិត៣.៣០ ដែលស្ថិតនៅទាបជាងមធ្យមភាគក្នុងចំណោមចំណុចរងទាំងបីគឺ ៣.៣៦។

ទិន្នន័យដែលទទួលបានពី ប្រធានក្រុមបច្ចេកទេស និងបុគ្គលិកមិនបង្រៀន ក៏កម្រិតសមត្ថភាពប្រហាក់ប្រហែលនឹងនាយកវាយតម្លៃខ្លួនឯងដែរគឺ៣.៣៨។ តែសមត្ថភាពរងលើផ្នែកផ្សព្វផ្សាយសេចក្តីសម្រេចចិត្តមានកម្រិតទាបជាងគេក្នុងចំណោមចំណុចរងទាំងបីគឺ៣.២៩ ដូចមានបង្ហាញក្នុងក្រាបទី១៣។

បើផ្អែកលើទិន្នន័យគ្រូវិញ គ្រូគិតថា នាយកមានសមត្ថភាពទាប លើការផ្សព្វផ្សាយសេចក្តីសម្រេចចិត្តទៅវិញ។ គ្រូយល់ឃើញថា នាយកទំនងជាមិនបានប្រើប្រាស់មូលដ្ឋានទិន្នន័យ ឬមិនវិភាគទិន្នន័យ ដែលឆ្លងកាត់ការសិក្សាស្រាវជ្រាវច្បាស់ លាស់ក្នុងការរៀបចំផែនការនោះទេ។ ម្យ៉ាងទៀត នាយកខ្វះការទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដើម្បីធ្វើការពិភាក្សាក៏ដូចជាផ្តល់យោបល់ ក្នុងការរៀបចំផែនការសាលា។ សរុបមកតាមរយៈទិន្នន័យ ទាំងពីរខាងលើសមត្ថភាព នាយកសាលាលើផ្នែករៀបចំផែនការយុទ្ធសាស្ត្រ មាន៣.៣៧ ធៀបទៅនឹងស្តង់ដាអាស៊ាន។

ក្រាបទី១៣៖ កម្រិតសមត្ថភាពនាយក លើផ្នែកផែនការយុទ្ធសាស្ត្រ (ប្រធានក្រុមបច្ចេកទេសវាយតម្លៃ)




ក្រាបទី១៤៖ កម្រិតសមត្ថភាពនាយក លើផ្នែកផែនការយុទ្ធសាស្ត្រ (នាយក និងប្រធានក្រុមបច្ចេកទេសវាយតម្លៃ)




ទិន្នន័យដែលទទួលបានពី សំណួរបើកលើផ្នែករៀបចំផែនការយុទ្ធសាស្ត្រ បង្ហាញឱ្យឃើញថា ដំណើរការរៀបចំផែនការទាមទារការកំណត់ចក្ខុវិស័យ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីឲ្យការអនុវត្តផែនការ ការតាមដាន និងការវាយតម្លៃរបស់នាយកសាលាមានប្រសិទ្ធភាព។ ផ្ទុយទៅវិញបញ្ហាប្រឈមលើផ្នែកនេះដោយសមត្ថភាពនាយក នាយិកាសាលានៅមានកម្រិត។ សម្រាប់ផែនការដែលពួកគាត់ធ្លាប់អនុវត្តមានផែនការអភិវឌ្ឍសាលា និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលផ្តោតតែទៅលើការរៀបចំសកម្មភាពតិចតួច ដើម្បីចំណាយថវិកាPB និង SIG។ ការចូលរួមរបស់សហគមន៍ មាតាបិតាសិស្សនៅមានកម្រិតដោយពួកគាត់មិនសូវយកចិត្តទុកដាក់ និងឲ្យតម្លៃសាលា។ កត្តាទាំងនេះអាចបណ្តាលមកពីការគ្រប់គ្រងមិនទាន់មានតម្លាភាព និងការប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចចិត្ត មិនទាន់បានទូលំទូលាយ ដោយខ្វះមូលដ្ឋានច្បាស់លាស់ លើការប្រមូលទិន្នន័យការវិភាគ និងការបកស្រាយទិន្នន័យ។ ការពិនិត្យតាមដានលើការអនុវត្តផែនការនៅមានចំណុចខ្វះខាត លើធនធានមនុស្ស និងថវិកាសម្រាប់គាំទ្រ។

ម្យ៉ាងវិញទៀត នាយកសាលាមិនបានបង្កើតក្រុមការងារសម្រាប់គ្រូតពិនិត្យ បង្កើត និងប្រតិបត្តិចក្ខុវិស័យ បេសកកម្ម និងគោលដៅ ដើម្បីរៀបចំផែនការប្រតិបត្តិក្នុងការលើកកម្ពស់ការអភិវឌ្ឍសាលារៀនដោយចីរភាពទេ។ ជាងនេះទៅទៀត ផែនការយុទ្ធសាស្ត្រមិនបានគិតគ្រប់ជ្រុងជ្រោយទៅដល់ការអប់រំបញ្ចូលគ្នា ក៏ដូចជាភាពខុសគ្នារបស់សិស្សក្នុងសាលា។

### ៣.៥ សមត្ថភាពនាយកក្នុងការដឹកនាំការបង្រៀននិងរៀន

ក្នុងស្តង់ដារអាស៊ាន ការដឹកនាំការបង្រៀន និងរៀន នាយកត្រូវមានសមត្ថភាពដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា ការបង្កើតបរិស្ថានសិក្សាសិស្សមជ្ឈមណ្ឌល ការពិនិត្យកែលម្អ និងការវាយតម្លៃការងាររបស់គ្រូបង្រៀន និងការសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុក។ នាយកសាលាទទួលបានពិន្ទុនៅចន្លោះ ៣.៤៦ ទៅ ៣.៦៨។ ដូចគ្នាដែរ សមត្ថភាពរបស់នាយកលើការរៀបចំផែនការយុទ្ធសាស្ត្រ គឺស្ថិតនៅទាបជាងស្តង់ដាររបស់អាស៊ាន។ តាមទិន្នន័យស្វ័យវង្វាយតម្លៃរបស់នាយក ក៏ដូចគ្នានឹងការវាយតម្លៃពីបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន ជារួមសមត្ថភាពក្នុងការសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុក ជាបញ្ហាប្រឈមជាងគេនៅក្នុងចំណោមសមត្ថភាពរងទាំងបួននៃការដឹកនាំការបង្រៀន និងរៀន។ នាយកទំនងមិនសូវយកចិត្តទុកដាក់ទៅលើផែនការបង្រៀនរបស់គ្រូ។ ផែនការបង្រៀនរបស់គ្រូមិនត្រូវបានបន្ស៊ីនឹងគោលបំណងរបស់សាលា ក៏ដូចជាគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡាដែរ។ ការសម្រេចចិត្តផ្សេងៗរបស់នាយកសាលា លើការងារបង្រៀន និងរៀនមិនបានប្រើប្រាស់ ឬសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយលើលទ្ធផលនៃការសិក្សារបស់សិស្ស។ បើយើងធ្វើការប្រៀបធៀបលើសមត្ថភាពទាំងពីរ ដែលបានលើកយកមកធ្វើការសិក្សាស្រាវជ្រាវ យើងសង្កេតឃើញថា សមត្ថភាពរបស់នាយកលើផ្នែកទាំងពីរនោះ៖ នៅមានកម្រិតបើប្រៀបធៀបជាមួយស្តង់ដារអាស៊ាន។ ប៉ុន្តែសមត្ថភាពលើផ្នែកដឹកនាំការបង្រៀននិងរៀន នាយកសាលាក្នុងប្រទេសកម្ពុជាទំនងជាមានភាពប្រសើរជាងសមត្ថភាពក្នុងការរៀប ចំផែនការយុទ្ធសាស្ត្រ នេះដោយ សារតែនាយកសាលាភាគច្រើនឆ្លងកាត់ការងារបង្រៀនក្នុងចន្លោះពី៥ ទៅ១០ឆ្នាំ មុនត្រូវបានជ្រើសតាំងឱ្យធ្វើជានាយកសាលា។

តាមទិន្នន័យស្វ័យវង្វាយតម្លៃរបស់នាយក សមត្ថភាព ក្នុងការសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុក (B4) មាន៣.៤៦ជាបញ្ហាប្រឈមខ្លាំងជាងគេក្នុងចំណោមសមត្ថភាពរងទាំងបួននៃការដឹកនាំការបង្រៀន និងរៀន។ កត្តាទាំងនេះ៖ អាចបណ្តាលមកពីភាពមិនប្រាកដប្រជាទៅលើធនធាន មនុស្ស សម្ភារ និងថវិកា ក្នុងការគាំទ្រការអនុវត្ត ក៏ដូចជាខ្វះប្រសិទ្ធភាពក្នុងការតាមដាន និងគ្រូតពិនិត្យ។

ក្រាបទី១៥៖ កម្រិតសមត្ថភាពនាយកលើផ្នែកការដឹកនាំការបង្រៀន និងរៀន (នាយកស្វ័យវាយតម្លៃ)




*សម្គាល់៖ ការវាស់វែងផ្អែកលើមាត្រដ្ឋាន likert ១-៥ ដែល ១ = តិចតួចណាស់ និង ៥ = ច្រើនណាស់។*

*B: ការដឹកនាំការបង្រៀន និងរៀន*

*B1: ការដឹកនាំការអនុវត្តនិងការកែលម្អកម្មវិធីសិក្សា*

*B2: ការបង្កើតបរិស្ថានសិក្សាសិស្សមជ្ឈមណ្ឌល*

*B3: ការពិនិត្យកែលម្អនិងការវាយតម្លៃការងាររបស់គ្រូ*

*B4: ការសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុក។*

ក្រាបទី១៦៖ កម្រិតសមត្ថភាពនាយកលើផ្នែកការដឹកនាំបង្រៀន និងរៀន (ប្រធានក្រុមបច្ចេកទេសវាយតម្លៃ)




ទិន្នន័យដែលទទួលបាន ពីប្រធានក្រុមបច្ចេកទេស និងបុគ្គលិកមិនបង្រៀន កម្រិតសមត្ថភាពប្រហាក់ប្រហែលនឹងនាយកស្វ័យវាយតម្លៃខ្លួនឯងដែរគឺ ៣.៥១ជាមធ្យម។ ក្នុងនោះ៖ សមត្ថភាពរងលើផ្នែកការសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុកទាបជាងគេ ក្នុងចំណោមចំណុចរងទាំងបួនគឺ៣.៤១។ ក្រាបខាងក្រោមនេះ បង្ហាញពីសមត្ថភាពទាំងនោះ។

ក្រាបទី១៧៖ កម្រិតសមត្ថភាពនាយកលើផ្នែកការដឹកនាំការបង្រៀន និងរៀន (នាយក និងប្រធានក្រុមបច្ចេកទេសវាយតម្លៃ)




តាមទិន្នន័យដែលទទួលបានពីសំណួរបើក លើផ្នែកដឹកនាំការបង្រៀន និងរៀនបង្ហាញថា បញ្ហាប្រឈមគឺសមត្ថភាពរបស់ពួកគាត់ ដោយមួយចំនួនមិនទាន់យល់ច្បាស់នៅឡើយ លើការអនុវត្ត និងកែលម្អកម្មវិធីសិក្សា។ កត្តាទាំងនេះអាចបណ្តាលមក ពីខ្វះមូលដ្ឋានលើការបង្កើតចក្ខុវិស័យ និងការធ្វើកំណែទម្រង់ឲ្យស្របទៅនឹងតម្រូវការជាក់ស្តែង។ ការអនុវត្តកម្មវិធីសិក្សា គឺយោងទៅតាមផែនការដែលបានគ្រោងទុកនៅតាមខែ ឬឆមាសនីមួយៗ ផ្អែកទៅលើចំនួនម៉ោងសរុប និងចំនួនម៉ោងកំណត់ដោយក្រសួងសម្រាប់គ្រូម្នាក់ៗ និងផ្អែកទៅលើរបាយម៉ោងតាមមុខវិជ្ជា។ ការគណនា និងការរៀបចំបែបនេះ៖ នាយកសាលាមិនទាន់មានមូលដ្ឋានច្បាស់លាស់នៅឡើយ។ កត្តាទាំងនេះអាចនាំឲ្យមានការខ្វះ ឬលើសគ្រូ។ ការតាមដាន និងការវាយតម្លៃដោយឈរលើមូលដ្ឋានអង្កេត របាយការណ៍ប្រចាំខែ របាយការណ៍រដ្ឋបាល ថ្នាក់និទស្សន៍ ការធ្វើអធិការកិច្ចជាប្រព័ន្ធ និងការផ្តល់ព័ត៌មាន ត្រឡប់ពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅមិនទាន់អនុវត្តបានល្អ និងមានភាពយឺតយ៉ាវ ឬខ្វះប្រភពទិន្នន័យ។

បរិស្ថានសិក្សាសិស្សមជ្ឈមណ្ឌល មានការលំបាកដូចជាគ្រូភាគច្រើនជ្រើសរើស វិធីសាស្ត្របង្រៀនតាមបែបប្រពៃណី និងការរៀបចំសកម្មភាពរៀនរបស់សិស្សបានតិចតួច ការប្រើប្រាស់សម្ភារនៅមានកម្រិត ការរៀបចំកិច្ចតែងការបានតិចតួច និងប្រើប្រាស់កិច្ចតែងការចាស់ៗ។ ការធ្វើការងារជាក្រុមបានតិចតួច។

ការពិនិត្យ កែលម្អ និងការវាយតម្លៃគ្រូបង្រៀនមានការលំបាក ដោយការគ្រប់គ្រងបុគ្គលិកមានការដំឡើងកាំតាមលំ ជាប់ជាស្វ័យប្រវត្តិ និងការបើកប្រាក់ខែតាមប្រព័ន្ធធនាគារធ្វើឲ្យនាយកសាលាពិបាកដាក់វិន័យដល់គ្រូដែលអសកម្ម។ បញ្ហាគ្រូអវត្តមានច្រើន និងគ្មានគ្រូជំនួស។ ការធ្វើអធិការកិច្ចថ្នាក់រៀន និងការប្រជុំប្រធានក្រុមបច្ចេកទេសមិនទាន់បានទៀងទាត់ព្រោះនាយកសាលារវល់ការងាររដ្ឋបាល និងការងារសង្គមច្រើនពេក។ ការអភិវឌ្ឍសមត្ថភាពបង្រៀនរបស់បុគ្គលិកមិនស្មើគ្នា នៅមានកម្រិតដោយពួកគាត់បានចូលរួមតិចតួច និងមិនទាន់មានការភ្ញាក់រឭក ឬឆ្លុះបញ្ចាំងខ្លួនឯង ដើម្បីធ្វើជាគំរូល្អនៅឡើយ។ បញ្ហាតម្លាភាព និងអាកប្បកិរិយា ប្រកបដោយក្រមសីលធម៌តម្រូវឲ្យមានការអភិវឌ្ឍ។ បញ្ហាលំបាកក្នុងការបង្កើតរចនាសម្ព័ន្ធ ប្រព័ន្ធតាមដានវាយតម្លៃ អធិការកិច្ចលើផ្នែករដ្ឋបាល និងរបាយការណ៍ស្នាដៃបុគ្គលិកនៅមានភាពយឺតយ៉ាវ។ ការគាំទ្រផ្នែកគរុកោសល្យ ការចុះធ្វើអធិការកិច្ច ការផ្តល់មតិយោបល់លើការបង្ហាត់បង្រៀន ការផ្តល់សម្ភារឧបទេស និងការគាំទ្រផ្នែកថវិកានៅមានកម្រិត។ ការរៀបចំដំណើរការប្រតិបត្តិងាយស្រួលក្នុងការស្រង់អវត្តមាន បញ្ជីចុះហត្ថលេខាតាមម៉ោងបង្រៀនស្របតាមគោលការណ៍របស់ក្រសួង មិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ។ ការគ្រប់គ្រង អវត្តមានគ្រូ ការកំណត់បញ្ហា និងការរៀបចំផែនការសម្រាប់បង្ការទុកជាមុនមិនទាន់បានផ្សព្វផ្សាយទូលំទូលាយ។ ការតាមដាន និងវាយតម្លៃផ្អែកលើសមត្ថភាពបុគ្គលិកម្នាក់ៗ និងលទ្ធផលបង្រៀនមិនទាន់ស្របគ្នា នឹងលទ្ធផលសិក្សារបស់សិស្ស។ ការអង្កេតថ្នាក់ មិនទាន់បានវិភាគរកឲ្យឃើញពីចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីធ្វើជាបង្អែកក្នុងការរៀបចំផែនការបង្រៀន និងរៀននាពេលអនាគត។

ការបង្កើតក្រុម ជាវិធីមួយសម្រាប់ពង្រឹងការបង្រៀន និងរៀន តាមការចូលរួមជាសហគមន៍បណ្តុះបណ្តាលអាជីពមិនទាន់រៀបចំ និងដំណើរការបានល្អនៅឡើយ។ ការចែករំលែកចំណេះដឹង បទពិសោធ ការគាំទ្រក្រុម និងការតាមដានត្រួតពិនិត្យនៅមានកម្រិត។ នាយករងទទួលបន្ទុកការងារបច្ចេកទេស ធ្វើការសហការជាមួយបុគ្គលិកតាមដានការងារ និងការបង្កើតក្លឹបសិក្សាសម្រាប់សិស្សរៀនយឺតមិនទាន់ដំណើរការល្អ ដោយពួកគាត់ជាប់ភារកិច្ចបង្រៀន។ ការរៀបចំវាយតម្លៃដើម្បីពង្រឹងការបង្រៀន និងរៀនដោយរៀបចំតេស្តតាមលក្ខណៈស្តង់ដាជួយឲ្យមានការកែទម្រង់ការបង្រៀន និងរៀន ឬរបៀបគិតរបស់សិស្ស ស្របតាមគោលដៅរបស់សាលាអនុវត្តបានតិចតួច។ ការរៀបចំតេស្តរបស់គ្រូមិនទាន់មានភាពទៀងទាត់ ដោយខ្វះលក្ខណៈ

វិនិច្ឆ័យសមស្របតាមកំណែទម្រង់ថ្មីក្នុងការប្រឡង និងមិនទាន់បានធ្វើការប្រៀបធៀបទៅនឹងបណ្ដាឆ្នាំកន្លងមក ក៏ដូចជាគោលដៅនិងចំណុចដៅតាមផែនការដែលបានគ្រោងទុក។ ការធ្វើតេស្តតាមជំណាក់ និងតេស្តបញ្ចប់ឆ្នាំបានស្រង់ចូលបញ្ជី និងធ្វើចំណាត់ថ្នាក់ តែខ្វះរង្វាន់ដើម្បីលើកទឹកចិត្តដល់សិស្សដែលមាននិទ្ទេសល្អ។ ការវិភាគលទ្ធផលតេស្តតាមមុខវិជ្ជា និងការយកលទ្ធផលសិក្សារបស់សិស្សធ្វើជាបង្អែកក្នុងការសម្រេចចិត្តមិនទាន់អនុវត្តបានល្អ និងការរៀបចំផែនការបន្តតាមរបាយការណ៍ប្រចាំឆ្នាំ និងធ្វើការផ្សព្វផ្សាយដល់សហគមន៍ និងមាតាបិតាសិស្សមិនទាន់បានទូលំទូលាយ។

តាមរយៈទិន្នន័យខាងលើសមត្ថភាពនាយកៈ (១) ការរៀបចំផែនការយុទ្ធសាស្ត្រ និង (២) ការដឹកនាំការរៀន និង បង្រៀនមានកម្រិតទាបនៅឡើយធៀបទៅនឹងស្តង់ដាអាស៊ាន។ ក្នុងចំណោមសមត្ថភាពគោលធំៗទាំងពីរការរៀបចំផែនការយុទ្ធសាស្ត្រមាន ៣.៣៧ និងការដឹកនាំការរៀននិងបង្រៀនមាន៣.៥៤។ ក្រាបខាងក្រោមនេះបង្ហាញពីសមត្ថភាពទាំងនោះ។

ក្រាបទី១៨៖ កម្រិតសមត្ថភាពនាយកលើផ្នែកផែនការយុទ្ធសាស្ត្រ និងការដឹកនាំការបង្រៀន និងរៀន




## ៥. ការសន្និដ្ឋាន និងសំណូមពរ

ទោះបីជាមានចំណុចស្របគ្នាដូចការរៀបរាប់ខាងលើនេះក៏ដោយ ក៏សង្កេតឃើញថា នៅមិនទាន់អាចប្រៀបធៀបបានទៅនឹងកម្រិតសមត្ថភាពអប្បរមានៃស្តង់ដាអាស៊ានដែរ។ ហេតុដូច្នេះហើយសមាសភាពតួនាទីរបស់នាយក នាយករងវិទ្យាល័យនៃប្រទេសកម្ពុជាមិនទាន់ធានាបាននូវស្តង់ដាមួយសមរម្យនៅឡើយ។

នាយកសាលា ទំនងជាមិនបានយល់ច្បាស់លាស់ទេអំពីដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រ។ ផែនការដែលនាយកធ្លាប់រៀបចំ ភាគច្រើនជាផែនការបែបប្រពៃណី ឬតាមទម្លាប់។ កត្តាទាំងនេះអាចមកពីនាយកមួយចំនួនមិនដែលបានទទួលការបណ្តុះបណ្តាល ឬការបណ្តុះបណ្តាលកន្លងមកមិនទាន់ឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តជាក់ស្តែងក៏ដូចជាមិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ។

តាមរយៈការវិភាគស្ថិតិ One Way ANOVA លើអថេរសញ្ញាបត្របង្ហាញថា សមត្ថភាពនាយកក្នុងការរៀបចំផែនការយុទ្ធសាស្ត្រមានភាពខុសគ្នា។ នាយក និងនាយិកាដែលមានសញ្ញាបត្រកាន់តែខ្ពស់ (បរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ) មានសមត្ថភាព ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រខ្ពស់ជាងនាយក និងនាយិកា ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រ។

តាមរយៈការវិភាគស្ថិតិ One Way ANOVA លើអថេរបទពិសោធបម្រើការងារក្នុងការងារអប់រំ បង្ហាញថា សមត្ថភាពនាយកក្នុងការដឹកនាំការបង្រៀន និងរៀនមានភាពខុសគ្នា។ នាយក និងនាយិកាដែលមានបទពិសោធបម្រើការងារយូរឆ្នាំ (ចាប់ពី១០ឆ្នាំឡើងទៅ) មានសមត្ថភាពដឹកនាំការបង្រៀន និងរៀនខ្ពស់ជាងនាយក និងនាយិកាដែលមានបទពិសោធបម្រើការងារតិចជាង១០ឆ្នាំ។ (អតីតភាពជាបុគ្គលិកបង្រៀន)។ កត្តាសញ្ញាបត្រ និងបទពិសោធជាមូលដ្ឋានគ្រឹះសំខាន់ក្នុងតួនាទីដឹកនាំអប់រំ។

តាមស្ថិតិបែបរៀបរាប់ បានបង្ហាញការចូលរួមបំពេញកម្រងសំណួរនាយកមាន៨៣.៩% និងនាយិកាមាន១៦.១% ។ ដូចគ្នានេះដែរ តាមរយៈ T-Test ទៅលើអថេរភេទបានបង្ហាញថា ក្នុងចំណោមសមត្ថភាពរងទាំង៧ នាយិកាមានកម្រិតទាបជាងនាយក លើកលែងតែ(B1)។ គម្លាតទាំងពីរខាងលើគួរបង្រួមឲ្យតូច ដើម្បីសម្រេចបាននូវគោលនយោបាយសមធម៌ក្នុងការគ្រប់គ្រងវិស័យអប់រំ។

ការបណ្តុះបណ្តាលនាយក ក្នុងការរៀបចំផែនការគួរអនុវត្តដើម្បីលើកកម្ពស់ផែនការអភិវឌ្ឍសាលារៀន និងគុណភាពអប់រំ។ ការបណ្តុះបណ្តាលនាយកក្នុងការដឹកនាំការបង្រៀន និងរៀនរឹតតែចាំបាច់ព្រោះនាយកសាលាជាអធិការអចិន្ត្រៃយ៍ប្រចាំសាលានីមួយៗ។ ការបណ្តុះបណ្តាលលើមូលដ្ឋានគ្រឹះទាំងពីរខាងលើនេះ នឹងជួយជំរុញលើការអនុវត្តគោលនយោបាយ និងការពង្រឹងសមត្ថភាព និងភាព

ឆ្លើយតប។ វាបង្កើនទំនាក់ទំនងល្អ និងភាពស៊ីចង្វាក់គ្នារវាង អធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅ។ ប៉ុន្តែរាល់ការបណ្តុះបណ្តាល ឬការបំប៉នត្រូវឲ្យមានភាពច្បាស់លាស់លើខ្លឹមសារ និងគ្រូឧទ្ទេស។ មានន័យថាខ្លឹមសារត្រូវតែឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ហើយអាចយកទៅអនុវត្តបាន។ រីឯគ្រូឧទ្ទេសត្រូវតែមានសមត្ថភាពស្រាវជ្រាវទាំងផ្នែកចំណេះដឹង វិធីសាស្ត្របង្រៀន និងគរុកោសល្យ បើមិនដូច្នេះទេនាំឲ្យមានការខាតបង់កាន់តែច្រើនទៅលើការបណ្តុះបណ្តាល និងការបំប៉ននេះ។ ចូរចងចាំថា ការបណ្តុះបណ្តាល ឬការបំប៉នដែលគ្មានគុណភាពស្មើនឹងការបំផ្លាញ ព្រោះធនធានដែលទទួលបានមិនអាចយកទៅប្រើប្រាស់បាន ហើយអាចធ្វើឲ្យសង្គមគ្មានសុខុមាលភាពទៀតផង។

## ៦. ឯកសារយោង


1) ក្រសួងអប់រំ យុវជន និងកីឡា ២០១៦, គោលនយោបាយស្តីពីគំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ។
2) ក្រសួងអប់រំ យុវជន និងកីឡា ២០១៥, បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា។
3) ក្រសួងអប់រំ យុវជន និងកីឡា ២០១១, តួនាទី និងទំនួលខុសត្រូវរបស់នាយក នាយករង និងលេខាធិការវិទ្យាល័យប្រភេទខេត្តមធ្យម។
4) ក្រសួងអប់រំ យុវជន និងកីឡា, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ២០១១, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។
5) ក្រសួងអប់រំ យុវជន និងកីឡា ២០១០, ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ។
6) ក្រសួងអប់រំ យុវជន និងកីឡា ២០១៤, ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨។
7) ក្រសួងអប់រំ យុវជន និងកីឡា ២០១៤, ផែនការយុទ្ធសាស្ត្រឆ្នាំ២០០៩-២០១៣។
8) រាជរដ្ឋាភិបាលកម្ពុជា ២០១៥, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំ។
9) រាជរដ្ឋាភិបាលកម្ពុជា: យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីរីកចម្រើន ការងារ សមធម៌ និងប្រសិទ្ធភាព។
10) Canole, M. & Young, M. (2013). Standards for Educational Leaders: An Analysis, Washington, D.C
11) Hite, S. & De Grauwe, A. (2009). Capacity development in educational planning and management, Paris, IIEP.
12) Losby, J & Wetmore, A. (2012). Using Likert Scales in Evaluation Survey Work, Atlanta, USA
13) Ministry of Education, Youth and Sport, Royal Government of Cambodia (2014). Education Strategic Plan.
14) MoEYs, Enhanced Education Quality Project (EEQP), A Report to the World Bank.
15)Philip, H. and Joseph, F.(1987). Assessing and Developing Principal Instructional Leadership.
16)Philip, H. and Wen-Chung. W.(2015). Assessing Instructional Leadership with the Principal Instructional Management Rating Scale. ISBN 978-3-319-15533-3, p: 14.
17) Phillip, H. (2003). Leading Educational Change: reflections on the practice of instructional and transformational leadership Cambridge Journal of Education, Vol. 33, No. 3.
18) Seung-Hwan, H. (2015). Agreement of self-other perceptions matters: Analyzing the effectiveness of principal leadership through multi-source assessment. Australian Journal of Education, Vol. 59(3) 225–246.
19) SEAMEO INNOTECH,(2014). Competency Framework for Southeast Asian School Heads.

# ទស្សនៈរបស់មន្ត្រីអប់រំស្តីពីអធិការកិច្ចអប់រំជាប្រព័ន្ធ

ឌី បុណ្ណា ម៉ម ចាន់សៀន នួម រ៉ាដា សេង សច្ចា សៀង វាសនា លន លីណា ញ៉ែម ចន្ធា ម៉ន មុនិន្ទ លាង តុលា ប៉ែន សំភា

វិទ្យាស្ថានជាតិអប់រំ

សារអេឡិចត្រូនិចទំនាក់ទំនង៖ mamchansean@gmail.com

***មូលន័យសង្ខេប៖*** *អធិការកិច្ចអប់រំជាប្រព័ន្ធ ត្រូវបានណែនាំឱ្យអនុវត្តដើម្បីធានាគុណភាពអប់រំនៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០១៥ មកម្លេះ បន្ទាប់ពីអធិការបឋមសិក្សា និងអធិការមធ្យមសិក្សាតាមមុខវិជ្ជាដែលមានស្រាប់បានទទួលការបំប៉នអំពីប្រព័ន្ធអធិការកិច្ចថ្មីនេះដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិអប់រំ។ ការរៀបចំកម្មវិធីបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌអធិការថ្មី និងការបណ្តុះបណ្តាលគ្រូឧទ្ទេសអធិការ ត្រូវបានគាំទ្រដោយអធិការដ្ឋានអប់រំនៃប្រទេសស៊ុយអែត។ ការស្រាវជ្រាវនេះមានគោលបំណងឈ្វេងយល់ពីទស្សនៈរបស់មន្ត្រីអប់រំលើអធិការកិច្ចអប់រំជាប្រព័ន្ធ និងទស្សនៈរបស់សិក្ខាកាមដែលបានទទួលការបណ្តុះបណ្តាលពីអធិការកិច្ចអប់រំជាប្រព័ន្ធដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ។ លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា៖ (១) មន្ត្រីអប់រំគ្រប់កម្រិតថ្នាក់ មានទស្សនៈថាអធិការកិច្ចអប់រំជាប្រព័ន្ធអាចធានាគុណភាពអប់រំបានកម្រិតខ្ពស់ ស្របនឹងសសរស្តម្ភទី៣នៃវិធានការកែទម្រង់វិស័យអប់រំដែលផ្តោតសំខាន់លើពីការងារអធិការកិច្ច ហើយវាជាពេលវេលាដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវចាប់ផ្តើមអនុវត្តកិច្ចការនេះជាប្រព័ន្ធហើយ ដើម្បីធានាគុណភាពអប់រំឱ្យបានល្អ និងដើម្បីប្រកួតប្រជែងជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក, (២) មន្ត្រីអប់រំដែលមានការងារពាក់ព័ន្ធនឹងការងារអធិការកិច្ចមានសុធន្ទៈក្នុងការអនុវត្តប្រព័ន្ធអធិការកិច្ចថ្មី, (៣) មន្ត្រីអប់រំ ដែលបានទទួលការបណ្តុះបណ្តាលពីប្រព័ន្ធអធិការកិច្ចអប់រំជាប្រព័ន្ធ បានវាយតម្លៃថាគ្រូឧទ្ទេសអធិការអប់រំមានសមត្ថភាពខ្ពស់ក្នុងការរៀបចំមេរៀន និងការ- បណ្តុះបណ្តាល, ហើយ (៤) រាល់ខ្លឹមសារមេរៀនដែលបានរៀបចំមានទំនាក់ទំនងខ្លាំងទៅនឹងការងារប្រចាំថ្ងៃរបស់គាត់ជាអធិការ ឬជានាយកសាលារៀន។*

***ពាក្យគន្លឹះ៖*** *អធិការកិច្ចអប់រំជាប្រព័ន្ធ អធិការកិច្ចសាលារៀន គុណភាពអប់រំ មន្ត្រីអប់រំ កម្មវិធីបណ្តុះបណ្តាល*

## ១. សេចក្តីផ្តើម

អធិការកិច្ចសាលារៀនគឺជាវិធីមួយដ៏ចម្បង និងមាន ប្រសិទ្ធភាពនៅក្នុងបណ្តាប្រទេសជាច្រើន ដើម្បីពិនិត្យថាតើសាលារៀនអនុវត្ត និងទទួលខុសត្រូវលើការងារបានកម្រិតណា (Colin, ២០០៤)។ អធិការកិច្ចសាលារៀន ជាឧបករណ៍សម្រាប់ពិនិត្យតាមដាន និងកែលម្អគុណភាពអប់រំនៅតាមសាលារៀន នៅក្នុងបណ្តាប្រទេសជាច្រើន ជាពិសេសនៅអឺរ៉ុប (Marielle, ២០១២)។ Marielle (២០១២) បានបន្ថែមទៀតថា អធិការដ្ឋានអប់រំពឹងថាសាលារៀនដែលបានចុះអធិការកិច្ច នឹងកែលម្អតាមព័ត៌មាន ត្រឡប់ដែលផ្តល់ទៅសាលារៀនតាមរយៈការផ្តល់ជំបូន្មាន និងការណែនាំក្នុងអំឡុងពេលចុះអធិការកិច្ច និងតាមរយៈរបាយការណ៍អធិការកិច្ច។ អធិការកិច្ចសាលារៀនធ្វើឱ្យសាលារៀនមានការកែលម្អ និងធ្វើឱ្យគ្រូបង្រៀនផ្លាស់ប្តូរ ឥរិយាបថ (Chapman, ២០០១; Dedering & Muller, ២០១១)។ ការផ្តល់ព័ត៌មានត្រឡប់អំពីចំណុចគួរកែលម្អ ដោយមានការឯកភាពគ្នារវាងអធិការ និងសាលារៀនអំពីសកម្មភាពត្រូវកែលម្អបានធ្វើឱ្យមានភាពផ្លាស់ប្តូរប្រសើរឡើងនៅក្នុងសាលារៀន (Ehren & Visscher, ២០០៨; Dedering & Muller, ២០១១)។

ប្រទេសកម្ពុជា បានផ្តល់តម្លៃខ្ពស់ដល់ការងារអធិការកិច្ចក្នុងការធានាគុណភាពអប់រំ។ តាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅជំពូកទី៦៣ បានចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិតថ្នាក់ និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប"។[១] តាមច្បាប់ស្តីពីការអប់រំនៅមាត្រា២១ បានចែងថា "រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំ..........ប្រកបដោយប្រសិទ្ធភាព" ។[២] ដើម្បីធានាគុណភាពអប់រំ ស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា អធិការកិច្ចអប់រំជាតម្រូវការចាំបាច់។ អធិការកិច្ចត្រូវបានកំណត់ជាចំណុចអាទិភាពមួយ នៅក្នុង

[១] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[២] ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧

គោលការណ៍កំណែទម្រង់ទាំង១៥ចំណុច របស់ក្រសួងអប់រំ យុវជន និងកីឡា។

អធិការកិច្ចសាលារៀនត្រូវបានអនុវត្ត នៅប្រទេសកម្ពុជា ចាប់តាំងពីប្រទេសស្ថិតនៅក្រោមអាណាព្យាបាលបារាំងមកម្លេះ(១៨៦៣-១៩៤៥) និងបន្តរហូតដល់ឆ្នាំ១៩៧៥។ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ប្រទេសកម្ពុជាពុំមានប្រព័ន្ធអប់រំច្បាស់លាស់ទេ ដោយសារប្រទេសនេះធ្លាក់ក្នុងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ។ ចាប់ពីឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្នអធិការកិច្ចសាលារៀន ជាមធ្យោបាយមួយសម្រាប់ ធានាគុណភាពអប់រំនៅកម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតក្របខ័ណ្ឌអធិការបឋមសិក្សា និងអធិការមធ្យមសិក្សានៅឆ្នាំ១៩៩៤ ដោយមានកំណត់ ពីភារកិច្ចសំខាន់ៗច្បាស់លាស់។ អធិការបឋមសិក្សា ធ្វើអធិការកិច្ចទូទៅនៅសាលាបឋមសិក្សា។ ចំណែកឯអធិការមធ្យមសិក្សា ធ្វើអធិការកិច្ចក្នុងក្របខ័ណ្ឌនៃមុខវិជ្ជាឯកទេសរបស់ខ្លួន។[៣] ក្រោមការជួយឧបត្ថម្ភរបស់អធិការដ្ឋានអប់រំ នៃប្រទេសស៊ុយអែត កម្ពុជា បានផ្លាស់ប្តូរពីការអនុវត្តអធិការកិច្ចតាមមុខវិជ្ជាឯកទេសមកជា "អធិការកិច្ចអប់រំជាប្រព័ន្ធ ឬហៅថាប្រព័ន្ធអធិការកិច្ចថ្មី"។ គ្រូឧទ្ទេសចំនួន ២១នាក់ ដែលបានជ្រើសរើសដោយក្រសួងអប់រំ យុវជន និងកីឡា មកពីវិទ្យាស្ថានជាតិអប់រំ និងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិមួយចំនួនទៀតត្រូវបានទទួលការបណ្តុះបណ្តាលរយៈពេលមួយឆ្នាំ ក្នុងឆ្នាំ២០១៤ នៅវិទ្យាស្ថានជាតិអប់រំ និងមានការដាក់ការសិក្សាស្រាវជ្រាវ លើក្របខ័ណ្ឌអធិការកិច្ចអប់រំថ្មី។ អធិការមានស្រាប់ (អធិការបឋមសិក្សា និងអធិការមធ្យមសិក្សា) នៅទូទាំងប្រទេសត្រូវបានអញ្ជើញឱ្យចូលរួមវគ្គបណ្តុះ បណ្តាល អំពីអធិការកិច្ចអប់រំជាប្រព័ន្ធចំនួន៦ម៉ូឌុល ក្នុងឆ្នាំ២០១៥ ដែលម៉ូឌុលទី១ស្តីពីសេចក្តីផ្តើម និងទិដ្ឋភាពរួមនៃការធានាគុណភាពអប់រំ ម៉ូឌុលទី២ស្តីពីអធិការកិច្ចអប់រំជាប្រព័ន្ធ ម៉ូឌុលទី៣ស្តីពីឧបករណ៍ និងដំណើរការអធិការកិច្ចអប់រំជាប្រព័ន្ធ ម៉ូឌុលទី៤ស្តីពីការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ ម៉ូឌុលទី៥ស្តីពីការវិភាគ និងសរសេររបាយការណ៍អធិការកិច្ច និងម៉ូឌុលទី៦ស្តីពីការបូកសរុប និងការវាយតម្លៃ។ នាយក-នាយិកាវិទ្យាល័យចំនួន៧០នាក់ ត្រូវបានអញ្ជើញឱ្យចូលរួមវគ្គបំប៉នពីប្រព័ន្ធអធិការកិច្ចជាប្រព័ន្ធនេះ ក្នុងឆ្នាំ២០១៥ និង២០១៦ ដែលមានចំនួន៤ម៉ូឌុលចំពោះម៉ូឌុលទី១ ដល់ទី៣ដូចគ្នានឹងម៉ូ-ឌុល ដែលបណ្តុះបណ្តាលអធិការមានស្រាប់ដែរ ហើយម៉ូ-ឌុលទី៤ស្តីពីការរៀបចំផែនការអភិវឌ្ឍសាលារៀន ដោយផ្អែកលើលទ្ធផលអធិការកិច្ច។ អធិការអប់រំថ្មីត្រូវបានចាប់ផ្តើមជ្រើសរើស និងទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ក្នុងរយៈពេល១០ខែ ចាប់ពីឆ្នាំ២០១៥ មានចំនួន១៤មុខវិជ្ជា ដែលមុខវិជ្ជាទី១៖ ទស្សនវិជ្ជាអប់រំ មុខវិជ្ជាទី២៖ ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង និងសរសេរ មុខវិជ្ជាទី៣៖ ការប្រើប្រាស់កុំព្យូទ័រក្នុងការងាររដ្ឋបាល មុខវិជ្ជា ទី៤៖ ការគ្រប់គ្រង និងផែនការ មុខវិជ្ជាទី៥៖ ការគ្រប់គ្រង និងដឹកនាំអប់រំ មុខវិជ្ជាទី៦៖ ទិដ្ឋភាពទូទៅ និងក្របខ័ណ្ឌច្បាប់ មុខវិជ្ជាទី៧៖ ប្រព័ន្ធអធិការកិច្ចអប់រំជាប្រព័ន្ធ មុខវិជ្ជាទី៨៖ការវិភាគ និងសរសេររបាយការណ៍ មុខវិជ្ជាទី៩៖ ស្វ័យវាយតម្លៃសាលារៀន មុខវិជ្ជាទី១០៖ វិធីសាស្ត្របង្រៀន និងរៀន មុខវិជ្ជាទី១១៖ ការសរសេរ និងអភិវឌ្ឍកម្មវិធីសិក្សា មុខវិជ្ជាទី១២៖ ការពិនិត្យកែលម្អសាលារៀន មុខវិជ្ជាទី១៣៖ ការពិនិត្យតាមដាន និងវាយតម្លៃអប់រំ និងមុខវិជ្ជាទី១៤៖ ការគ្រប់គ្រងអាស្រ័យតាមសាលារៀន។[៤]

ការស្រាវជ្រាវនេះ មានវត្ថុបំណងឈ្វេងយល់អំពីទស្សនៈ របស់មន្ត្រីអប់រំ លើអធិការកិច្ចអប់រំជាប្រព័ន្ធ និងការវាយតម្លៃរបស់សិក្ខាកាមលើ វគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធអធិការកិច្ចអប់រំថ្មីនេះ ដែលបានរៀបចំដោយវិទ្យាស្ថានជាតិអប់រំ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦។ ដើម្បីសម្រេចវត្ថុបំណងខាងលើ ក្រុមស្រាវជ្រាវបានកំណត់នូវសំណួរស្រាវជ្រាវដូចខាងក្រោម៖

- តើមន្ត្រីអប់រំមានទស្សនៈយ៉ាងណាចំពោះអធិការកិច្ចអប់រំជាប្រព័ន្ធក្នុងការធានាគុណភាពអប់រំ?
- តើវគ្គបណ្តុះបណ្តាលស្តីពី"អធិការកិច្ចអប់រំជាប្រព័ន្ធ" មានប្រសិទ្ធភាពកម្រិតណា?

## ២. វិធីសាស្ត្រស្រាវជ្រាវ

### ២.១ ភាគសំណាក

ការស្រាវជ្រាវនេះផ្តោតទៅលើតែមន្ត្រីអប់រំ ដែលធ្លាប់បានចូលរួមវគ្គបំប៉ន ឬបណ្តុះបណ្តាលស្តីពី អធិការកិច្ចអប់រំជាប្រព័ន្ធដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ និងអ្នកដែលធ្លាប់បានចូលរួម នៅក្នុងដំណើរការអធិការកិច្ចអប់រំជា

[៣] បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា ឆ្នាំ២០១៥

[៤] កម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានជាតិអប់រំឆ្នាំ២០១៥

ប្រព័ន្ធ។ ភាគសំណាកទាំងនោះរួមមានៈ ប្រធាន ឬអនុប្រធានមន្ទីរ ប្រធាន ឬអនុប្រធានការិយាល័យអធិការកិច្ចអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡាចំនួន៧ខេត្ត អធិការអប់រំ ដែលកំពុងបម្រើការងារអធិការកិច្ចនៅតាមរាជធានី-ខេត្ត និងនាយកដ្ឋានធានាគុណភាពអប់រំចំនួន៥៣នាក់ និស្សិតអធិការអប់រំចំនួន៣១នាក់ នាយកសាលារៀនដែលក្រសួង បានចុះធ្វើអធិការកិច្ចអប់រំជាប្រព័ន្ធសាកល្បងចំនួន១៥នាក់ និងលោកគ្រូ-អ្នកគ្រូដែលត្រូវបានសង្កេតការបង្រៀនដោយក្រុមអធិការអប់រំជាប្រព័ន្ធ ចំនួន៩៥នាក់។

## ២.២ ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវប្រើប្រាស់កម្រងសំណួរសម្រាប់បំពេញ និងកម្រងសំណួរសម្រាប់សម្ភាសន៍។

## ២.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

ក្រុមស្រាវជ្រាវបានចុះទៅសម្ភាសប្រធាន ឬអនុប្រធាន មន្ទីរ និងប្រធាន ឬអនុប្រធានការិយាល័យអធិការកិច្ចអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ កម្រងសំណួរសម្រាប់បំពេញ ត្រូវបានចែកជូនដល់អធិការអប់រំមានស្រាប់ និងនិស្សិតអធិការអប់រំ ក្នុងអំឡុងពេលទទួលការបណ្ដុះបណ្ដាល នៅវិទ្យាស្ថានជាតិអប់រំ។ ចំណែកនាយក-នាយិកា និងគ្រូបង្រៀនត្រូវបានចែកកម្រងសំណួរបំពេញនៅសាមីសាលា។

## ២.៤ វិធីសាស្ត្រវិភាគទិន្នន័យ

ការស្រាវជ្រាវនេះ ជាការស្រាវជ្រាវបែបពិពណ៌នាដោយប្រើប្រាស់ទិន្នន័យបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបែបរិមាណវិស័យត្រូវបានវិភាគជាមធ្យមភាគសម្រាប់ឆ្លុះបញ្ចាំងពីទស្សនៈរបស់មន្ត្រីអប់រំ លើអធិការកិច្ចអប់រំជាប្រព័ន្ធ។ លើសពីនេះ ការវិភាគទិន្នន័យបែបបរិមាណវិស័យត្រូវបានគាំទ្រដោយការពន្យល់ ឬបញ្ជាក់ហេតុផល ដែលទាក់ទងកម្រិតវាយតម្លៃចំណុចនីមួយៗ។ ការវិភាគបានប្រៀបធៀប និងសំយោគពីទស្សនៈ របស់មន្ត្រីអប់រំ ដែលបានចូលរួមក្នុងដំណើរការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធរួមមានៈ (១)ប្រធាន ឬអនុប្រធានមន្ទីរនិងប្រធានឬអនុប្រធានការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលជាអ្នកគ្រប់គ្រង (២) អធិការមានស្រាប់និងនិស្សិតអធិការ ដែលអនុវត្តការងារអធិការកិច្ចអប់រំ និង (៣) នាយក-នាយិកាសាលានិងគ្រូបង្រៀនដែលជាអ្នកត្រូវបានធ្វើអធិការកិច្ច ដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគាត់ អំពីការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធនៅកម្ពុជា។ ដោយឡែកចំពោះការវាយតម្លៃវគ្គបណ្ដុះបណ្ដាល គឺមានតែមន្ត្រីអប់រំដែលជាអធិការមានស្រាប់ និស្សិតអធិការ និងនាយក-នាយិកាសាលារៀនដែលបានចូលរួមវគ្គបណ្ដុះ បណ្ដាលដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំតែប៉ុណ្ណោះ។

## ៣. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

មន្ត្រីគ្រប់គ្រងថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបានទទួលព័ត៌មានអំពីអធិការកិច្ចអប់រំជាប្រព័ន្ធ។ តាមរយៈការសម្ភាសជាមួយប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបង្ហាញថា គាត់បានដឹងអំពីអធិការកិច្ចអប់រំជាប្រព័ន្ធតាមរយៈសិក្ខាសាលា ដែលរៀបចំដោយនាយកដ្ឋានធានាគុណភាពអប់រំ វិទ្យាស្ថានជាតិអប់រំ និងតាមរយៈរបាយការណ៍របស់អធិការ និងការិយាល័យអធិការកិច្ចរបស់មន្ទីរ។ ដូចនេះបង្ហាញឱ្យឃើញថា ព័ត៌មានស្ដីពីអធិការកិច្ចអប់រំជាប្រព័ន្ធ ត្រូវបានផ្សព្វផ្សាយដល់ថ្នាក់ដឹក-នាំរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ ប៉ុន្តែពួកគាត់ មិនទាន់យល់ច្បាស់អំពីដំណើរការអធិការកិច្ចអប់រំជាប្រព័ន្ធនៅឡើយទេ។ ពួកគាត់អាចពន្យល់បានតិចតួចប៉ុណ្ណោះអំពីអត្ថន័យ និងដំណើរការអធិការកិច្ចអប់រំជាប្រព័ន្ធ ដោយពួកគាត់ពុំទាន់បានទទួលវគ្គបំប៉នលម្អិតពីវិទ្យាស្ថានជាតិអប់រំ។ ចំណែកប្រធាន ឬអនុប្រធានការិយា ល័យអធិការកិច្ច ដែលបានផ្ដល់ការសម្ភាសនៅក្នុងការស្រាវជ្រាវនេះអាចពន្យល់បានយ៉ាងល្អអំពីអត្ថន័យ និងដំណើរការអធិការកិច្ចអប់រំជាប្រព័ន្ធដោយសារគាត់បានទទួលវគ្គបំប៉ន ឬបណ្ដុះបណ្ដាលអំពីអធិការកិច្ចជាប្រព័ន្ធ ដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ និងសិក្ខាសាលាផ្សេងៗទៀត ដែលរៀបចំដោយនាយកដ្ឋានធានាគុណភាពអប់រំ។

អធិការមានស្រាប់ និស្សិតអធិការ នាយកសាលារៀន បានយល់ច្បាស់ អំពីដំណើរការអធិការកិច្ចអប់រំជាប្រព័ន្ធ។ តាមរយៈកម្រងសំណួរ ពួកគាត់បានពន្យល់ថា អធិការកិច្ចអប់រំជាប្រព័ន្ធខុសពីអធិការកិច្ចអប់រំតាមមុខវិជ្ជាដែលអធិការ ធ្វើអធិការកិច្ចតែទៅលើមុខវិជ្ជាឯកទេស

នីមួយៗ តែប៉ុណ្ណោះ។ ចំណែកឯអធិការកិច្ចជាប្រព័ន្ធវិញ អធិការម្នាក់អាចមើលការបង្រៀនរបស់គ្រូនៅគ្រប់មុខវិជ្ជា ហើយគាត់បានបញ្ជាក់ថា អធិការកិច្ចតាមកាលកំណត់គឺពិនិត្យមើលលើបួនចំណុចសំខាន់ៗរួមមាន៖ ការគ្រប់គ្រងការបង្រៀននិងរៀន លទ្ធផលសិក្សារបស់សិស្ស និងស្វ័យវាយតម្លៃសាលារៀន។ គ្រូបង្រៀនពុំទាន់បានយល់អំពីដំណើរការអធិការកិច្ចបែបថ្មីនេះទេ គាត់នៅយល់ច្រឡំទៅនឹងអធិការកិច្ចតាមមុខវិជ្ជាដែលធ្លាប់បានអនុវត្តកន្លងមក។ នេះអាចសរបញ្ជាក់ថានាយក ឬនាយិកាសាលារៀនដែលបានចូលរួមវគ្គបំប៉នអំពីប្រព័ន្ធអធិការកិច្ចអប់រំជាប្រព័ន្ធ មិនបានផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីប្រព័ន្ធអធិការកិច្ចថ្មីនេះដល់បុគ្គលិក នៅក្នុងសាលារៀនរបស់គាត់នៅឡើយទេ។

ទោះបីក្រុមគោលដៅទាំងអស់ មានការយល់ដឹងពីប្រព័ន្ធអធិការកិច្ចអប់រំជាប្រព័ន្ធ នៅមានកម្រិតផ្សេងៗគ្នាក៏ដោយ ក៏ពួកគាត់បានបញ្ចេញនូវទស្សនៈរបស់ខ្លួនប្រកបដោយឯករាជ្យភាពរបស់គាត់ អំពីប្រព័ន្ធអធិការកិច្ចថ្មីនេះដូចខាងក្រោម៖

### ៣.១ អធិការកិច្ចអប់រំជាប្រព័ន្ធ

### អំពីការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ

ក្រុមគោលដៅ ដែលចូលរួមបានបញ្ចេញទស្សនៈរបស់ខ្លួនតាមរយៈកម្រងសំណួរថា ពួកគាត់ធ្លាប់បានចូលរួមអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ យ៉ាងតិចចំនួន១ដង។ អធិការអប់រំដែលកំពុងបម្រើការងារអធិការកិច្ច និងនិស្សិតអធិការអប់រំ បានចុះអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ បានចំនួនពី១ ទៅ៤សាលា។ ចំណែកឯនាយក-នាយិកាសាលារៀនបានចូលរួមចំនួនពី១ ទៅ៦ដង និងគ្រូបង្រៀនធ្លាប់បានចូលរួមចាប់ពី១ ទៅ៣ដង ដែលដំណើរការទាំងអស់នេះរួមមានអធិការកិច្ចសាកល្បង ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តដែលបានផ្តល់ការសម្ភាស ពុំទាន់បានរៀបចំផែនការច្បាស់លាស់ក្នុងការចុះអធិការកិច្ចសាលារៀន ដោយប្រើប្រព័ន្ធអធិការកិច្ចអប់រំជាប្រព័ន្ធនៅឡើយទេ។ ចំណែកប្រធានការិយាល័យអធិការកិច្ចមួយចំនួន បានបង្ហាញពីគម្រោងផែនការក្នុងការចុះអធិការកិច្ចសាលារៀន តែពុំទាន់ក្លាយជាផែនការសកម្មភាព ដែលមានការឯកភាពពីប្រធានស្ថាប័ននៅឡើយ។ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាមួយចំនួននៅមានទស្សនៈពុំទាន់បានទូលាយ ទៅលើអធិការកិច្ចបែបថ្មីនេះទេ ដោយនៅយល់ឃើញថា អធិការដែលមានក្របខណ្ឌជាអធិការបឋមសិក្សា មិនអាចចុះអធិការកិច្ចនៅមធ្យមសិក្សាបានទេ។ ប៉ុន្តែការពិត តាមគោលការណ៍អធិការកិច្ចអប់រំជាប្រព័ន្ធអធិការ មិនចាំបាច់មានចំណេះដឹងជំនាញទាក់ទងទៅនឹង គ្រប់មុខវិជ្ជាឯកទេសទាំងអស់ឡើយ ដោយអធិការត្រូវ ពិនិត្យមើលលើសមាសភាគសំខាន់ៗចំនួនបួនគឺ ការដឹកនាំ និងគ្រប់គ្រង ការបង្រៀននិងរៀន លទ្ធផលសិក្សារបស់សិស្ស និងស្វ័យវាយតម្លៃសាលារៀន។ អធិការកិច្ចថ្មីនេះមិនផ្តោតសំខាន់តែទៅលើការបង្រៀនលើមុខវិជ្ជាឯកទេសនីមួយៗឡើយ។

ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ភាគច្រើនបានបង្ហាញថា ពួកគាត់ជួបប្រទះនូវបញ្ហាលំបាកមួយចំនួន ក្នុងការអនុវត្តការងារអធិការកិច្ចអប់រំថ្មីនេះ ពីព្រោះពួកគាត់៖ ពុំទាន់យល់ច្បាស់អំពីប្រព័ន្ធនេះ ខ្វះអធិការ ខ្វះថវិកា និងខ្វះធនធានសម្ភារ។ ប្រធាន ឬអនុប្រធានការិយាល័យអធិការកិច្ចវិញ បានសម្តែងនូវការលំបាកដោយ៖ (១) ពិបាកក្នុងការជំរុញសាលារៀនឱ្យមានការកែលម្អតាមអនុសាសន៍របស់អធិការ (២) មិនមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការឱ្យដំបូន្មាននិងណែនាំដល់សាលារៀន និង (៣) មានកង្វល់ពីសមត្ថភាពអធិការ និងអធិការម្នាក់ត្រូវពិនិត្យមើលការបង្រៀននៅគ្រប់មុខវិជ្ជា។ រីឯអធិការមានស្រាប់ និងនិស្សិតអធិការដែលជាអ្នកអនុវត្តបានបញ្ចេញទស្សនៈថា ពួកគាត់ជួបប្រទះនូវបញ្ហាមួយចំនួនក្នុងការចុះអធិការកិច្ច ដូចជាបញ្ហាក្នុងដំណើរការអនុវត្តធនធានសម្ភារ ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងបញ្ហាមួយចំនួនទៀត។ ពួកគាត់ពុំទាន់យល់ច្បាស់ពីដំណើរការអនុវត្តការងារអធិការកិច្ចថ្មី ដោយធ្លាប់តែអនុវត្តអធិការកិច្ចចាស់ ហើយអធិការកិច្ចថ្មីមានសូចនាករច្រើនតែពេលវេលាអនុវត្តខ្លី និងពិបាកក្នុងការសរសេររបាយការណ៍។ អធិការនៅមានការខ្វះខាតផ្នែកធនធានសម្ភារដូចជា មធ្យោបាយធ្វើដំណើរ កុំព្យូទ័រ និងម៉ាស៊ីនបោះពុម្ពជាដើម។ ម្យ៉ាងវិញទៀត អ្នកពាក់ព័ន្ធដែលចូលរួមផ្តល់ព័ត៌មាន ដូចជានាយកសាលារៀន គ្រូបង្រៀន និងសិស្សជាដើមពុំហ៊ានផ្តល់ព័ត៌មានពិតដោយអធិការម្នាក់បាននិយាយថា *"សិស្ស សហគមន៍ គ្រូមិនទាន់ហ៊ានបញ្ចេញមតិការពិត"*។ ជាងនេះទៅទៀត អធិការ ពុំមានឥទ្ធិពលក្នុងការជំរុញឱ្យសាលារៀនអនុវត្ត

តាមអនុសាសន៍ដែលខ្លួនបានផ្តល់ឱ្យ ហើយអធិការខ្លួនឯងមិនអាចដោះស្រាយបានភ្លាមៗ នូវបញ្ហាដែលជួបប្រទះ។ សាលារៀនមួយចំនួន ពុំទាន់បានស្គាល់អធិការកិច្ចអប់រំថ្មី។ ចំណែកនាយក-នាយិកាសាលារៀនភាគច្រើនបានបញ្ចេញទស្សនៈថា ពួកគាត់ពុំមានជួបការលំបាកអ្វីគួរឱ្យកត់សម្គាល់ឡើយ លើកលែងតែការរៀបចំឯកសារសម្រាប់អធិការពិនិត្យ ពិបាកក្នុងការបំពេញឯកសារ ខ្វះឯកសារដែលអធិការត្រូវការ និងការជូនដំណឹងសម្រាប់ការចុះអធិការកិច្ចមានរយៈពេលខ្លីពេក។

ដើម្បីឱ្យការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ ប្រព្រឹត្តទៅបានល្អ ជាទស្សនៈរបស់អធិការតាមរយៈកម្រងសំណួរបានលើកឡើងនូវចំណុចមួយចំនួនដូចជា ក្រសួងគួរចេញសារាចរណែនាំ កំណត់ពីតួនាទី និងភារកិច្ចអធិការឱ្យបានច្បាស់លាស់ដើម្បីឱ្យពួកគាត់អនុវត្តការងារឱ្យមានប្រសិទ្ធ-ភាព។

ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តបានគាំទ្រ និងជំរុញការអនុវត្តការងារអធិការកិច្ច។ តាមរយៈការ-សម្ភាស លោកប្រធាន និងអនុប្រធានមន្ទីរបានមានប្រសា-សន៍ថា មន្ទីរមានកញ្ចប់ថវិកាសម្រាប់ដំណើរការអធិការកិច្ចអប់រំជាប្រព័ន្ធ ដូចជាថវិកាកម្មវិធី ឬ Programme Budget (PB) ព្រមទាំងមានគោលការណ៍ណែនាំពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជំរុញអនុវត្តអធិការកិច្ចជាប្រព័ន្ធថ្មីនេះ។ ប្រធាន និងអនុប្រធានការិយាល័យអធិការកិច្ចមានប្រសាសន៍ថា គាត់គាំទ្រ និងជំរុញការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធទាំងស្រុង ដោយអធិការកិច្ចថ្មីនេះត្រូវពិនិត្យលើចំណុចខ្លាំង និងចំណុចខ្សោយរបស់សាលារៀន ដោយផ្តោតលើ៤ចំណុច រួមមាន ការគ្រប់គ្រងនិងដឹកនាំ ការ-បង្រៀននិងរៀន លទ្ធផលសិក្សារបស់សិស្ស និងស្វ័យវាយតម្លៃសាលារៀន ដែលអាចជួយឱ្យសាលារៀនមានការ-អភិវឌ្ឍ។ ទន្ទឹមនឹងការគាំទ្រពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត អធិការ និងនិស្សិតអធិការនៅត្រូវការការគាំទ្របន្ថែមទៀត ដើម្បីឱ្យការអនុវត្តអធិការកិច្ចជាប្រព័ន្ធប្រព្រឹត្តទៅបានល្អ។ ពួកគាត់បានសុំឱ្យមានការគាំទ្របន្ថែមទៀតលើ៖ (១) ឯកសារផ្លូវច្បាប់ពាក់ព័ន្ធនឹងការងារអធិការកិច្ច (២) សម្ភារនិងមធ្យោបាយធ្វើដំណើរ (៣) បង្កើនប្រាក់បេសកកម្មឱ្យស្មើនឹងអ្នកមានតួនាទី នៅក្នុងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត (៤) ការគាំទ្រពីអ្នកពាក់-ព័ន្ធនានា ទាំងផ្នែកបច្ចេកទេសនិងថវិកា (៥) ត្រូវការការ-បណ្តុះបណ្តាលនាយក-នាយិកាសាលារៀន និងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ឬ District Training and Monitoring Team (DTMT) ឱ្យបានច្បាស់ពីស្វ័យវាយតម្លៃសាលារៀន (៦) ត្រូវមានកញ្ចប់ថវិកាដោយ-ឡែកសម្រាប់ការិយាល័យអធិការកិច្ច (៧) បំប៉នបន្ថែមលើជំនាញក្នុងការវិភាគទិន្នន័យ និងសរសេររបាយការណ៍ (៨) មានឯករាជ្យភាពក្នុងការបញ្ជូនរបាយការណ៍ ទៅនាយកដ្ឋានធានាគុណភាពអប់រំដោយផ្ទាល់ និងត្រូវការបញ្ចូលរបាយការណ៍ ទៅក្នុងប្រព័ន្ធព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា (៩) ត្រូវការឯករាជ្យភាព ដោយចំណុះតែនាយកដ្ឋានធានាគុណភាពអប់រំ និង (១០) លើកទឹកចិត្តក្នុងការបំពេញតួនាទី មានតម្លាភាព និងយុត្តិធម៌។

មន្ត្រីអប់រំគ្រប់កម្រិតថ្នាក់ បានបញ្ចេញទស្សនៈថាគួរអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធនៅប្រទេសកម្ពុជា។ មន្ត្រីអប់រំភាគច្រើនបំផុត ដែលបានផ្តល់ចម្លើយតាមរយៈកម្រងសំណួរ និងការសម្ភាសសុទ្ធតែបានសម្តែងនូវសុទិដ្ឋិនិយមក្នុងការអនុវត្តអធិការកិច្ចជាប្រព័ន្ធនៅកម្ពុជា លើកលែងតែប្រធាន ឬអនុប្រធានមន្ទីរពីរនាក់ប៉ុណ្ណោះ ដែលមិនទាន់មានភាពច្បាស់លាស់។ មន្ត្រីអប់រំដែលយល់ថាគួរអនុវត្តប្រព័ន្ធអធិការកិច្ចអប់រំជាប្រព័ន្ធនៅកម្ពុជា បានសម្តែងការយល់ឃើញរៀងៗខ្លួនដូចជា៖ ប្រធាន ឬអនុប្រធានមន្ទីរម្នាក់និយាយថា *"ត្រូវតែអនុវត្តនៅទូទាំងប្រទេស ពីព្រោះវាជួយលើកកម្ពស់គុណភាពអប់រំ"* ហើយអ្នកផ្សេងៗទៀតនិយាយថាអធិការកិច្ចជាប្រព័ន្ធងាយស្រួលអនុវត្ត ដោយប្រើប្រាស់ធនធានតិច អាចមើលបានគ្រប់ជ្រុងជ្រោយ និងឆាប់រកឃើញហេតុវិនិច្ឆ័យ។ ប្រធាន ឬអនុប្រធានការិយាល័យអធិការកិច្ចបាននិយាយថា អធិការកិច្ចថ្មីនេះប្រើអធិការតិចហើយពិនិត្យបានលើគ្រប់ផ្នែកទាំងអស់ និងទទួលបានព័ត៌មានពីគ្រប់ភាគីពាក់ព័ន្ធ។ អធិការមានស្រាប់ និងនិស្សិតអធិការបានយល់ឃើញថា អធិការកិច្ចអប់រំជាប្រព័ន្ធជាមធ្យោបាយ ដើម្បីលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែមានប្រសិទ្ធភាព ប្រើប្រាស់ធនធានមនុស្សតិច ហើយអាចពិនិត្យមើលសាលារៀនអនុវត្តផ្នែកទាំង៤ ហើយប្រព័ន្ធអធិការកិច្ចថ្មីនេះត្រូវបានអនុវត្ត ក្នុងបណ្តាប្រទេសជឿនលឿនដូចជាប្រទេសស៊ុយអែតជាដើម។ ពួកគាត់ក៏បានបន្ថែមទៀតថា ការអនុវត្តការងារអធិការកិច្ចអប់រំជា-ប្រព័ន្ធអាចទាក់ទាញសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗ ឱ្យចូលរួមក្នុងការធានាគុណភាពអប់រំ និងអាចពង្រឹងការអនុ

វត្តការងារគ្រប់ គ្រងរបស់នាយកសាលារៀន និងការបង្រៀននិងរៀនរបស់គ្រូបង្រៀនផងដែរ។ នាយក-នាយិកាសាលារៀនយល់ថា អធិការកិច្ចអប់រំជាប្រព័ន្ធ ពិនិត្យមើលការអនុវត្តរបស់សាលារៀនលើផ្នែកជាច្រើន ហើយសាលារៀនទទួលបាននូវព័ត៌មានត្រឡប់ ដើម្បីកែលម្អការអនុវត្តក្នុងសាលារៀនរបស់ពួកគាត់។ នាយកសាលារៀនម្នាក់បាននិយាយថា "*គួរអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ ពីព្រោះអាចជួយដល់គ្រូបង្រៀនបានច្រើន ដែលខុសពីអធិការកិច្ចមុន អធិការម្នាក់មើលបានតែមួយមុខវិជ្ជាមិនអាចមើលឯកទេសផ្សេងៗទៀតបាន*"។ ចំណែកប្រធាន ឬអនុប្រធានមន្ទីរពីរនាក់ ដែលពុំទាន់មានភាពច្បាស់ក្នុងការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធនៅកម្ពុជា គឺដោយសារពួកគាត់ពុំទាន់យល់ច្បាស់ ពីប្រព័ន្ធអធិការកិច្ចអប់រំថ្មីនេះ។ ប្រធាន ឬអនុប្រធានមន្ទីរម្នាក់បាននិយាយថា "*មិនទាន់ដឹងទេ ព្រោះទើបតែចាប់ផ្តើម តែត្រូវបន្តដើម្បីឱ្យឃើញលទ្ធផល*" និងម្នាក់ទៀតនិយាយថា "*អនុវត្តប្រព័ន្ធអធិការកិច្ចនៅកម្ពុជាបារម្ភខ្លាចតែច្រើនពេក។ មិនដឹងថាអធិការកិច្ចជាប្រព័ន្ធ យ៉ាងម៉េចទេ*" ។

ដើម្បីឱ្យការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធប្រព្រឹត្តទៅបានល្អ អ្នកពាក់ព័ន្ធបានបញ្ចេញទស្សនៈរបស់ខ្លួនដូចជា៖ ប្រធាន ឬអនុប្រធានមន្ទីរ ម្នាក់និយាយថា "*ត្រូវរៀបចំ ផែនការអធិការកិច្ចឱ្យបានច្បាស់លាស់ ហើយពេលចុះអនុវត្តជួបប្រទះបញ្ហាអ្វីត្រូវលើកយកមកពិភាក្សាដោះស្រាយតាមរយៈការប្រជុំបូកសរុបក្រោយពេលចុះ រួចផ្តល់ព័ត៌មានជូននាយកសាលារៀន និងធ្វើការប្រជុំនៅមន្ទីរដើម្បីលើកផែនការបន្ត*"។ អ្នកផ្សេងទៀតនិយាយថាត្រូវបន្ថែមថវិកា ធនធានមនុស្ស សូមជួយបណ្តុះបណ្តាលបន្ថែមលើជំនាញអធិការកិច្ច ត្រូវតំឡើងឋានៈអធិការ និងត្រូវគោរពតាមការរកឃើញ។ *ប្រធាន និងអនុប្រធានការិយាល័យអធិការកិច្ច* បាននិយាយថា៖ (១) ត្រូវផ្តល់សិទ្ធអំណាចកម្រិតណាមួយដល់អធិការ ដើម្បីឱ្យគេអនុវត្តតាម (២) ត្រូវមានចំនួនអធិការឱ្យសមស្របទៅតាមចំនួនសាលារៀន (៣) ត្រូវបំប៉នមន្ត្រីនៅការិយាល័យអធិការកិច្ច (៤) ត្រូវផ្សព្វផ្សាយពីការងារអធិការអប់រំថ្មី ឱ្យបានទូលំទូលាយ និង (៥) ត្រូវបង្កើនថវិកាសម្រាប់ការងារអធិការកិច្ច។ អធិការមានស្រាប់ និងនិស្សិតអធិការបាននិយាថា៖ (១) ត្រូវផ្តល់អំណាចដល់អធិការ (២) ត្រូវផ្តល់មធ្យោបាយធ្វើដំណើរសម្រាប់អធិការ (៣) ត្រូវមានរចនាសម្ព័ន្ធដឹកនាំដោយមានការបោះឆ្នោត (៤) ត្រូវអនុវត្តទៅតាមកាលវិភាគរយៈពេល២ថ្ងៃ ក្នុងការចុះអធិការកិច្ចសាលារៀនមួយ (៥) ត្រូវមានការគាំទ្រពេញលេញពីគ្រប់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៦) ត្រូវលើកទឹកចិត្តអធិការទាំងស្មារតី និងសម្ភារ (៧) ត្រូវបង្កើនឋានៈអធិការក្នុងក្របខ័ណ្ឌមួយខ្ពស់ជាងគ្រូបង្រៀន និងនាយកសាលារៀន (៨) ត្រូវបំប៉នន្ថែមដល់ក្រុមអធិការ និងDTMT (៩) ត្រូវមានផែនការថវិកាដើម្បីអនុវត្តការងារអធិការកិច្ច (១០) ត្រូវចេញគោលការណ៍ណែនាំនៃការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធឱ្យបានច្បាស់លាស់ (១១) ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធ (១២) ត្រូវបណ្តុះបណ្តាលអធិការឱ្យបានគ្រប់គ្រាន់ (១៣) ត្រូវមានសម្ភារគ្រប់គ្រាន់ សម្រាប់ការងារអធិការកិច្ច (១៤) ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់គ្រឹះស្ថានសិក្សា ដើម្បីយល់ជ្រួតជ្រាបពីប្រព័ន្ធអធិការកិច្ចជាប្រព័ន្ធ និង (១៥) មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ នាយក-នាយិកាសាលារៀន និងគ្រូបង្រៀនបាននិយាយថាត្រូវ៖ មានផែនការ មានវគ្គបំប៉ន (នាយក-នាយិកា នាយករង-នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន) មានការចូលរួមសហការជាមួយមន្ត្រីអធិការសាលារៀន មានការលើកទឹកចិត្តនិងជំរុញសកម្មភាព មានការចុះអធិការកិច្ចពីអធិការក្រសួង ឱ្យបានញឹកញាប់ និងការចូលរួមសហការគ្នារវាងសាលារៀន និងក្រុមអធិការ។

## ការធានាគុណភាពអប់រំ

អធិការកិច្ចអប់រំជាប្រព័ន្ធ អាចធានាគុណភាពអប់រំបានល្អកម្រិតខ្ពស់។ ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានមានប្រសាសន៍ថាអធិការកិច្ចអប់រំជាប្រព័ន្ធ អាចធានាគុណភាពអប់រំបានកម្រិតខ្ពស់ តាមរយៈការជំរុញ ការអនុវត្តតាមជំនាញនីមួយៗ ការពង្រឹងការបង្រៀន និងរៀន ការអនុវត្តការងារឱ្យបានហ្មត់ចត់ ការពិនិត្យមើលការ ប្រែប្រួលរបស់សាលារៀនបន្ទាប់ពីចុះអធិការកិច្ច ការផ្តល់ តម្លៃដល់ការងារអធិការកិច្ច និងមានការលើកទឹកចិត្តអធិការ ដែលមានស្នាដៃល្អ។ ប្រធាន ឬអនុប្រធានមន្ទីរម្នាក់ បានមានប្រសាសន៍ថា "*អធិការកិច្ចអប់រំជាប្រព័ន្ធអាចធានាគុណភាពអប់រំឱ្យប្រសើរឡើង ដោយយើងធ្វើការលើកទឹកចិត្តនាយកសាលារៀន លោកគ្រូ-អ្នកគ្រូឱ្យអនុវត្តទៅតាមគោលការណ៍ណែនាំ និងការអនុវត្តឱ្យបានត្រឹមត្រូវ*

*តាមសារាចរ និងសេចក្តីណែនាំរបស់ក្រសួង*"។ ចំណែកប្រធាន ឬអនុប្រធានការិយាល័យអធិការកិច្ច បានមានប្រសាសន៍ថា ដើម្បីឱ្យអធិការកិច្ចអប់រំជាប្រព័ន្ធអាចធានាគុណភាពអប់រំ បានល្អ លុះត្រាតែលទ្ធផលអធិការកិច្ចត្រូវបានថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់ និងផ្សព្វផ្សាយ ហើយអ្នកពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុសាសន៍របស់អធិការ។ តាមរយៈតារាងទី១ ក៏បានបង្ហាញថា៖ អធិការមានស្រាប់ និស្សិតអធិការ និងនាយកសាលារៀនបានវាយតម្លៃខ្ពស់ថា អធិការកិច្ចអប់រំជាប្រព័ន្ធអាចធានាគុណភាពអប់រំបានកម្រិតខ្ពស់ ដោយបានផ្តល់នូវមធ្យមពិន្ទុនៃការវាយតម្លៃចាប់ពី៣.៩ ទៅ៤.១។ ចំណែកឯគ្រូបង្រៀនពុំយល់ស្របថា អធិការកិច្ចអប់រំជាប្រព័ន្ធ អាចធានាគុណភាពអប់រំបានកម្រិតខ្ពស់នោះទេ ពួកគាត់បានផ្តល់នូវមធ្យមពិន្ទុនៃការវាយតម្លៃត្រឹមតែកម្រិតមធ្យមគឺ២.២ ប៉ុណ្ណោះ។ អធិការ មានស្រាប់ និស្សិតអធិការ និងនាយកសាលារៀនបានបញ្ចេញនូវយោបល់រួមគ្នាអំពីហេតុផលដែលយល់ថា

តារាងទី១៖ ទស្សនៈមន្ត្រីអប់រំ លើការធានាកម្រិតគុណភាពអប់រំ តាមរយៈអធិការកិច្ចអប់រំជាប្រព័ន្ធ

| មន្ត្រី | អធិការ មានស្រាប់ | និស្សិតអធិការ | នាយកសាលា | គ្រូបង្រៀន |
|---|---|---|---|---|
| *ទស្សនៈលើការធានាគុណភាពអប់រំ* | ៣.៩ | ៣.៩ | ៤.១ | ២.២ |
| | អធិការកិច្ចអប់រំជាប្រព័ន្ធធានាគុណភាពអប់រំកម្រិតខ្ពស់ដោយមានមធ្យមភាគនៃការវាយតម្លៃពី ៣.៩ ទៅ ៤.១(លើកលែងតែគ្រូបង្រៀន គឺ ២.២) | | | |

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥:ខ្ពស់ណាស់ ៤.៤-៣.៥:ខ្ពស់ ៣.៤-២.៥ មធ្យម ២.៤-១.៥ ទាប ១.៤-១ ទាបណាស់*

អធិការកិច្ចអប់រំជាប្រព័ន្ធអាចធានាគុណភាពអប់រំល្អកម្រិតខ្ពស់ ដោយសារអធិការកិច្ចអប់រំជាប្រព័ន្ធ ពិនិត្យមើលលើគ្រប់ផ្នែកដែលពាក់ព័ន្ធនឹងការធានាគុណភាពអប់រំ។ អធិការ ម្នាក់បាននិយាយថា "*អធិការកិច្ចអប់រំជាប្រព័ន្ធវាយតម្លៃលើ ការគ្រប់គ្រងនិងដឹកនាំ ការបង្រៀននិងរៀន លទ្ធផលសិក្សារបស់សិស្ស និងស្វ័យវាយតម្លៃសាលារៀន*"។ និស្សិតអធិការម្នាក់និយាយថា "*....អាចជួយជំរុញការដឹកនាំគ្រប់គ្រងរបស់អង្គភាពឱ្យមានតម្លាភាព គណនេយ្យភាព ហើយបានធ្វើឱ្យគ្រូផ្លាស់ប្តូរឥរិយាបថបង្រៀន ជួយពង្រឹងសមត្ថភាពគ្រូ និងអាចជួយបំពេញបន្ថែមនូវភាពខ្វះខាតខ្វះចន្លោះលើការ-អនុវត្តដែលសាលារៀនអនុវត្តមិនទាន់បានល្អ*"។ ចំណែកអ្នកពាក់ព័ន្ធពុំគិតថាអធិការកិច្ចបែបថ្មីនេះ អាចធានាគុណភាពអប់រំល្អបានទេ ព្រោះប្រព័ន្ធបែបថ្មីនេះបង្ហាញតែបញ្ហាដែលបានរកឃើញតែប៉ុណ្ណោះ មិនបានជួយអ្វីដល់សាលា ឬលោកគ្រូ-អ្នកគ្រូត្រូវការឱ្យជួយនោះទេ ហើយអធិការកិច្ចបែបថ្មីនេះ ពុំអាចជួយគ្រូបានច្រើនឡើយ ព្រោះអធិការពុំមានចំណេះដឹងគ្រប់មុខវិជ្ជាឯកទេសឡើយ។

## ចំណង់អនុវត្ត

ជាសញ្ញាណល្អមួយ សម្រាប់ការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធនៅប្រទេសកម្ពុជា ពីព្រោះអ្នកពាក់ព័ន្ធទាំងអស់សុទ្ធតែបានបង្ហាញនូវសុឆន្ទៈខ្លាំងក្នុងការអនុវត្ត ហើយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក៏ដូចជាប្រធានការិយាល័យអធិការកិច្ច បានបង្ហាញនូវសុឆន្ទៈក្នុងការជំរុញ ឱ្យមានការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ។ តារាងទី២ ចង្អុលបង្ហាញថា អធិការ និស្សិតអធិការ និងនាយកសាលារៀន និងគ្រូបង្រៀនមានបំណងក្នុងការអនុវត្តខ្លាំងដោយបានវាយតម្លៃនូវកម្រិតមធ្យមពិន្ទុ ៤.០ទៅ ៤.២។ ពួកគាត់មានចំណង់អនុវត្តខ្លាំង ពីព្រោះពួកគាត់យល់ឃើញថាអធិការកិច្ចអប់រំជាប្រព័ន្ធ អាចធានាគុណភាពអប់រំបានល្អ ដើម្បីអាចប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។ អធិការម្នាក់បាននិយាយថា "*អាចរកឃើញចំណុចកែលម្អបានសព្វគ្រប់ និងគ្រប់ជ្រុងជ្រោយ មានលក្ខណៈជាប្រព័ន្ធ អាចកែប្រែគោលនយោបាយ ឬយុទ្ធសាស្ត្រសម្រាប់កែលម្អគុណភាពអប់រំ*" ហើយអធិការម្នាក់ទៀតនិយាយថា "*...ព្រោះមានសូចនាករជាក់លាក់ និងគោលការណ៍ត្រឹមត្រូវ*"។ នាយកសាលារៀនម្នាក់និយាយថា "*. . . ដើម្បីពង្រឹងគុណភាពគ្រូបង្រៀន សំខាន់គឺ មើលបានគ្រប់ឯកទេស និងការងាររដ្ឋបាលផងដែរ*"។ គ្រូបង្រៀនភាគច្រើនបាននិយាយថា ការចុះអធិការច្រើនដង អាចធ្វើឱ្យក្រុមអធិការដឹង ពីកម្រិតចំណេះដឹងរបស់សិស្ស និងជួយកែលម្អការបង្រៀនបានល្អ។ គ្រូ-បង្រៀនម្នាក់បាននិយាយថា "*បើអធិការចុះមកមើលកាន់ តែច្រើន នោះការត្រៀមឯកសារបង្រៀនបានកាន់តែច្រើន ជាពិសេសការធ្វើកិច្ចតែងការបង្រៀន*"។ ទន្ទឹមនឹងអ្នកពាក់ព័ន្ធភាគច្រើនមានចំណង់អនុវត្តខ្លាំង ក៏មានអធិការមួយចំនួនមានចំណង់អនុវត្តធម្ម

តា ដោយអធិការម្នាក់បាននិយាយថា "...*ពីព្រោះការធ្វើអធិការកិច្ចដល់សាលារៀន មានបំណងតែមួយ គឺជួយគ្រូក្នុងការផ្តល់ចំណេះដឹងដល់សិស្សប្រកបដោយគុណភាព*" និង "...*ពីព្រោះដំណើរការអធិការកិច្ចពុំមានប្រសិទ្ធភាព ពុំអាចធានាគុណភាពអប់រំ*"។ គ្រូបង្រៀនម្នាក់បាននិយាយថា "*អធិការកិច្ចច្រើនដងពេកធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តកម្មវិធីសិក្សា*"។ គ្រូបង្រៀនភាគច្រើនពុំបានយល់ពីប្រព័ន្ធអធិការកិច្ចអប់រំថ្មីទេ ការបញ្ចេញយោបល់របស់ពួកគាត់អាចផ្តោតទៅលើអធិការកិច្ចទូទៅ ដែលបានអនុវត្តកន្លងមក។

តារាងទី២៖ ទស្សនៈមន្ត្រីអប់រំលើកម្រិតចំណង់អនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ

| មន្ត្រី | អធិការមានស្រាប់ | និស្សិតអធិការ | នាយកសាលា | គ្រូបង្រៀន |
|---|---|---|---|---|
| *ទស្សនៈលើចំណង់អនុវត្ត* | ៤.០ | ៤.២ | ៤.០ | ៤.០ |
| | មន្ត្រីអប់រំទាំងអស់មានចំណង់អនុវត្តដោយមានមធ្យមពិន្ទុចាប់ពី៤.០ ឡើងទៅ | | | |

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥:ខ្លាំងណាស់ ៤.៤-៣.៥:ខ្លាំង ៣.៤-២.៥ ធម្មតា ២.៤-១.៥ តិចតួច ១.៤-១ គ្មានសោះ*

## ៣.២ ការបំប៉ន និងការបណ្តុះបណ្តាល

អធិការអប់រំមានស្រាប់ទាំងអស់ បានចូលរួមក្នុងវគ្គបំប៉នចំនួន៦ម៉ូឌុល នាយក-នាយិកាវិទ្យាល័យបានចូលរួមវគ្គបំប៉នចំនួន៤ម៉ូឌុល ស្តីពីអធិការកិច្ចអប់រំជាប្រព័ន្ធដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ។ និស្សិតអធិការបានទទួលការបណ្តុះបណ្តាលអំពីការងារអធិការកិច្ចចំនួន១៤មុខវិជ្ជា។ សិក្ខាកាមទាំងបីមុខសញ្ញា បានវាយតម្លៃអំពីវគ្គបណ្តុះ បណ្តាលដូចខាងក្រោម៖

### ខ្លឹមសារបំប៉ន និងបណ្តុះបណ្តាល

គ្រូឧទ្ទេសអធិការ បានកំណត់វត្ថុបំណងមេរៀនបាន ច្បាស់ និងមានការរៀបចំមេរៀនធ្វើឱ្យសិក្ខាកាមងាយយល់។ តារាងទី៣ ចង្អុលបង្ហាញថាការកំណត់វត្ថុបំណងមេរៀនសម្រាប់បំប៉ននាយក-នាយិកាវិទ្យាល័យមានភាពច្បាស់- លាស់ (៣.៦) ជាងការកំណត់វត្ថុបំណងមេរៀនសម្រាប់បំប៉នអធិការមានស្រាប់ (៣.៣) និងសម្រាប់បណ្តុះបណ្តាលនិស្សិតអធិការ (២.៨)។ ការរៀបចំមេរៀនសម្រាប់នាយក-នាយិកាសាលារៀន និងអធិការមានស្រាប់បានល្អដែលធ្វើឱ្យសិក្ខាកាមងាយយល់។ ការរៀបចំមេរៀនសម្រាប់និស្សិតអធិការក៏បានល្អដែរ ដោយនិស្សិតអធិការបានវាយតម្លៃជាមធ្យមពិន្ទុគឺ ៣.៤។ តារាង ទី៣ បង្ហាញផងដែរពីការវាយតម្លៃរបស់សិក្ខាកាមថា មានភាពទាក់ទងគ្នារវាងការកំណត់វត្ថុបំណងមេរៀន និងការរៀបចំមេរៀន។ នៅពេលដែលគ្រូឧទ្ទេសកំណត់វត្ថុបំណងមេរៀនបានច្បាស់លាស់ នោះការ- រៀបចំមេរៀនក៏ធ្វើឱ្យសិក្ខាកាមងាយយល់ដែរ។

តារាងទី៣៖ការកំណត់វត្ថុបំណងនិងការរៀបចំមេរៀន

| មន្ត្រី / ការវាយតម្លៃ | *អធិការមានស្រាប់* | *និស្សិតអធិការ* | *នាយកសាលា* |
|---|---|---|---|
| ភាពច្បាស់នៃវត្ថុបំណង | ៣.៣ | ២.៨ | ៣.៦ |
| កម្រិតរៀបចំមេរៀន | ៣.៨ | ៣.៤ | ៤.១ |

*សម្គាល់៖ កម្រិតវាយតម្លៃវត្ថុបំណង ៥-៤.៥:ច្បាស់ខ្លាំងណាស់ ៤.៤-៣.៥:ច្បាស់ខ្លាំង ៣.៤-២.៥ :ច្បាស់ ២.៤-១.៥: មិនសូវច្បាស់ ១.៤-១ :មិនច្បាស់*

*កម្រិតវាយតម្លៃការរៀបចំមេរៀន ៥-៤.៥:ងាយយល់ណាស់ ៤.៤-៣.៥:ងាយយល់ ៣.៤-២.៥ យល់ ២.៤-១.៥ ពិបាកយល់ ១.៤-១ ពិបាកយល់ណាស់*

សិក្ខាកាម នៅក្នុងវគ្គបំប៉ននាយកសាលារៀន និងអធិការមានស្រាប់ បានធ្វើស្វ័យវាយតម្លៃខ្លួនឯងថាពួកគាត់បានយល់ពីខ្លឹមសារមេរៀន នៅគ្រប់ម៉ូឌុលទាំងអស់នៅក្នុងវគ្គបំប៉ន។ តាមតារាងទី៤ បង្ហាញថាអធិការយល់ច្បាស់ណាស់ អំពីខ្លឹមសារដែលបានបណ្តុះបណ្តាលនៅក្នុងម៉ូឌុលទី២ និងទី៤ ដោយបានផ្តល់មធ្យមពិន្ទុនៃការវាយតម្លៃពី ៣.៥ ទៅ៣.៧។ អធិការមានស្រាប់ពុំទាន់យល់បានច្បាស់អំពីខ្លឹមសារបណ្តុះបណ្តាលក្នុងម៉ូឌុលទី៣ ដែលនិយាយពីការវិភាគ និងសរសេររបាយការណ៍អធិការកិច្ច សាលារៀនដោយពួកគាត់វាយតម្លៃត្រឹមមធ្យមពិន្ទុ ៣.០ ប៉ុណ្ណោះ។ តារាងទី៤ ក៏បានបង្ហាញផងដែរថានាយក-នាយិកាសាលា-រៀន យល់នៅកម្រិតប្រហាក់ប្រហែលគ្នានៅគ្រប់ម៉ូឌុលទាំងអស់ដោយមានមធ្យមពិន្ទុវាយតម្លៃពី ៣.១ ដល់៣.៤។

និស្សិតអធិការ បានយល់នូវខ្លឹមសារមេរៀនស្ទើរគ្រប់មុខវិជ្ជាទាំងអស់នៅក្នុងកម្មវិធីបណ្តុះបណ្តាល។ តាមរូបភាពទី១ បង្ហាញថា មុខវិជ្ជាដែលនិស្សិតអធិការយល់បាន ច្រើនជាងគេគឺ មុខវិជ្ជាទី៧ស្តីពីប្រព័ន្ធអធិការកិច្ចអប់រំថ្មី និងមុខវិជ្ជាទី១០ស្តីពីវិធីសាស្ត្របង្រៀននិងរៀន ដោយទទួលបានមធ្យមពិន្ទុនៃការវាយតម្លៃគឺ ៣.៤។ មុខវិជ្ជាដទៃទៀតដែលនិស្សិតអធិការ បានធ្វើស្វ័យវាយតម្លៃចាប់ពីមធ្យមពិន្ទុ៣.០ ដល់៣.៣ រួមមានមុខវិជ្ជាទី២, ៣, ៤, ៥, ៩ និងទី១១។ មុខវិជ្ជាដែលគរុនិស្សិតយល់ដែរ តែមានមធ្យមពិន្ទុត្រឹម២.៨ ដល់២.៩ មានមុខវិជ្ជាទី១, ៦ និងទី១២។ មុខវិជ្ជាដែលនិស្សិតមិនសូវយល់មានមួយមុខវិជ្ជា គឺមុខវិជ្ជា ទី១៤ ស្តីពីការគ្រប់គ្រងផ្អែកតាមសាលារៀន ដោយបានមធ្យមពិន្ទុស្វ័យវាយតម្លៃត្រឹមតែ២.៤ ប៉ុណ្ណោះ។

តារាងទី៤៖ ការវាយតម្លៃពីភាពយល់ដឹងនៃម៉ូឌុលនីមួយៗទៅនឹងការអនុវត្ត

| មន្ត្រី / ខ្លឹមសារ | អធិការមានស្រាប់ | នាយកសាលា |
|---|---|---|
| ម៉ូឌុលទី១ | ៣.៣ | ៣.៣ |
| ម៉ូឌុលទី២ | ៣.៧ | ៣.១ |
| ម៉ូឌុលទី៣ | ៣.៣ | ៣.៤ |
| ម៉ូឌុលទី៤ | ៣.៥ | ៣.៣ |
| ម៉ូឌុលទី៥ | ៣.០ | X |
| ម៉ូឌុលទី៦ | ៣.១ | X |

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥: យល់ច្បាស់ណាស់ ៤.៤-៣.៥: យល់ច្បាស់ ៣.៤-២.៥: យល់ ២.៤-១.៥: មិនសូវយល់ ១.៤-១: មិនយល់*

ខ្លឹមសារវគ្គបណ្តុះបណ្តាលនៅគ្រប់ម៉ូឌុលទាំងអស់មានភាពពាក់ព័ន្ធខ្លាំងទៅនឹង ការអនុវត្តជំនាញវិជ្ជាជីវៈប្រចាំថ្ងៃរបស់នាយកសាលារៀន និងអធិការមានស្រាប់។ តាម រយៈតារាងទី៥ អធិការមានស្រាប់បានបង្ហាញថាខ្លឹមសារដែលគាត់បានទទួលពីវគ្គបណ្តុះបណ្តាល មានភាពទាក់- ទងខ្លាំងទៅនឹងការងារប្រចាំថ្ងៃរបស់គាត់ ដោយបានផ្តល់នូវមធ្យមពិន្ទុចាប់ពី៣.៥ ដល់៣.៨ ហើយនាយកសាលារៀនបាន ផ្តល់មធ្យមពិន្ទុចាប់ពី៣.៥ ដល់៣.៧ លើកលែងតែម៉ូឌុលទី៤ ដែលមានមធ្យមពិន្ទុ ៣.៤។




រូបភាពទី១៖ មធ្យមពិន្ទុស្វ័យវាយតម្លៃអំពីការយល់ដឹងរបស់និស្សិតអធិការតាមមុខវិជ្ជា

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥:យល់ច្បាស់ណាស់ ៤.៤-៣.៥:យល់ច្បាស់ ៣.៤-២.៥: យល់ ២.៤-១.៥: មិនសូវយល់ ១.៤-១:មិនយល់*

តារាងទី៥៖ ការវាយតម្លៃពីភាពទាក់ទងនៃម៉ូឌុលនីមួយៗទៅនឹងការអនុវត្ត

| មន្ត្រី / ខ្លឹមសារ | អធិការមានស្រាប់ | នាយកសាលា |
|---|---|---|
| ម៉ូឌុលទី១ | ៣.៥ | ៣.៥ |
| ម៉ូឌុលទី២ | ៣.៨ | ៣.៧ |
| ម៉ូឌុលទី៣ | ៣.៧ | ៣.៥ |
| ម៉ូឌុលទី៤ | ៣.៧ | ៣.៤ |
| ម៉ូឌុលទី៥ | ៣.៨ | X |
| ម៉ូឌុលទី៦ | ៣.៨ | X |

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥:ទាក់ទងខ្លាំងណាស់ ៤.៤-៣.៥: ទាក់ទងខ្លាំង ៣.៤-២.៥: ទាក់ទង ២.៤-១.៥: មិនសូវទាក់ទង ១.៤-១: មិនទាក់ទងសោះ*

ខ្លឹមសារវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ អាចឱ្យសិក្ខាកាមអនុវត្តការងារអធិការកិច្ចជាប្រព័ន្ធបានល្អខ្លាំង។តាមតារាងទី៦ បង្ហាញថានាយក

សាលាមានទំនុកចិត្តច្រើនជាង អធិការមានស្រាប់ និងនិស្សិតអធិការ ក្នុងការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ ដោយបានផ្តល់មធ្យមពិន្ទុវាយតម្លៃ ៤.១ ចំណែកឯអធិការមានស្រាប់ និងនិស្សិតអធិការបានផ្តល់មធ្យមពិន្ទុត្រឹមតែ ៤.០ ប៉ុណ្ណោះ។

ដើម្បីឱ្យការអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ មានប្រសិទ្ធ ភាពខ្ពស់ក្នុងការធានាគុណភាពអប់រំ សិក្ខាកាមដែលធ្លាប់បានទទួលវគ្គបំប៉ន ឬបណ្តុះបណ្តាលពីការងារអធិការកិច្ច បានធ្វើសំណូមពរបន្ថែមទៀតដូចតទៅ។ អធិការបានធ្វើសំណូមពរ ឱ្យមានការបណ្តុះបណ្តាលបន្ថែមលើ (១) ស្វ័យវាយតម្លៃសាលារៀន (២) ការវិភាគ និងសរសេររបាយការណ៍ (៣) ការប្រើប្រាស់ទិន្នន័យស្ថិតិប័ណ្ណព័ត៌មានសាលារៀន និង (៤) ការកសាងផែនការអប់រំ។ និស្សិតអធិការ បានធ្វើសំណូមពរ ឱ្យមានការបណ្តុះបណ្តាល បន្ថែមលើ(១) ការសរសេររបាយការណ៍អធិការកិច្ច (២) ផ្នែក ICT (៣) ភាសាអង់គ្លេស (៤) ស្វ័យវាយតម្លៃសាលា- រៀន និង(៥) ការរៀបចំផែនការអធិការកិច្ច។ ចំណែកនាយកសាលារៀនបានសំណូមពរ ឱ្យមានការបណ្តុះ- បណ្តាលបន្ថែមលើ (១) ផ្នែកឧបករណ៍វាយតម្លៃគ្រូ- បង្រៀន (២) វិធីសាស្ត្រក្នុងការបង្កើតកម្រងសំណួរអធិការកិច្ច (៣) ផ្នែកបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន(ICT) និង (៤) ផែនការអភិវឌ្ឍសាលារៀន។

តារាងទី៦៖ មធ្យមពិន្ទុវាយតម្លៃខ្លឹមសារបណ្តុះបណ្តាលដែលជួយឱ្យ សិក្ខាកាមអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធ

| មន្ត្រី | *អធិការមានស្រាប់* | *និស្សិតអធិការ* | *នាយកសាលា* |
|---|---|---|---|
| ទស្សនៈរបស់មន្ត្រីអប់រំ | ៤.០ | ៤.០ | ៤.១ |
| | មន្ត្រីអប់រំដែលបានទទួលការបណ្តុះបណ្តាលមានទំនុកចិត្តច្រើនក្នុងការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធ (៤.០-៤.១) | | |

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥:ច្រើនណាស់ ៤.៤-៣.៥:ច្រើន ៣.៤-២.៥: មធ្យម ២.៤-១.៥: តិចតួច ១.៤-១: គ្មានសោះ*

## សមត្ថភាពគ្រូឧទ្ទេស

គ្រូឧទ្ទេសអធិការ ដែលបានបំប៉នអធិការមានស្រាប់ នាយកសាលារៀន និងបណ្តុះបណ្តាលអធិការថ្មី៖ (១) មានចំណេះដឹងច្បាស់លាស់ពីមេរៀន (២) រៀបចំមេរៀនបានល្អ (៣) មានវិធីសាស្ត្របង្រៀនល្អ (៤) បានជំរុញ និងលើកទឹកចិត្តឱ្យសិក្ខាកាមចូលរួមពិភាក្សាយ៉ាងសកម្ម (៥) បានរៀបចំសកម្មភាពការងារជាក្រុម ជួយឱ្យសិក្ខាកាមទទួលបានបទពិសោធ និងចំណេះដឹងបន្ថែមទៀត និង (៦) បានប្រើប្រាស់ពេលវេលាលើការបង្រៀនសមរម្យ និងគ្រប់គ្រាន់។ នាយកសាលារៀន មានការឯកភាពខ្លាំងលើគ្រប់ចំណុចវាយតម្លៃទាំង៦ ដោយផ្តល់មធ្យមពិន្ទុវាយតម្លៃចាប់ពី ៣.៩ ដល់៤.១ និងនិស្សិតអធិការ អធិការមានស្រាប់ វាយតម្លៃចាប់ពីឯកភាពទៅឯកភាពខ្លាំងលើចំណុចវាយតម្លៃទាំង៦ខាងលើដោយផ្តល់មធ្យមពិន្ទុវាយតម្លៃពី ៣.០ ដល់៣.៦ (តារាងទី៧)។

ទោះជាសិក្ខាកាមបានវាយតម្លៃល្អពីសមត្ថភាព និងការរៀបចំរបស់គ្រូឧទ្ទេសយ៉ាងណាក៏ដោយ ពួកគាត់នៅតែមានយោបល់កែលម្អមួយចំនួនដើម្បី ធ្វើឱ្យការបណ្តុះបណ្តាលជំនាញអធិការកិច្ចអប់រំប្រព្រឹត្តទៅបានល្អ។ អធិ- ការមានស្រាប់បានផ្តល់យោបល់ថា គ្រូឧទ្ទេសគួរ៖ (១) លើកឧទាហរណ៍ឱ្យបានច្រើនដែលទាក់ទងទៅនឹងការអនុ- វត្ត ហើយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងបរិបទអប់រំនៅកម្ពុជា (២) សម្របសម្រួលយកភាពត្រឹមត្រូវជាក់លាក់ លើខ្លឹមសារមេរៀន ដោយកុំផ្អែកលើយោបល់សិក្ខាកាមទាំងស្រុង (៣) ពិភាក្សាគ្នាឱ្យបានច្បាស់លាស់មុនពេលបង្រៀន ពីព្រោះខ្លឹមសារថ្មី សិស្សថ្មី (៤) បង្រៀនពីការអនុវត្តឱ្យបានច្រើនជាងទ្រឹស្តី (៥) ចែកឯកសារដែលបកប្រែទាំងភាសាអង់គ្លេស និងភាសាខ្មែរ និង (៦) មានចម្លើយរំពឹងទុកនូវរាល់សំណួរទាំងអស់។ ចំណែកឯនិស្សិតអធិការវិញបានលើកនូវចំណុចមួយចំនួន សម្រាប់ឱ្យគ្រូឧទ្ទេសយកទៅកែលម្អដូចជា៖ (១) គួរបង្ហាញឧទាហរណ៍ជាក់ស្តែងផ្សារភ្ជាប់ទៅនឹងសកម្មភាពនៅក្នុងសាលារៀន (២) ត្រូវមានជំនាញលើមុខវិជ្ជាបង្រៀនរបស់ខ្លួនច្បាស់លាស់ (៣) គួរមានឯកសារសិស្សជាភាសាខ្មែរ និងកំណត់ខ្លឹមសារមេរៀនឱ្យបានច្បាស់លាស់ (៤) គួរសង្ខេបមេរៀនឱ្យបានច្បាស់ និងងាយយល់ និង (៥) គួរកំណត់វត្ថុបំណងមេរៀន និងរៀបចំមេរៀនឱ្យបានច្បាស់លាស់។ សម្រាប់សិក្ខាកាមជានាយកសាលារៀន វិញបានផ្តល់យោបល់កែលម្អសម្រាប់គ្រូឧទ្ទេស ដូចជា៖ (១) គួរបង្ហាញពីសកម្មភាពពិតៗដូចដែលអធិការចុះទៅធ្វើអធិការកិច្ចសាលារៀន និង (២) គ្រូឧទ្ទេសគួរនៅជាមួយសិក្ខាកាមពេលពិភាក្សាក្រុម។

តារាងទី៧៖ ការវាយតម្លៃសមត្ថភាពគ្រូឧទ្ទេស និងការរៀបចំមេរៀន

| មន្ត្រី / ចំណុចវាយតម្លៃ | *អធិការមានស្រាប់* | *និស្សិតអធិការ* | *នាយកសាលា* |
|---|---|---|---|
| គ្រូឧទ្ទេសមានចំណេះដឹងច្បាស់លាស់ពីមេរៀន | ៣.៣ | ៣.២ | ៣.៩ |
| គ្រូឧទ្ទេសរៀបចំមេរៀនបានល្អ | ៣.៤ | ៣.១ | ៤.១ |
| គ្រូឧទ្ទេសមានវិធីសាស្ត្របង្រៀនល្អ | ៣.៣ | ៣.០ | ៣.៩ |
| គ្រូឧទ្ទេសជំរុញ និងលើកទឹកចិត្តឱ្យសិក្ខាកាមចូលរួមពិភាក្សាយ៉ាងសកម្ម | ៣.៥ | ៣.៦ | ៤.១ |
| សកម្មភាពការងារជាក្រុមពិតជាជួយឱ្យសិក្ខាកាមទទួលបានបទពិសោធ និងចំណេះដឹងបន្ថែមទៀត | ៣.៦ | ៣.៦ | ៤.០ |
| ពេលវេលាប្រើប្រាស់ក្នុងការបង្រៀនគឺមានភាពសមរម្យ និងគ្រប់គ្រាន់ | ៣.២ | ៣.២ | ៣.៩ |

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥:ឯកភាពទាំងស្រុង ៤.៤-៣.៥: ឯកភាពខ្លាំង ៣.៤-២.៥: ឯកភាព ២.៤-១.៥: ឯកភាពតិចតួច ១.៤-១: មិនឯកភាព*

### សម្ភារ និងឯកសារបំប៉ន និងបណ្តុះបណ្តាល

គ្រូឧទ្ទេសអធិការបានផ្តល់ និងប្រើប្រាស់ឯកសារគ្រប់ គ្រាន់នៅក្នុងវគ្គបណ្តុះបណ្តាល។ នាយកសាលារៀនបានបង្ហាញថា គ្រូឧទ្ទេសផ្តល់ឯកសារគ្រប់គ្រាន់ ដោយផ្តល់មធ្យមពិន្ទុវាយតម្លៃ ៣.៤ និងប្រើប្រាស់ឯកសារទាំងនោះបានច្រើនក្នុងពេលបង្រៀន ហើយផ្តល់មធ្យមពិន្ទុនៃការវាយតម្លៃ ៣.៥។ ចំណែកឯអធិការមានស្រាប់ និងនិស្សិតអធិការវិញ បានវាយតម្លៃថាគ្រូឧទ្ទេសផ្តល់ឯកសារ និងប្រើប្រាស់ឯកសារគ្រប់គ្រាន់ក្នុងពេលបង្រៀន ដោយផ្តល់នូវមធ្យមពិន្ទុវាយតម្លៃពី ២.៧ ទៅ៣.៤ (តារាងទី៨)។

តារាងទី៨៖ ការផ្តល់ឯកសារ និងការប្រើប្រាស់ឯកសាររបស់ គ្រូឧទ្ទេសនៅក្នុងវគ្គបណ្តុះបណ្តាល

| មន្ត្រី / ចំណុចវាយតម្លៃ | *អធិការមានស្រាប់* | *និស្សិតអធិការ* | *នាយកសាលា* |
|---|---|---|---|
| ការផ្តល់ឯកសារ | ៣.២ | ៣.៤ | ៣.៤ |
| ការប្រើប្រាស់ឯកសារ | ៣.១ | ២.៧ | ៣.៥ |

*សម្គាល់៖កម្រិតវាយតម្លៃ ៥-៤.៥:ច្រើនណាស់ ៤.៤-៣.៥:ច្រើន ៣.៤-២.៥:គ្រប់គ្រាន់ ២.៤-១.៥: មិនគ្រប់គ្រាន់ ១.៤-១: គ្មានសោះ*

## ៤. សេចក្តីសន្និដ្ឋាន

### ទស្សនៈមន្ត្រីអប់រំលើអធិការកិច្ចអប់រំជាប្រព័ន្ធ

មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធនឹងការងារអធិការកិច្ចបានសម្តែងទស្សនៈថា ត្រូវអនុវត្តអធិការកិច្ចអប់រំជាប្រព័ន្ធនៅប្រទេសកម្ពុជា។ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មានការប្តេជ្ញាចិត្តក្នុងការជួយជំរុញ និងគាំទ្រការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធ នៅកម្ពុជា ហើយជាពេលវេលាមួយដែលត្រូវអនុវត្តប្រព័ន្ធអធិការកិច្ចថ្មីនេះ។ មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់បានយល់ឃើញថាអធិការកិច្ចអប់រំជាប្រព័ន្ធ អាចធានាគុណភាពអប់រំបានកម្រិតខ្ពស់ ពីព្រោះបានវាយតម្លៃទៅលើគ្រប់ផ្នែកទាំងអស់ដែលទាក់ទងទៅនឹងការធានាគុណភាពអប់រំ នៅតាមសាលារៀន ដោយពិនិត្យមើលលើការងារគ្រប់គ្រង ការបង្រៀននិងរៀន លទ្ធផលសិក្សារបស់សិស្ស និងស្វ័យវាយតម្លៃសាលារៀន។ ពួកគាត់មានចំណង់អនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធជាខ្លាំង។

ទន្ទឹមនឹងនេះពួកគាត់ក៏បានបញ្ចេញទស្សនៈថា ការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធ ជួបនូវបញ្ហាមួយចំនួនដូចជា៖ ពុំមានអធិការគ្រប់គ្រាន់ ខ្វះធនធានសម្ភារ

ខ្វះមធ្យោបាយធ្វើដំណើរ ខ្វះថវិកា និងខ្វះការចូលរួមពីអ្នកពាក់ព័ន្ធនានា។

**ទស្សនៈមន្ត្រីអប់រំលើការបំប៉ន និងបណ្តុះបណ្តាល**

វគ្គបំប៉ន និងបណ្តុះបណ្តាលពីការងារអធិការកិច្ចដែលរៀបចំ ដោយវិទ្យាស្ថានជាតិអប់រំ ពិតជាទទួលបានការគាំទ្រពីសិក្ខាកាមទាំងអស់ ហើយអាចជួយឱ្យពួកគាត់អនុវត្តការងារអធិការកិច្ចជាប្រព័ន្ធនេះបាន ដើម្បីធានាគុណភាពអប់រំឱ្យល្អប្រសើរ។ មន្ត្រីអប់រំដែលជាសិក្ខាកាមគ្រប់កម្រិតថ្នាក់ បានវាយតម្លៃថា គ្រូឧទ្ទេសអធិការមានចំណេះដឹងច្បាស់លាស់ពីមេរៀន មានវិធីសាស្ត្របង្រៀនល្អ បានជំរុញ និងលើកទឹកចិត្តឱ្យសិក្ខាកាមចូលរួមយ៉ាងសកម្ម ។ល។ រាល់មេរៀនទាំងអស់ បានកំណត់វត្ថុបំណងច្បាស់លាស់ ហើយគ្រូឧទ្ទេសប្រើប្រាស់សម្ភារ និងឯកសារគ្រប់គ្រាន់ ដើម្បីឱ្យសិក្ខាកាមសម្រេចនូវវត្ថុបំណងដែលបានកំណត់។ សិក្ខាកាមបានធ្វើស្វ័យវាយតម្លៃថា ពួកគាត់យល់ច្បាស់លើគ្រប់មេរៀន ហើយមេរៀនទាំងអស់សុទ្ធតែពាក់ព័ន្ធខ្លាំង ទៅនឹងការអនុវត្តការងារជំនាញវិជ្ជាជីវៈរបស់គាត់។

វគ្គបំប៉ន និងបណ្តុះបណ្តាលនៅមានចំណុចខ្វះខាតមួយចំនួនដូចជា៖ គ្រូឧទ្ទេសពុំបានលើកឧទាហរណ៍ឱ្យបានច្រើន ដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង ពុំទាន់ផ្តល់ការកែលម្អចម្លើយរបស់សិក្ខាកាមបានត្រឹមត្រូវច្បាស់លាស់ និងឯកសារមួយចំនួនសម្រាប់បណ្តុះបណ្តាលអធិការថ្មីជាភាសាអង់គ្លេសជាដើម។ ចំណែកមេរៀនសំខាន់ៗមួយចំនួនសិក្ខាកាម ពុំទាន់យកទៅអនុវត្តបានល្អដូចជាមេរៀនស្តីពីការវិភាគនិងសសេររបាយការណ៍អធិការកិច្ចជាដើម។

## ៥. សំណូមពរ

ដើម្បីឱ្យ ការអនុវត្តការងារអធិការកិច្ចអប់រំជាប្រព័ន្ធប្រព្រឹត្តទៅបានល្អ ដើម្បីធានាគុណភាពអប់រំឱ្យបានប្រសើរ ក្រុមស្រាវជ្រាវ មានសំណូមពរមួយចំនួនសម្រាប់អ្នកពាក់ព័ន្ធដូចខាងក្រោម៖

*ក្រសួងអប់រំ យុវជន និងកីឡា* គួរលើកទឹកចិត្តអធិការតាមរយៈការផ្តល់នូវឋានៈ ឬក្របខ័ណ្ឌដែលខ្ពស់ជាងនាយកសាលារៀន និងជួយដោះស្រាយនូវកង្វះសម្ភារនិងមធ្យោបាយធ្វើដំណើរសម្រាប់អធិការ។

*ស្ថាប័នជំនាញថ្នាក់ជាតិ និងវិទ្យាស្ថានជាតិអប់រំ* គួរពង្រីកការផ្សព្វផ្សាយពីប្រព័ន្ធអធិការកិច្ចថ្មី ឱ្យបានទូលំទូលាយដល់មន្ត្រីគ្រប់គ្រងថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត នាយកសាលារៀនគ្រប់កម្រិតថ្នាក់ និងក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ខណ្ឌ ស្រុក (DTMT) តាមរយៈវគ្គបំប៉ន ឬសិក្ខាសាលាផ្សព្វផ្សាយ។

*ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត និងអធិការ* គួរធ្វើផែនការចុះអធិការកិច្ចឱ្យបានច្បាស់លាស់ ហើយបំលែងផែនការនោះ ទៅជាថវិកាជាក់លាក់ដើម្បីស្នើសុំថវិការដ្ឋ ឬថវិកាដៃគូអភិវឌ្ឍ សម្រាប់ការចុះធ្វើអធិការកិច្ច។ មន្ទីរអប់រំ យុវជន និងកីឡាគួរមានកញ្ចប់ថវិកាដោយឡែកសម្រាប់ការអនុវត្តការងារអធិការកិច្ចតាមសាលារៀន។

*នាយក-នាយិកាសាលារៀន* គួរផ្សព្វផ្សាយបន្តដល់បុគ្គលិក និងគ្រូបង្រៀនក្នុងសាលារៀនរបស់ខ្លួនអំពីអធិការកិច្ចអប់រំជាប្រព័ន្ធនេះឱ្យបានទូលំទូលាយ បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលអំពីអធិការកិច្ចអប់រំជាប្រព័ន្ធ។

*គ្រូឧទ្ទេសអធិការអប់រំ* គួរពង្រឹងសមត្ថភាពបន្ថែមលើ ការងារអធិការកិច្ច ដើម្បីឱ្យមានចំណេះទូលំទូលាយក្នុងការលើកឧទាហរណ៍ឱ្យចំគោលដៅ និងការកែលម្អចម្លើយរបស់សិក្ខាកាមឱ្យបានល្អ។ គ្រូឧទ្ទេសគួរពិភាក្សាគ្នាឱ្យបានស៊ីជម្រៅលើខ្លឹមសារមេរៀននីមួយៗ ដើម្បីឱ្យការបង្រៀនបានល្អដូចៗគ្នា និងគួរកែលម្អមេរៀនមួយចំនួនដែលសិក្ខា-កាមពុំទាន់យល់ច្បាស់ និងពុំទាន់អាចយកទៅអនុវត្តបានល្អប្រសើរ ដើម្បីបើកវគ្គបំប៉នឡើងវិញ។

## ៦. ឯកសារយោង


1. Chapman, C. (2001), Changing Classrooms Through Inspections, *School Leadership and Management*, 21, 59–73
2. Colin, R. (2004). School Inspection. *Journal of Philosophy of Education*, 35, 1-10
3. Dedering, K. & Muller, S. (2011). School Improvement through Inspections? First Empirical Insights from Germany. *Journal of Educational Change*, 12, 301-322
4. Ehren, M.C.M. & Visscher, A.J. (2008). The Relationships between School Inspections,

School Characteristics and School Improvement. *British Journal of Educational Studies*, 56, 205-227

5. Marielle C. J. L. Klerks, (2012). The Effect of School Inspections, *Inspectorate for Youth Care, the Netherlands*
6. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
7. ច្បាប់ស្តីពីការអប់រំ (ព្រះរាជាណាចក្រកម្ពុជា) ឆ្នាំ២០០៧
8. ក្រសួងអប់រំ យុវជន និកីឡា បញ្ញត្តិនៃការធានាគុណភាពអប់រំ នៅកម្រិតមតេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា ឆ្នាំ២០១៥
9. វិទ្យាស្ថានជាតិអប់រំ កម្មវិធីបណ្តុះបណ្តាលអធិការថ្មី ឆ្នាំ២០១៥
10. វិទ្យាស្ថានជាតិអប់រំ កម្មវិធីបណ្តុះបណ្តាលអធិការមានស្រាប់អំពីអធិការកិច្ចអប់រំជាប្រព័ន្ធ ឆ្នាំ២០១៥
11. វិទ្យាស្ថានជាតិអប់រំ កម្មវិធីបណ្តុះបណ្តាល នាយកនាយិកា វិទ្យាល័យអំពីអធិការអប់រំជាប្រព័ន្ធ ឆ្នាំ២០១៥

# គុណភាពនៃការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅប្រទេសកម្ពុជា

នូវ វីរ៉ា ចៅ លិន នូ ចន្នី ប៉េង ទិត្យសុទ្ធី ជីវ ពេជ្រចិន្តា ថ្លាង សូរិយា ចាន់ រ៉ាដា បាន គនហេង ចេង ហុង ផ្លុង គូន

វិទ្យាស្ថានជាតិអប់រំ

សារអេឡិចត្រូនិចទំនាក់ទំនង: viraneau@hotmail.com, channy0207@gmail.com, tithsothypeng@yahoo.com, chaulinn@yahoo.com

***មូលន័យសង្ខេប៖*** *ការសិក្សាស្រាវជ្រាវនេះបង្ហាញពីគុណភាពនៃការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ តាមរយៈការពិនិត្យមើលពីស្ថានភាពនៃការបង្រៀនរបស់គ្រូមធ្យមសិក្សាទុតិយភូមិ ស្ថានភាពសិក្សារបស់សិស្សកំពុងរៀនត្រួតថ្នាក់ទី១២ និងស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូកម្រិតបង្រៀនឧត្តម។ ទិន្នន័យបានប្រមូលពីគ្រូបង្រៀនចំនួន៥៦៦នាក់ និងសិស្សចំនួន៤០៦នាក់ ពីវិទ្យាល័យចំនួន៣២ ក្នុងខេត្តចំនួន០៦ នៅប្រទេសកម្ពុជា តាមរយៈការបំពេញកម្រងសំណួរ ការពិភាក្សាក្រុមគោលដៅ ការសម្ភាស និងការសិក្សាព័ត៌មានពីឯកសារពាក់ព័ន្ធមួយចំនួន។ ការសិក្សានេះបង្ហាញថា ស្ថានភាពនៃការបំពេញកិច្ចការរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិមិនទាន់មានលក្ខណៈប្រសើរនៅឡើយ ដោយសារខ្វះការបំប៉នសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ការប្រជុំបច្ចេកទេសមិនបានធ្វើតាមផែនការ មិនមានបញ្ជាក់ពីវត្ថុបំណងនៃការប្រជុំ និងការលើកទឹកចិត្តគ្រូនៅមានកម្រិត។ ចំណែកឯការបង្រៀន និងរៀន នៅមានលក្ខណៈបែបទម្លាប់ ដូចជា សិស្សមើលនិងស្តាប់គ្រូពន្យល់បង្ហាញច្រើនជាងឱ្យសិស្សបង្កើតសម្មតិកម្ម រៀបចំការពិសោធ និងទាញសេចក្តីសន្និដ្ឋានបែបវិទ្យាសាស្ត្រ។ ដោយឡែក ស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមមានការទទួលស្គាល់ថា មានលក្ខណៈសមស្របនៅក្នុងបរិបទប្រទេស (មធ្យមភាគ=៤.០) ប៉ុន្តែនៅមានភាពមិនច្បាស់លាស់លើផ្នែកពិនិត្យតាមដាន និងវាយតម្លៃ ជាពិសេសលើផ្នែកកម្មសិក្សាប្រតិបត្តិគរុកោសល្យ។ ដូចនេះ ការផ្តល់វគ្គបំប៉នសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឱ្យត្រូវតាមតម្រូវការគួរតែត្រូវយកចិត្តទុកដាក់ កត្តាលើកទឹកចិត្តគ្រូបង្រៀនគួរតែធ្វើឡើងតាមគោលការណ៍ច្បាស់លាស់ ដើម្បីជំរុញសកម្មភាពចូលរួមបំពេញការងារឱ្យមានប្រសិទ្ធភាព និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមគួរតែមានភាពច្បាស់លាស់លើការធ្វើអធិការកិច្ចកម្មសិក្សាប្រតិបត្តិគរុកោសល្យ។*

***ពាក្យគន្លឹះ៖*** *គុណភាពនៃការបង្រៀន គុណវុឌ្ឍិគ្រូបង្រៀន គ្រូមធ្យមសិក្សាទុតិយភូមិ សិស្សរៀនត្រួតថ្នាក់ទី១២*

## ១. សេចក្តីផ្តើម

នៅក្នុងសតវត្សរ៍ទី២១នេះ ទស្សនៈនៃការអប់រំរបស់ពិភពលោកមាននិន្នាការផ្លាស់ប្តូរពី សង្គមសេដ្ឋកិច្ចផ្អែកលើកម្លាំងពលកម្ម ទៅជាសង្គមសេដ្ឋកិច្ចផ្អែកលើចំណេះដឹង ហើយមានតែការអប់រំប្រកបដោយគុណភាពទេដែលអាចកសាងធនធានមនុស្សឱ្យជួយសង្គម មានការអភិវឌ្ឍលើគ្រប់វិស័យបាន (Guofang & Danniel, 2011)។ ដើម្បីឆ្លើយតបទៅនឹងនិន្នាការនៃការប្រែប្រួលខាងលើនេះ រាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា បានកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ សម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ដោយផ្តោតជាចម្បងទៅលើការអភិវឌ្ឍមូលធនមនុស្ស សម្រាប់ប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ (អយក., ២០១៣)។ បណ្តាប្រទេសទាំងឡាយនៅក្នុងពិភពលោក ជាពិសេសបណ្តាប្រទេសនៅក្នុងសមាគមន៍អាស៊ាន បានកំណត់ថា គុណភាពនៃការអប់រំ គឺផ្តោតលើកត្តាបួនសំខាន់ៗរួមមាន នាយកសាលា គ្រូបង្រៀន កម្មវិធីសិក្សា និងសម្ភារឧបទេស (Anton, 2009)។ បន្ថែមពីលើនេះទៀត បណ្តាប្រទេសទាំងឡាយខាងលើក៏បានកំណត់ ពីលក្ខណៈប្រាំយ៉ាងនៃគ្រូបង្រៀនប្រកបដោយគុណភាព គឺចំណេះដឹងឯកទេស ចំណេះដឹងគរុកោសល្យ ចំណេះដឹងភាសាបរទេស ចំណេះដឹងព័ត៌មានវិទ្យា និងមានបុគ្គលិកលក្ខណៈល្អ។ ផ្សារភ្ជាប់ទៅនឹងការប្រែប្រួលប្រកបដោយភាពវិជ្ជមាននេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងនូវវិធានការអាទិភាពមួយចំនួនក្នុង «គោលនយោបាយស្តីពីគ្រូបង្រៀន» មានដូចជា ការត្រៀមរៀបចំឯក

សារក្របខណ្ឌគតិយុត្តិ ការជ្រើសរើស ការបណ្តុះបណ្តាល ការបែងចែក ការគាំទ្រគ្រប់ផ្នែក និងការវាយតម្លៃ (អយក., ២០១៣; សៀវភៅគោលនយោបាយស្តីពីគ្រូបង្រៀន, មករា ២០១៥)។

ការវិនិយោគលើវិស័យអប់រំ ជាពិសេសគ្រូបង្រៀន ជាកត្តាមិនអាចមើលរំលងបានឡើយ។ បញ្ហាចម្បងៗ ដែលពាក់ព័ន្ធនឹងគោលនយោបាយ ពង្រឹងគុណភាពនៃការបង្រៀនរួមមាន៖ គ្រូបង្រៀនខ្វះគុណវុឌ្ឍិ ភាពមិនមានទំនាក់ទំនងគ្នារវាងការបណ្តុះបណ្តាលគ្រូបង្រៀន និងតម្រូវការរបស់សាលារៀន ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ការផ្គត់ផ្គង់គ្រូបង្រៀនដែលមានគុណភាពឱ្យបានគ្រប់គ្រាន់តាមតម្រូវការនៃមុខវិជ្ជានីមួយៗ និងការពង្រាយគ្រូបង្រៀនឱ្យដល់សាលារៀននៅតាមតំបន់ (OECD, 2011)។

តាមលទ្ធផលនៃការស្រាវជ្រាវរបស់អង្គការVSO ឆ្នាំ ២០០៨ បង្ហាញថា គ្រូបង្រៀនមានឆន្ទៈក្នុងការបង្រៀន ប៉ុន្តែលក្ខខណ្ឌការងារ និងការលើកទឹកចិត្តមិនបានជំរុញឱ្យពួកគាត់ប្រឹងប្រែងបំពេញភារកិច្ចក្នុងការបង្រៀនឱ្យបានល្អទេ (Benveniste et al., 2008; NEP, 2008)។

យោងតាមរបាយការណ៍ ដែលចេញផ្សាយដោយអង្គការ យូណេស្កូ បញ្ជាក់ថា «ការផ្តល់លទ្ធភាពឱ្យពួកគាត់អាចបញ្ចេញសក្តានុពលរបស់ខ្លួន មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការលើកកម្ពស់គុណភាព នៃការរៀនសូត្រ»។ អង្គការនេះក៏បានបញ្ជាក់ផងដែរថា គុណភាពនៃការអប់រំមានការកើនឡើងនៅពេលដែល គ្រូទទួលបានការគាំទ្រ (UNES-CO, 2015-2016)។

បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូពាក់ព័ន្ធកំពុងយកចិត្តទុកដាក់ ក្នុងការបង្កើតយន្តការទាក់ទាញអ្នកដែលមានសមត្ថភាព និងមានចំណូលចិត្តឱ្យចូលធ្វើការក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានប្រសិទ្ធភាព គឺជាគន្លឹះនៃកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាល គ្រូបង្រៀនផងដែរ (អយក., ២០១៣; សៀវភៅគោលនយោបាយស្តីពីគ្រូបង្រៀន, មករា ២០១៥)។

ទោះបីជាយ៉ាងនេះក្តី ការដាក់ចេញនូវគោលនយោបាយគ្រូបង្រៀន និងការអនុវត្តគោលនយោបាយនេះ គឺជាជំហាននៃការចាប់ផ្តើមនៃរបត់ថ្មីមួយ ក្នុងដំណើរឆ្ពោះទៅរកគុណភាពនៃការអប់រំ។ ការជ្រើសរើសគ្រូ គឺជាវិធានក្នុងការបំពេញកង្វះគ្រូ ប៉ុន្តែការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យបានត្រឹមត្រូវទើបជាការបំពេញបាននូវការអប់រំ ដែលមានគុណភាព (UNESCO, 2015-2016; (Wan G., & Gut D. M., 2011)។ ដើម្បីសម្រេចបានគោលដៅខាងលើទាមទារឱ្យគ្រូបង្រៀនអភិវឌ្ឍសមត្ថភាពចំណេះដឹង និងជំនាញ ហើយត្រូវមានបំណិនច្បាស់លាស់ក្នុងការបង្រៀន មានឥរិយាបថប្រកបដោយឆន្ទៈ មានក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្រៀន។ ជាងនេះទៅទៀត គុណភាពនៃការអប់រំត្រូវមានការវាយតម្លៃដែលមានសូចនាករច្បាស់លាស់ ដើម្បីបញ្ជាក់ពីគុណភាព និងការធានាគុណភាពបណ្តុះបណ្តាល ព្រមទាំងការទទួលស្គាល់ពីមជ្ឈដ្ឋានសង្គម (Mohan M.et al, 2007)។ ទាំងនេះ គឺជាកត្តាគន្លឹះ ក្នុងការជួយសិស្សឱ្យទទួលបានលទ្ធផលល្អប្រសើរក្នុងការរៀនសូត្រផង ព្រមទាំងជួយឱ្យពួកគេក្លាយជាពលរដ្ឋពេញលេញ។ ការកសាងសមត្ថភាពគ្រូបង្រៀនប្រកបដោយចំណេះដឹងជំនាញឯកទេស វិធីសាស្ត្របង្រៀន និងបំណិនក្នុងវិជ្ជាជីវៈគ្រូបង្រៀនច្បាស់លាស់ គឺជាបន្ទុករបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដែលមានលទ្ធភាពគ្រប់គ្រាន់ និងមានយន្តការពិនិត្យតាមដានច្បាស់លាស់ក្នុងការបំពេញបេសកម្មនេះផងដែរ (Anton, 2009; UNESCO, 2015-2016; NEP, 2008; Gannicott, 2009)។ សមត្ថភាព និងគុណភាពបង្រៀនរបស់គ្រូបង្រៀនជះឥទ្ធិពល ទៅលើដំណើរការនៃការសិក្សារបស់សិស្ស។ តាមរយៈ លទ្ធផលប្រឡងបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិថ្នាក់ជាតិនៃសិស្សថ្នាក់ទី១២កន្លងទៅបង្ហាញថា ក្នុងឆ្នាំសិក្សា២០១២-២០១៣ លើកទីមួយគឺ ២៥% និងលើកទីពីរគឺ ១៧.៩៤%។ ចំណែកលទ្ធផលសម្រាប់ឆ្នាំសិក្សា ២០១៣-២០១៤ គឺបានតែ២៥.៧២% និងសម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ អត្រាប្រឡងជាប់គឺ៥៦% (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ, របាយការណ៍ស្តីពីលទ្ធផលប្រឡងមធ្យមសិក្សាទូទាំងប្រទេស, ២០១៤-២០១៥ និង ២០១៥-០១៦)។ លទ្ធផលទាំងនេះបង្ហាញថា ភាគរយនៃកំណើនលទ្ធផល និងសមិទ្ធផលសិក្សារបស់សិស្សមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំកំណែទម្រង់ ការប្រឡងនៅមានកម្រិតទាប។

ជារួម លទ្ធផលនេះអាចបញ្ជាក់ផងដែរថា ភាគរយសិស្សដែលប្រឡងធ្លាក់ច្រើន ក៏នៅជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បន្តទៀត។ នេះជាមូលហេតុធ្វើឱ្យកើតមានឡើងនូវការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។

### វត្ថុបំណងនៃការស្រាវជ្រាវ

ការសិក្សានេះត្រូវបានរៀបចំឡើង ដើម្បីពិនិត្យមើលពី លទ្ធភាពបំពេញការងាររបស់គ្រូដែលកំពុងបង្រៀនថ្នាក់ទី១២នៅតាមវិទ្យាល័យ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ការពង្រឹងគុណភាពនៃការបង្រៀននិងរៀន ការវាយតម្លៃលទ្ធផលសិក្សា និងការលើកទឹកចិត្តគ្រូ ព្រមទាំងស្ថានភាពសិក្សារបស់សិស្សរៀនត្រូតថ្នាក់ទី១២ និងកត្តាដែលអាចជះឥទ្ធិពលលើ ដំណើរការសិក្សារបស់ពួកគេ។ ការសិក្សានេះ ក៏ត្រូវបានពិនិត្យផងដែរពី ស្ថានភាពបណ្តុះបណ្តាលគ្រូ កម្រិតឧត្តម កម្មវិធីបណ្តុះណ្តាល សមត្ថភាពគ្រូឧទ្ទេស គុណភាព និងប្រសិទ្ធភាព ការដឹកនាំ គ្រប់គ្រង ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ។

### សំណួរស្រាវជ្រាវ

ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើក្រុមការងារស្រាវជ្រាវផ្តោតលើសំណួរស្រាវជ្រាវ៣គឺ (១)តើស្ថានភាពនៃការបង្រៀនរបស់គ្រូកំពុងបង្រៀននៅតាមវិទ្យាល័យមានលក្ខណៈបែបណា? (២)តើស្ថានភាពនៃការសិក្សារបស់សិស្សកំពុងរៀនត្រូតថ្នាក់ទី១២ មានលក្ខណៈបែបណា? ហើយ តើកត្តាអ្វីខ្លះបានជះឥទ្ធិពលលើការសិក្សារបស់ពួកគេ? និង (៣)តើស្ថានភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូកម្រិតឧត្តមមានលក្ខណៈយ៉ាងដូចម្តេច?

## ២. វិធីសាស្ត្រស្រាវជ្រាវ

សំណួរស្រាវជ្រាវចែកចេញជាពីរផ្នែកធំៗគឺ មួយផ្នែកសម្រាប់គ្រូកំពុងបង្រៀនថ្នាក់ទី១២ និងមួយផ្នែកទៀតសម្រាប់សិស្សកំពុងរៀនត្រូតថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា ២០១៥-២០១៦។ ដើម្បីប្រមូលបានទិន្នន័យជាក់លាក់មានសុក្រឹតភាព និងភាពគួរឱ្យទុកចិត្តបាន អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រទាំងបែបបរិមាណវិស័យ និងគុណវិស័យ។

### ២.១ ភាគសំណាក

ការសិក្សានេះរួមមានភាគសំណាកជា គ្រូកំពុងបង្រៀនថ្នាក់ទី១២ចំនួន៥៦៦នាក់ ដែលក្នុងនោះមានគ្រូភេទស្រីចំនួន១៣៩នាក់(២៤.២៥%) និងសិស្សកំពុងរៀនត្រូតថ្នាក់ទី១២ចំនួន៤០៦នាក់ ដែលក្នុងនោះមានសិស្សភេទស្រីចំនួន២០៩នាក់(៥១.៥%) ក្នុងឆ្នាំសិក្សា ២០១៥-២០១៦។ ភាគសំណាកគ្រូ និងសិស្សទាំងអស់នេះ ត្រូវបានជ្រើសរើសដោយចៃដន្យចេញពី តារាងស្ថិតិរបស់សាលារៀននីមួយៗ ដោយជ្រើសយកតែគ្រូកំពុងបង្រៀនថ្នាក់ទី១២ និងសិស្សកំពុងរៀនត្រូតថ្នាក់ទី១២ ដែលបានផ្តល់ឱ្យដោយមន្ទីរអប់រំ យុវជន និងកីឡា របស់វិទ្យាល័យចំនួន៣២ ក្នុងស្រុកចំនួន២២ នៃខេត្តចំនួន០៦ (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ កំពត ព្រៃវែង និងស្វាយរៀង)។ ក្នុងចំណោមវិទ្យាល័យទាំង៣២ ដែលបានជ្រើសរើសរួមមាន វិទ្យាល័យនៅទីប្រជុំជនចំនួន២០ (៦៨.៧៥%) នៅជនបទចំនួន១១ (៣៤.៣៨%) និងនៅតំបន់ជួបការលំបាកចំនួន០១(៣.១២%)។

ភាគសំណាកជាគ្រូ និងសិស្សដូចមានចំនួនខាងលើបានចូលរួមបំពេញកម្រងសំណួរ ផ្តល់ជូនតាមផ្នែកដាច់ដោយឡែក។ ភាគសំណាកគ្រូត្រូវបានបែងចែកជាក្រុមគ្រូមុខវិជ្ជាវិទ្យាសាស្ត្រនិងគណិតវិទ្យា និងក្រុមគ្រូមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ដើម្បីក្លាយជាក្រុមគោលដៅសម្រាប់ធ្វើការពិភាក្សាក្រុម ក្នុងការស្វែងយល់ពីទស្សនៈរបស់ពួកគាត់លើស្ថានភាពរបស់គ្រូដែលកំពុងបង្រៀនថ្នាក់ទី១២ ស្ថានភាពបច្ចុប្បន្ន នៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ដែលអាចជាកត្តាជះឥទ្ធិពលលើសមត្ថភាព និងលទ្ធភាពសិក្សារបស់សិស្សថ្នាក់ទី១២។

### ២.២ ឧបករណ៍ស្រាវជ្រាវ

ការសិក្សានេះ ប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ ដូចជា (១) កម្រងសំណួរសម្រាប់បំពេញដោយគ្រូដែលកំពុងបង្រៀនថ្នាក់ទី១២ (២) កម្រងសំណួរសម្រាប់បំពេញដោយសិស្សដែលកំពុងរៀនត្រូតថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា ២០១៥-២០១៦ និង (៣) សំណួរពិភាក្សាក្រុមសម្រាប់ពិភាក្សា និងបំពេញចម្លើយដោយគ្រូដែលកំពុងបង្រៀនថ្នាក់ទី១២។

### ២.៣ ការប្រមូលទិន្នន័យ

ទិន្នន័យសម្រាប់ការសិក្សានេះបានមកពីប្រភពពីរគឺ គ្រូ និងសិស្ស តាមរយៈការបំពេញកម្រងសំណួរស្ទាបស្ទង់មតិ និងចម្លើយសំណួរក្រុមគោលដៅ ដែលបានប្រព្រឹត្តិធ្វើនៅក្នុងវិទ្យាល័យទាំង៣២ ក្នុងខេត្តទាំង០៦ ចាប់ពីខែមីនា ដល់ខែមិថុនា ឆ្នាំ២០១៦។

ជាដំបូង កម្រងសំណួរត្រូវបានចែកជូនទៅកាន់ភាគសំណាកគ្រូកំពុងបង្រៀនថ្នាក់ទី១២ និងសិស្សកំពុង

រៀនត្រួតថ្នាក់ទី១២ ដើម្បីបំពេញនឹងប្រគល់មកវិញបន្ទាប់ពីទទួលការណែនាំយ៉ាងច្បាស់លាស់ ពីការបំពេញកម្រងសំណួរ។ កម្រងសំណួរដែលពួកគេបំពេញបានប្រើស្កេលជាបំពេញចន្លោះ និងពហុជម្រើស។

បន្ទាប់មក ដើម្បីបង្កើនសុពលភាពនៃការរកឃើញសំណួរស្ទាបស្ទង់មតិក្រុមគោលដៅ ត្រូវបានផ្តល់ជូនទៅដល់ក្រុមគោលដៅសម្រាប់គ្រូដែលបានកំណត់រួច ដើម្បីពិភាក្សាក្រុមរកចំណុចរួម នៃចម្លើយសំណួរស្ទាបស្ទង់មតិ។ កម្រងសំណួរនេះត្រូវបានរៀបចំតាមមាត្រដ្ឋានLikert (ពី១ ដល់៥) ដែលមានភាពជឿជាក់បានគឺ តម្លៃអាល់ហ្វាCronbach នៃភាពអាចជឿទុកចិត្តមានកម្រិតខិតទៅរកភាពល្អប្រសើរគឺស្ថិតក្នុងចន្លោះពី α=០.៨១៣ ដល់០.៩៥៤ សម្រាប់កម្រងសំណួរគ្រូ និងពី α=០.៦៧៤ ដល់០.៨៤៦ សម្រាប់កម្រងសំណួរសិស្ស។ កម្រងសំណួរត្រូវបានសាកល្បងជាលើកដំបូងជាមួយគ្រូចំនួន១៣នាក់ និងសិស្សចំនួន១០នាក់ និងសាកសួរព័ត៌មានសម្រាប់ពិនិត្យមើលភាពច្បាស់លាស់។ បន្ទាប់មកកម្រងសំណួរដែលបានកែសម្រួលចុងក្រោយត្រូវបាន យកទៅសួរគ្រូកំពុងបង្រៀនថ្នាក់ទី១២ និងសិស្សកំពុងរៀនត្រួតថ្នាក់ទី១២ នៃវិទ្យាល័យចំនួន៣២ក្នុងខេត្តចំនួន០៦ នៅប្រទេសកម្ពុជា។

ការស្រាវជ្រាវនេះ ផ្តោតសំខាន់តែលើប្រសិទ្ធភាពនានាដែលទាក់ទងនឹងគុណភាពនៃការបង្រៀនរបស់គ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាតែប៉ុណ្ណោះ។

## ២.៤ វិធីសាស្ត្រវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រចម្រុះទាំងបរិមាណវិស័យ និងគុណវិស័យ។ ដំបូង ចម្លើយនៃសំណួរស្ទាបស្ទង់មតិទាំងគ្រូបង្រៀន និងសិស្សត្រូវបានបញ្ចូលទៅក្នុងកម្មវិធីSPSS ហើយសំណួរពិភាក្សាក្រុមគោលដៅត្រូវបានវិភាគតាមបែបគុណវិស័យ ដោយដាក់ជាក្រុមតាមមូលន័យសំខាន់ៗ។ បន្ទាប់មក ទិន្នន័យកម្រងសំណួរត្រូវសំអាតដើម្បីធានាគុណភាព និងសីលធម៌វិជ្ជាជីវៈរបស់អ្នកស្រាវជ្រាវ។ ជាចុងក្រោយ ទិន្នន័យត្រូវបានវិភាគ តាមរយៈការគណនាស្ថិតិពិពណ៌នា ដូចជា ចំនួនប្រេកង់ ភាគរយ និងមធ្យមភាគ។

## ៣. លទ្ធផល និងការពិភាក្សា

### ៣.១ ស្ថានភាពគ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ

ជាទូទៅ គុណភាពនៃការបង្រៀនរបស់គ្រូបង្រៀនត្រូវបានគេទទួលស្គាល់ថា ជាប់ពាក់ព័ន្ធនឹងកត្តាជាច្រើនផ្នែក ដូចជា សមត្ថភាពលើផ្នែកចំណេះដឹងមុខវិជ្ជាឯកទេស ជំនាញ ឬបំណិនគរុកោសល្យក្នុងការបង្រៀន ជាពិសេសការគាំទ្រទាំងផ្នែកស្មារតី និងសម្ភារ គឺជាសមាសភាគសំខាន់ ដែលជំរុញឱ្យគ្រូបង្រៀនមានលទ្ធភាពបំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈ (Benveniste et al., 2008; OECD, 2011)។ ការស្វែងយល់ស្ថានភាពជាក់ស្តែងក្នុងការបំពេញការងារ របស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិផ្តោតលើ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ការបង្រៀននិងរៀន របៀបនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការលើកទឹកចិត្តគ្រូ។

#### ៣.១.១ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ គឺជាដំណើរការនៃការផ្តល់សេវាបណ្តុះបណ្តាល ឬការបំប៉នសមត្ថភាពបន្ត និងការផ្តល់ជំនួយការបច្ចេកទេសដើម្បីធ្វើឱ្យស្ថាប័ន ឬសាលារៀនមួយ មានការផ្លាស់ប្តូរជាវិជ្ជមានប្រកបដោយនិរន្តភាព (Anton, 2009)។ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន គឺជាកត្តាចាំបាច់សម្រាប់ជួយឱ្យគ្រូបង្រៀនបំពេញការងារប្រកបដោយប្រសិទ្ធភាព ក៏ដូចជាជំរុញឱ្យមានការបង្រៀនមានភាពទាក់ទាញសិស្ស ឱ្យខិតខំរៀន និងទទួលបានលទ្ធផលល្អ។ ជាទូទៅ ការបណ្តុះបណ្តាល និងការបំប៉នសមត្ថភាពគឺត្រូវឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ព្រោះវាមានសារៈប្រយោជន៍សម្រាប់យកទៅអនុវត្តក្នុងការបង្រៀន។ ការបណ្តុះបណ្តាល និងការបំប៉ន រួមមាន ជំនាញឯកទេស វិធីសាស្ត្របង្រៀនថ្មីតាមបែបគរុកោសល្យទំនើប (វិធីវិទ្យាសាស្ត្រ វិធីសាស្ត្ររៀនតាមបែបរិះរក...) ហ្វឹកហ្វឺនគរុកោសល្យ ការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់ICTក្នុងការបង្រៀន ការបំប៉នលើវគ្គតម្រង់ទិសសៀវភៅសិក្សាថ្មី សិក្ខាសាលាស្តីពីកម្មវិធីសិក្សាថ្មី សិក្ខាសាលាស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ សិក្ខាសាលាស្តីពីយេនឌ័រ និងសិទ្ធិមនុស្ស ឬសិទ្ធិកុមារ និងវគ្គខ្លីៗ (ទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស) ជាដើម។

ការសិក្សានេះបង្ហាញថា គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិជាង៩៥% ធ្លាប់បានទទួលការបណ្តុះបណ្តាលបន្តជាមធ្យមមិនដល់១ដងផង (០.៥ដង)

ក្នុងមួយឆ្នាំ (រូបទី១)។ តាមការពិភាក្សាក្រុមពួកគាត់បានបញ្ជាក់បន្ថែមថា វគ្គបណ្តុះបណ្តាលបន្តភាគច្រើនដែលបានផ្តល់ឱ្យ គឺសម្រាប់គ្រូមុខវិជ្ជាវិទ្យាសាស្ត្រតែប៉ុណ្ណោះ។ ឧទាហរណ៍ដូចជា វិធីវិទ្យាសាស្ត្រ វិធីសាស្ត្ររៀនតាមបែបរិះរក និងការសិក្សាស្រាវជ្រាវមេរៀន ជាដើម ដែលទទួលបានការឧបត្ថម្ភពីអង្គការ JICA/STEPSAM, VVOB និង VSO (JICA, 2009)។ លើសពីនេះទៀត ចំណេះដឹងដែលទទួលបានពីការបំប៉នភាគច្រើនអាចជួយដល់ការបង្រៀនរបស់គាត់ ប៉ុន្តែឱកាសនៃការទទួលបានតិចតួចពេក និងជាពិសេសអ្នកខ្លះចូលរួមវគ្គមិនត្រូវជំនាញឯកទេសរបស់ពួកគាត់ទៀតផង។ គួរឱ្យកត់សម្គាល់ផងដែរ គ្រូមុខវិជ្ជាវិទ្យាសាស្ត្រសង្គមបានឆ្លើយថា ពួកគាត់កម្របានចូលរួមវគ្គបំប៉នស្តីពីជំនាញឯកទេស វិធីសាស្ត្របង្រៀនថ្មីតាមបែបគរុកោសល្យទំនើប និងការប្រើប្រាស់ICTក្នុងការបង្រៀននោះណាស់ លើកលែងតែគ្រូមុខវិជ្ជាភាសាបរទេស។




រូបទី១៖ ការបណ្តុះបណ្តាលបន្តគិតជាចំនួនដងក្នុង១ឆ្នាំ

ចំណែកឯ ការផ្តល់ជំនួយការបច្ចេកទេសនៅក្នុងសាលារៀនត្រូវបានផ្តល់ឱ្យ តាមរយៈការប្រជុំបច្ចេកទេសជាប្រចាំ និងត្រូវមានប្រធានបទ ព្រមទាំងរបៀបវារៈជាក់លាក់ដែលជាចំណុចសំខាន់ទាមទារដំណោះស្រាយ និងមានការចូលរួមពីអ្នកពាក់ព័ន្ធ ដូចជា គ្រូបង្រៀនតាមឯកទេស ដើម្បីចែករំលែកបទពិសោធន៍ ឬការដាក់ចេញជាគោលការណ៍ក្នុងការអនុវត្តឱ្យបានសមស្រប។ ការសិក្សានេះបង្ហាញថា គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិធ្លាប់បានចូលរួមប្រជុំបច្ចេកទេសជាមធ្យមចំនួន២.៧២ដងក្នុងមួយឆ្នាំ (រូបទី២) ដែលការប្រជុំបច្ចេកទេសនោះផ្តោតជាសំខាន់លើការរៀបចំបំណែងចែក កម្មវិធីសិក្សាប្រចាំឆ្នាំ ការធ្វើកិច្ចតែងការបង្រៀនប្រចាំម៉ោងសិក្សា ការពិភាក្សាពីរបៀបបង្រៀនបញ្ញតិពិបាក ការផ្លាស់ប្តូរបទពិសោធន៍បង្រៀន ការផលិតសម្ភារៈបង្រៀន ការរៀបចំសម្ភារៈបង្រៀន ការសង្កេតការបង្រៀនរបស់គ្រូបង្រៀនមុខវិជ្ជាផ្សេងទៀត ការទទួលការសង្កេតថ្នាក់ពីគ្រូបង្រៀនមុខវិជ្ជាដទៃ និងថ្នាក់និទស្សន៍។ ក្នុងនោះ ការធ្វើកិច្ចតែងការបង្រៀនគឺជាប្រធានបទដែលបានលើកមកប្រជុំបច្ចេកទេសញឹកញាប់ជាងគេ ពោលជាមធ្យមចំនួនជាង៣ដងក្នុង១ឆ្នាំ ហើយការប្រជុំលើប្រធានបទ នៃការសង្កេតថ្នាក់មុខវិជ្ជាផ្សេង និងការទទួលការសង្កេតថ្នាក់ពីមុខវិជ្ជាដទៃជាមធ្យមបានតែ១ដងក្នុង១ឆ្នាំ ប៉ុណ្ណោះ។ ចំណែកឯការប្រជុំពីរបៀបបង្រៀនបញ្ញត្តិពិបាក ការផ្លាស់ប្តូរបទពិសោធបង្រៀន ការផលិត និងរៀបចំសម្ភារបង្រៀនបានជាង២ដងក្នុង១ឆ្នាំ (២.៥ដង)។

លទ្ធផល នៃការពិភាក្សាស៊ីជម្រៅក្នុងក្រុមគោលដៅ បង្ហាញថា រាល់ការប្រជុំបច្ចេកទេសធ្វើឡើងតាមក្រុមមុខវិជ្ជាគឺស្ថិតក្នុងចន្លោះ ពី៤ទៅ១២ដងក្នុង១ឆ្នាំ និងខុសគ្នាទៅតាមសាលារៀន និងខេត្ត។ ការប្រជុំបច្ចេកទេសភាគច្រើនធ្វើលើប្រធានបទ ដូចជា វិធីសាស្ត្រនៃការបង្រៀននិងរៀន ខ្លឹមសារមេរៀនពិបាកយល់ និងប្រធានបទលើការផលិតសម្ភារឧបទេស ការពិភាក្សាបញ្ញត្តិពិបាក និងការធ្វើថ្នាក់និទស្សន៍ និងការផលិតវិញ្ញាសាសម្រាប់ប្រឡងមាន

ចំនួនតិច។ លទ្ធផលពិភាក្សាក្រុមគោលដៅនេះអាចបញ្ជាក់បានថា មូលហេតុនៃការប្រជុំបច្ចេកទេសភាគច្រើនធ្វើឡើងដើម្បីពង្រឹងសមត្ថភាពបង្រៀន ការអនុវត្តកម្មវិធីក្នុងសៀវភៅសិក្សាគោល ឱ្យទាន់កម្មវិធីសិក្សាក្រសួងអប់រំ ដំណោះស្រាយបញ្ហាប្រឈម ចំណុចខ្វះខាត និងការផ្លាស់ប្តូរបទពិសោធគ្នាក្នុងការបង្រៀនគឺមានតិចតួច។ លទ្ធផលនេះក៏អាចបញ្ជាក់បានថា ពួកគាត់យល់ថាការប្រជុំបច្ចេកទេសមានសារៈសំខាន់ ប៉ុន្តែដំណើរការ ឬនៃការប្រជុំមិនច្បាស់លាស់ ពីព្រោះមិនមានបានបញ្ជាក់ពីវត្ថុបំណងនៃការប្រជុំ ព្រមទាំងមិនបានធ្វើជាប្រចាំតាមផែនការ។




រូបទី២៖ ការប្រជុំបច្ចេកទេសគិតចំនួនដងក្នុង១ឆ្នាំ

## ៣.១.២ ការបង្រៀន និងរៀន

សក្តានុពល នៃការបំពេញការងាររបស់គ្រូបង្រៀនពឹងផ្អែកលើកម្លាំងកាយ ចិត្ត បញ្ញាស្មារតី ចំណេះដឹង និងបទពិសោធន៍លើជំនាញវិជ្ជាជីវៈ ដែលរួមចំណែកធ្វើឱ្យការងារទទួលបានលទ្ធផលល្អ (Joo et al , 2010)។ ការសិក្សាស្រាវជ្រាវនេះបង្ហាញថា ក្នុងចំណោមគ្រូបង្រៀនទាំងអស់មានអាយុចន្លោះពី២៥ដល់៦០ឆ្នាំ ដែលបានចូលរួមឆ្លើយសំណួរដែលអ្នកមានអាយុចន្លោះពី៣១ដល់៣៥ឆ្នាំមានភាគរយច្រើនជាងគេគឺ២៧% ខណៈដែលគ្រូបង្រៀនអាយុចន្លោះពី៥៦ដល់៦០ឆ្នាំមានភាគរយទាបជាងគេ គឺ ១.១%តែប៉ុណ្ណោះ។ គ្រូបង្រៀនអាយុចន្លោះពី៤១ដល់៤៥ឆ្នាំ និង២៥ដល់៣០ឆ្នាំមាន២១.៧% និង២១.២%។ លទ្ធផលនេះបង្ហាញថា គ្រូបង្រៀនភាគច្រើននៅវ័យក្មេង ពេញកម្លាំងកាយ ដែលជាសក្តានុពលក្នុងការបង្រៀនសិស្សបានល្អតាមម៉ោងកំណត់។ ផ្អែកលើបទពិសោធន៍បង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ គ្រូបង្រៀនភាគច្រើនមានបទពិសោធន៍បង្រៀនតិចឆ្នាំគឺ ចាប់ពី១ដល់៥ឆ្នាំមាន២៨% និងពី៦ដល់១០ឆ្នាំមាន៣០% ចំណែកឯគ្រូបង្រៀនមានបទពិសោធន៍បង្រៀនច្រើនឆ្នាំ ពី២៦ដល់៣០ឆ្នាំមានតែ ៣.០% និងពី៣១ដល់៣៥ឆ្នាំមានតែ០.២%ប៉ុណ្ណោះនៃភាគសំណាកសរុប។ សម្រាប់គ្រូមានបទពិសោធន៍បង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិពី១១ដល់១៥ឆ្នាំ ពី១៦ដល់២០ឆ្នាំ និងពី២១ដល់២៥ឆ្នាំ មាន១១% ១៩% និង៧.៨%។

គុណវុឌ្ឍិរបស់គ្រូបង្រៀន គឺជាកត្តាសំខាន់មួយក្នុងចំណោមកត្តាជាច្រើនទៀត។ គុណភាពនៃការបង្រៀន និងលទ្ធភាពបំពេញការងាររបស់គ្រូបង្រៀន ក៏អាស្រ័យទៅនឹងកម្រិតវប្បធម៌ជាមូលដ្ឋានដើម្បី ឈោងចាប់យកចំណេះដឹងឯកទេស និងជំនាញវិជ្ជាជីវៈផងដែរ (Anton, 2009; Boyd et al , 2011; Lankford et al., 2002)។ ការប្រើប្រាស់គ្រូបង្រៀននៅក្នុងបរិបទប្រទេសកម្ពុជាមានការបត់បែន និងសម្របសម្រួលតាមតម្រូវការចាំបាច់។ ការសិក្សានេះបង្ហាញថា គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិមានកម្រិតវប្បធម៌ចាប់ពីបឋមសិក្សារហូតដល់បរិញ្ញាបត្រជាន់ខ្ពស់។ ក្នុងនោះ គ្រូបង្រៀនមានសញ្ញាបត្របរិញ្ញាបត្រមានភាគរយខ្ពស់គឺស្មើនឹង៧៦.៤% សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ១១.៨% និងបរិញ្ញាបត្រជាន់ខ្ពស់មានតែ ៩.៥%ប៉ុណ្ណោះ។ ប៉ុន្តែលទ្ធផលគួរឱ្យកត់សម្គាល់នោះ គឺ គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិចំនួន១.១% និង

០.៤% មានសញ្ញាបត្រត្រឹមតែកម្រិតមធ្យមសិក្សាបឋមភូមិ និងបឋមសិក្សា។ ក្នុងចំណោមគ្រូបង្រៀនកំពុងបង្រៀនថ្នាក់ទី១២ ដែលបានឆ្លើយផ្នែកនេះមានចំនួន៥១៥នាក់ ដែលក្នុងនោះគ្រូបង្រៀនមានសញ្ញាបត្រគ្រូកម្រិតឧត្តម ៦៦.៥%(៣៧៧នាក់) ហើយអ្នកមិនទទួលបាន ការបណ្តុះបណ្តាលជាគ្រូបង្រៀនកម្រិតឧត្តមមាន២៤.៣% (១៣៨នាក់)។

បន្ថែមពីលើនេះ គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ជាទូទៅ គ្រូម្នាក់បង្រៀនលើសពី១កម្រិតថ្នាក់ ដូចជា គ្រូម្នាក់បង្រៀនទាំងថ្នាក់ទី១២ និងថ្នាក់ទី១០ ឬថ្នាក់ទី១១។ លទ្ធផលសិក្សាបង្ហាញថា ក្នុងចំណោមសំណាកគ្រូបង្រៀនចំនួន៥៦៤នាក់ មានគ្រូបង្រៀនតែ១៣.១២% (៧៤នាក់) ប៉ុណ្ណោះដែលកំពុងបង្រៀនតែមួយកម្រិតថ្នាក់ទី១២, ៨.៥១%(៤៨នាក់) កំពុងបង្រៀនទាំងបីកម្រិតថ្នាក់ (ទី១០ ទី១១ និងទី១២), ៥១.៥៩%(២៩១នាក់) កំពុងបង្រៀនទាំងថ្នាក់ទី១១និងទី១២ និង២១.៦៣%(១២២នាក់) កំពុងបង្រៀនទាំងថ្នាក់ទី១០ និងទី១២ (រូបទី៣)។




រូបទី៣៖ កម្រិតថ្នាក់ដែលគ្រូបង្រៀន

ការបង្រៀនបានល្អទាមទារឱ្យគ្រូបង្រៀន រៀបចំកិច្ចតែងការបង្រៀន និងសម្ភារបង្រៀននិងរៀនឱ្យបានគ្រប់គ្រាន់។ ដូច្នេះ ការបង្រៀនច្រើនកម្រិតថ្នាក់ទាមទារឱ្យគ្រូបង្រៀនចំណាយពេលវេលាស្រាវជ្រាវច្រើន ដើម្បីធ្វើកិច្ចតែងការបង្រៀន និងរៀបចំ ឬផលិតសម្ភារបង្រៀន និងរៀនឱ្យបានគ្រប់កម្រិតថ្នាក់ផងដែរ។

សកម្មភាពអនុវត្តក្នុងលំនាំនៃការបង្រៀន និងរៀន គឺជាកិច្ចការចម្បង និងចាំបាច់សម្រាប់ឱ្យសិស្សធ្វើសកម្មភាពដើម្បីទទួលយកចំណេះដឹង និងជំនាញពេញលេញ មានន័យថា ការរៀនតាមរយៈទ្រឹស្តីផ្សារភ្ជាប់នឹងការប្រតិបត្តិ។ លទ្ធផលសិក្សានេះ បង្ហាញថា គ្រូបង្រៀនប្រហែល៩៨%អនុវត្តសកម្មភាពបង្រៀន ដូចជា ការពន្យល់បង្ហាញឱ្យសិស្សមើល ឬស្តាប់ ឱ្យសិស្សរំលឹកមេរៀននៅក្នុងថ្នាក់ ផ្តល់ឱកាសឱ្យសិស្សខ្សោយបានចូលរួមសកម្មភាពរៀនក្នុងថ្នាក់ ឱ្យសិស្សទទួលបានការកែលម្អ ការគាំទ្រ និងការលើកទឹកចិត្ត ហើយសិស្សពេញចិត្តនឹងសកម្មភាពរៀនបែបនេះនៅរាល់ម៉ោងសិក្សា។ លើសពីនេះទៀត គ្រូបង្រៀនប្រហែលជាង៩៧% បានឆ្លើយថា ការបង្រៀនជាញឹកញាប់ផ្តោតលើសកម្មភាព ដូចជា ឱ្យសិស្សបង្កើតសម្មតិកម្ម ពិភាក្សាក្រុមតូច (៣-៥នាក់) ពិភាក្សាក្រុមធំ (៦-៨នាក់) ពិភាក្សាដៃគូ ធ្វើការជាបុគ្គល បកស្រាយពន្យល់ពីខ្លឹមសារនៃការពិភាក្សារបស់ខ្លួន ទាញទំនាក់ទំនងខ្លឹមសារមេរៀនទៅ នឹងការរស់នៅក្នុងជីវភាពប្រចាំថ្ងៃ និងសិស្សពូកែជួយសិស្សខ្សោយ។ ក្រៅពីនេះ គ្រូបានឱ្យសិស្សរៀបចំការពិសោធន៍ម្តងម្កាលដែរ (តារាងទី១)។

តារាងទី១៖ សកម្មភាពដែលគ្រូបង្រៀនបានប្រើក្នុងម៉ោងបង្រៀន

| សកម្មភាពបង្រៀនផ្តោតលើ | មធ្យមភាគ | អ្នកឆ្លើយ(%) |
|---|---|---|
| សិស្សមើលឬស្តាប់គ្រូពន្យល់បង្ហាញ | 1.34 | 97.53 |
| សិស្សបង្កើតសម្មតិកម្ម | 2.08 | 94.88 |
| សិស្សរៀបចំការពិសោធ | 2.55 | 94.35 |
| សិស្សពិភាក្សាក្រុមតូច (៣-៥នាក់) | 2.38 | 97.70 |
| សិស្សពិភាក្សាក្រុមធំ (៦-៨នាក់) | 2.72 | 96.64 |
| សិស្សពិភាក្សាឬធ្វើការជាដៃគូ | 2.28 | 97.35 |
| សិស្សធ្វើការជាបុគ្គល | 2.20 | 97.17 |
| សិស្សបកស្រាយពន្យល់លទ្ធផលនៃការពិភាក្សា | 2.25 | 97.00 |
| សិស្សទាញទំនាក់ទំនងខ្លឹមសារមេរៀនទៅនឹងការរស់នៅក្នុងជីវភាពប្រចាំថ្ងៃ | 2.17 | 96.82 |
| សិស្សរំឭកមេរៀននៅក្នុងថ្នាក់ | 1.95 | 98.41 |
| សិស្សពូកែជួយសិស្សខ្សោយ | 2.29 | 98.06 |
| សិស្សខ្សោយមានឱកាសចូលរួមសកម្មភាពរៀនក្នុងថ្នាក់ | 1.97 | 98.76 |
| សិស្សទទួលបានការកែលម្អការគាំទ្រ និងលើកទឹកចិត្ត | 1.98 | 97.70 |
| សិស្សចូលចិត្តសកម្មភាពរៀន និងមានការអភិវឌ្ឍ | 1.96 | 97.35 |

តាមរយៈចម្លើយរបស់សិស្សបង្ហាញថា ពួកគេរៀនតាមរយៈសកម្មភាពមើល និងស្តាប់គ្រូពន្យល់បង្ហាញ រំឭកមេរៀននៅក្នុងថ្នាក់ សិស្សពូកែជួយសិស្សខ្សោយ ការកែលម្អ គាំទ្រ និងលើកទឹកចិត្តហើយពួកគេពេញចិត្តនឹងសកម្មភាពរៀនបែបនេះផងដែរ។

### ៣.១.៣ ការវាយតម្លៃលទ្ធផលសិក្សា

លទ្ធផលសិក្សារបស់សិស្សបានល្អ ឬមិនល្អឆ្លុះបញ្ចាំងពីគុណភាពនៃការបង្រៀន និងរៀន។ លទ្ធផលសិក្សាល្អក៏បញ្ជាក់ពីការប្រឹងប្រែងយកចិត្តដាក់ក្នុងកិច្ចការបង្រៀនរបស់គ្រូផងដែរដូចជា ពង្រឹងចំណេះដឹង ជំនាញ វិធីសាស្ត្របង្រៀន ជាពិសេសការបង្រៀនដែលឆ្លើយតបទៅនឹងតម្រូវការសិស្ស ព្រមទាំងរបៀបវាយតម្លៃការសិក្សាដែលគួរឱ្យជឿជាក់បាន។ ការសិក្សានេះបង្ហាញថា គ្រូមធ្យមសិក្សាទុតិយភូមិវាយតម្លៃ លទ្ធផលសិក្សាតាមរយៈតេស្តខ្លី១៥នាទី សំណួរផ្ទាល់មាត់ កិច្ចការផ្ទះ ប្រឡងប្រចាំខែ ប្រឡងឆមាស និងប្រឡងថ្នាក់ជាតិ (តារាងទី២)។

គ្រូបង្រៀនភាគច្រើនឯកភាពលើ ភាពងាយស្រួលនៃ កម្រិតសំណួរនៅក្នុងរបៀបវាយតម្លៃលទ្ធផលសិក្សាមានន័យថា កម្រិតសំណួរ និងការដាក់ពិន្ទុលើសំណួរដែលបានប្រើប្រាស់នៅក្នុងរបៀបវាយតម្លៃ ខាងលើងាយស្រួល និងសុក្រឹតផងដែរ (មធ្យមភាគសរុប៤.២៥ និង៤.៤២)។ ចំណែកឯសិស្សក៏បានបង្ហាញលទ្ធផលប្រហាក់ប្រហែលគ្នានេះដែរលើកម្រិតសមណួរវាយតម្លៃ (មធ្យមភាគសរុប៤.១៨) និងការដាក់ពិន្ទុលើសំណួរវាយតម្លៃថាសុក្រឹត (មធ្យមភាគសរុប៤.២៧)។

តាមលទ្ធផលនៃការពិភាក្សាក្រុម គ្រូបង្រៀនមានទស្សនៈប្លែកៗគ្នាលើការប្រើប្រាស់កម្រិតសំណួរ និងការដាក់ពិន្ទុនៅក្នុងការប្រឡងថ្នាក់ជាតិនាឆ្នាំកន្លងទៅ។ គ្រូបង្រៀនភាគច្រើនយល់ថាកម្រិតសំណួរសមស្រប និងងាយស្រួល ប៉ុន្តែសំណួរទាំងនោះហាក់ដូចជាមិនស្របតាមកម្មវិធីសិក្សាទេ។ គ្រូបង្រៀនមួយចំនួនបញ្ជាក់ថា ការដាក់ពិន្ទុលើសំណួរនីមួយៗហាក់ដូចជាមិនមានតុល្យភាព និងមិនសូវសុក្រឹតដូចជា សំណួរងាយបានពិន្ទុច្រើនជាងសំណួរពិបាក និងមុខវិជ្ជាខ្លះគ្រូដាក់ពិន្ទុធូរដៃជាង។ ទោះជាយ៉ាងណា ពួកគាត់បានឯកភាព និងទទួលយកលទ្ធផលនៃការប្រឡង។

ដូចនេះ របៀបវាយតម្លៃលទ្ធផលសិក្សាហាក់ដូចជាមិនមានផលប៉ះពាល់លើលទ្ធផលសិក្សារបស់សិស្សឡើយ សូម្បីតែលទ្ធផលប្រឡងថ្នាក់ជាតិ។ ប៉ុន្តែអ្វីគួរឱ្យកត់សម្គាល់នោះអ្នកចូលរួមឆ្លើយគឺជាសិស្សដែលបានប្រឡងធ្លាក់កាលពីឆ្នាំសិក្សាកន្លងទៅ។

តារាងទី២៖ របៀបវាយតម្លៃលទ្ធផលសិក្សា

| | ភាពងាយស្រួលនៃកម្រិតសំណួរវាយតម្លៃ | | | | សុក្រឹតភាពនៃការដាក់ពិន្ទុសំណួរវាយតម្លៃ | | | |
|---|---|---|---|---|---|---|---|---|
| | គ្រូ | | សិស្ស | | គ្រូ | | សិស្ស | |
| | មធ្យមភាគ | % | មធ្យមភាគ | % | មធ្យមភាគ | % | មធ្យមភាគ | % |
| តេស្តខ្លី១៥នាទី | 3.96 | 98.06 | 3.85 | 99.01 | 4.30 | 97.53 | 4.10 | 96.8 |
| សំណួរផ្ទាល់មាត់ | 4.25 | 98.23 | 4.13 | 98.52 | 4.34 | 98.41 | 4.19 | 97.78 |
| កិច្ចការផ្ទះ | 4.26 | 99.12 | 4.24 | 98.52 | 4.28 | 98.94 | 4.26 | 98.03 |
| ប្រឡងប្រចាំខែ | 4.44 | 99.82 | 4.49 | 99.01 | 4.58 | 99.12 | 4.50 | 98.77 |
| ប្រឡងឆមាស | 4.38 | 99.65 | 4.39 | 98.52 | 4.58 | 98.70 | 4.47 | 99.28 |
| ប្រឡងថ្នាក់ជាតិ | 4.23 | 98.76 | 4.01 | 96.31 | 4.44 | 98.06 | 4.16 | 95.57 |
| មធ្យមភាគសរុប | 4.25 | | 4.42 | | 4.18 | | 4.27 | |

### ៣.១.៤ ការលើកទឹកចិត្តគ្រូបង្រៀន

ការលើកទឹកចិត្តគឺជាចលករសំខាន់ក្នុងការជំរុញឱ្យមានសកម្មភាពជាវិជ្ជមានក្នុងការបំពេញការងារ (NEP, 2008; Benveniste et al, 2008)។ ការលើកទឹកចិត្តអាចជារង្វាន់ជាប្រាក់ ឬជាការផ្តល់ឱកាសក្នុងការសិក្សាជំនាញបន្ថែម ការទទួលស្គាល់ស្នាដៃ ការទទួលបានការពេញចិត្តពីសិស្សទទួលបានលទ្ធផលសិក្សាល្អ (Joo et al., 2010)។ ការសិក្សានេះក៏បានផ្តោតលើការផ្តល់ឱកាសឱ្យចូលរួមអភិវឌ្ឍសមត្ថភាព លាភការណ៍ផ្សេងៗ និងការទទួលស្គាល់និងគោរពពីសង្គមសមរម្យ។ តាមរយៈការសិក្សានេះ លទ្ធផលបង្ហាញថា គ្រូនៅមធ្យមសិក្សាទុតិយភូមិស្ទាក់ស្ទើរក្នុងការឯកភាពលើការទទួលបានឱកាសចូលរួមអភិវឌ្ឍសមត្ថភាព ការទទួលបានប្រាក់បន្ថែមសមស្រប ការទទួលបានឋានៈសមរម្យពីមជ្ឈដ្ឋានសង្គម ការទទួលបានការលើកទឹកចិត្តតាមរយៈស្នាដៃបង្រៀន និងការស្រាវជ្រាវ (មធ្យមភាគសរុប ៣.៨៣) (រូបទី៤)។




រូបទី៤៖ របៀបនៃការលើកទឹកចិត្តគ្រូ

តាមលទ្ធផលពិភាក្សាក្រុមគោលដៅក៏បង្ហាញផងដែរថាការលើកទឹកចិត្តគ្រូមានភាពផ្សេងគ្នាទៅលើលក្ខខណ្ឌមួយចំនួនរវាងសាលារៀន។ លទ្ធផលនេះបញ្ជាក់ថាពួកគាត់មិនទទួលបានការណែនាំពីគោលការណ៍លើកទឹកចិត្តបានច្បាស់លាស់ ពីព្រោះពួកគាត់បានលើកឡើងថា «បើសាលារៀនមានគោលការណ៍លើកទឹកចិត្តគ្រូ

ច្បាស់លាស់តាមរូបភាពណាក៏ដោយ ក៏ជាការប្រសើរណាស់សម្រាប់ជួយគ្រូឱ្យចេះសហការគ្នា បង្កើតស្នាដៃមានមោទនភាព ក្នុងការបំពេញការងារប្រកបដោយឆន្ទៈ និងមនសិការ »។ ដូចនេះ ការលើកទឹកចិត្តគ្រូនៅតាមវិទ្យាល័យនៅមានកម្រិតនៅឡើយ ដែលទាមទារឱ្យមានការលើកទឹកចិត្តគ្រូបានសមស្រប មានតម្លាភាព និងយុត្តិធម៌ និងផ្អែកលើគោលការណ៍ច្បាស់លាស់។

### ៣.២ ស្ថានភាពការសិក្សារបស់សិស្ស

#### ៣.២.១. ចំណង់ចំណូលចិត្ត និងរបៀបរៀន

យោងតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា សិស្សនៅមធ្យមសិក្សាទុតិយភូមិត្រូវបានបែងចែក និងតម្រង់ទិសតាមរយៈការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម ដើម្បីឱ្យសិស្សរៀនបានសមស្របតាមសក្តានុពលបញ្ញាពីកំណើត (ឬនិស្ស័យ) តម្រូវការ និងងាយស្រួលក្នុងការជ្រើសរើស និងប្រឡងយកជំនាញនៅថ្នាក់ឧត្តមសិក្សា (អយក., ២០១០) (Slavin, 2009; Woolfolk, 2004)។

ការសិក្សានេះបង្ហាញថាសិស្ស៨៤.៥% ជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និង១៥.៥% ទៀតជ្រើសរើសថ្នាក់វិទ្យាសាស្ត្រសង្គម។ ក្នុងចំណោមមុខវិជ្ជាគោលទាំងពីរ (អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា) សិស្សភាគច្រើន (៦៧.៤%) ចូលចិត្តមុខវិជ្ជាអក្សរសាស្ត្រខ្មែរជាង បើធៀបនឹងមុខវិជ្ជាគណិតវិទ្យា(៥២.៨%)។ ជាងនេះទៅទៀត ក្នុងចំណោមមុខវិជ្ជាវិទ្យាសាស្ត្រទាំងអស់ សិស្សចូលចិត្តមុខវិជ្ជាពីរជាងគេ គឺជីវវិទ្យា(៦៣.២%) និងគីមីវិទ្យា(៥៥.៨%) ហើយមុខវិជ្ជាវិទ្យាសាស្ត្រសង្គម សិស្ស៥៣.៣% ចូលចិត្តមុខវិជ្ជាប្រវត្តិវិទ្យា (រូបទី៥)។




រូបទី៥៖ មុខវិជ្ជាដែលសិស្សចូលចិត្ត

ករណីនេះអាចបញ្ជាក់បានថា ទោះបីជាសិស្សភាគច្រើនជ្រើសរើសថ្នាក់វិទ្យាសាស្ត្រក៏ដោយ ប៉ុន្តែពួកគាត់មិនសូវចូលចិត្តមុខវិជ្ជាវិទ្យាសាស្ត្រទេ សូម្បីតែមុខវិជ្ជាគោលគណិតវិទ្យា។ ជាងនេះទៅទៀត ពួកគាត់ភាគច្រើនចូលចិត្តមុខវិជ្ជាអក្សរសាស្ត្រ និងប្រវត្តិវិទ្យា។ នេះប្រហែលមកពីមុខវិជ្ជាប្រវត្តិវិទ្យាត្រូវបានជ្រើសរើសជាមុខវិជ្ជាប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់វិទ្យាសាស្ត្រ។

ម្យ៉ាងទៀត របៀបរៀនរបស់សិស្សក៏ជាចំណែកមួយដែលជួយឱ្យ សិស្សរៀនបានលទ្ធផលល្អផងដែរ។ សិស្សម្នាក់ៗមានរបៀបរៀនដោយឡែកពីគ្នា។ សិស្សខ្លះចូលចិត្តរៀនតាមរយៈការស្តាប់ ឬមើលកត់ត្រា និងបកស្រាយពន្យល់។ ករណីនេះទាមទារឱ្យគ្រូប្រើប្រាស់មធ្យោបាយ ឬវិធីសាស្ត្រផ្សេងៗ ដើម្បីជំរុញទឹកចិត្តឱ្យចូលរួមសកម្មភាពរៀនយ៉ាងសកម្ម (Slavin, 2006)។ តាមរយៈការសិក្សានេះ សិស្សបានបង្ហាញថា នៅក្នុងម៉ោងរៀនស្ទើរតែគ្រប់មុខវិជ្ជា គ្រូទម្លាប់សិស្សឱ្យរៀនតាមរបៀប ដូចជា មើល និងស្តាប់គ្រូពន្យល់បង្ហាញ ធ្វើការជាបុគ្គល បកស្រាយពន្យល់អំពីខ្លឹមសារនៃការពិភាក្សារបស់ខ្លួន និងរំឭកមេរៀននៅក្នុងថ្នាក់រៀន ជាជាងឱ្យសិស្សបង្កើតសម្មតិកម្ម រៀបចំការពិសោធន៍ ពិភាក្សាជាដៃគូ ក្រុមតូច ឬក្រុមធំ និង

ទាញទំនាក់ទំនងរវាងខ្លឹមសារមេរៀននឹងការរស់នៅក្នុងជីវភាពប្រចាំថ្ងៃ។

ដោយឡែកនៅគ្រប់មុខវិជ្ជា សិស្សខ្សោយមានឱកាសចូលរួមសកម្មភាពរៀនក្នុងថ្នាក់ ទទួលបានការកែលម្អ ការគាំទ្រ និងលើកទឹកចិត្ត និងសិស្សពូកែជួយសិស្សខ្សោយ។ ម្យ៉ាងទៀត សិស្សបានបញ្ជាក់ថែមថា ក្នុងមួយថ្ងៃ ពួកគាត់ចំណាយពេលសិក្សា នៅសាលារៀនជាមធ្យមប្រហែលពី៦ទៅ៧ម៉ោង និងចំណាយពេលស្វ័យសិក្សាជាមធ្យមជាង១ម៉ោង៣០នាទីជារៀងរាល់ថ្ងៃរួមទាំងនៅពេលគ្រូតាមមុខវិជ្ជាអវត្តមានម្តងម្កាលផងដែរ។ ដូចនេះ ទាំងចំណង់ចំណូលចិត្ត របៀបរៀន និងការចំណាយពេលវេលាសម្រាប់ស្វ័យសិក្សារបស់សិស្ស ហាក់មិនគាំទ្រ និងជំរុញឱ្យលទ្ធផលសិក្សាថ្នាក់វិទ្យាសាស្ត្របានប្រសើរឡើយ។

### ៣.២.២ កត្តាជះឥទ្ធិពលលើការសិក្សា

លទ្ធផលនៃការសិក្សា (ប្រឡងធ្លាក់) អាចបណ្តាលមកពីកត្តាអ្វីផ្សេងទៀត ដូចជា គ្រូ សិស្ស និងការស្វ័យគ្រប់គ្រងវិន័យ ជាដើម។ ការដែលសិស្សរៀនដោយមិនយល់ពីវត្ថុបំណងនៃការបង្រៀន និងអត្ថប្រយោជន៍នៃមេរៀន គ្រូមិនប្រឹងប្រែងបង្រៀនអស់ពីសមត្ថភាព និងទេពកោសល្យក្នុងការបង្រៀន ការខ្វះយកចិត្តទុកដាក់លើការសិក្សា និងការគ្រប់គ្រងវិន័យ នៅក្នុងម៉ោងបង្រៀន ព្រមទាំងការវាយតម្លៃមិនយុត្តិធម៌ និងការដាក់ពិន្ទុមិនមានតម្លាភាព សុទ្ធតែចូលរួមចំណែក ឬមានផលប៉ះពាល់មកលើការសិក្សាទាំងអស់ (Richard & David. 2008; Cubukcu, 2010)។

ការស្រាវជ្រាវនេះបង្ហាញថា សិស្សជាង៩៨%មិនសូវយល់ពីវត្ថុបំណងនៃការបង្រៀនរបស់គ្រូ មិនសូវយល់ពីអត្ថប្រយោជន៍នៃមេរៀន គ្រូរបស់ពួកគេប្រឹងប្រែងបង្រៀនប៉ុន្តែមិនអស់ពីសមត្ថភាព និងទេពកោសល្យ ហើយពួកគាត់ក៏មិនសូវយកចិត្តទុកដាក់លើការសិក្សារបស់សិស្សដែរ ព្រមទាំងការគ្រប់គ្រងវិន័យ ក្នុងថ្នាក់រៀនរបស់គ្រូនៅមានកម្រិតឡើយ ឧទាហរណ៍ដូចជា គ្រូនៅឱ្យសិស្សមួយចំនួនអាចលួចចម្លងសំណៅឯកសារផ្សេងៗ បាននៅឡើយ។ លើសពីនេះទៀត សិស្សអវត្តមានភាគច្រើននៅមានសិទ្ធប្រឡង បើទោះជាការដាក់ពិន្ទុរបស់គ្រូលើសំណួរវាយតម្លៃរបស់សិស្សបង្ហាញថា មានតម្លាភាព និងយុត្តិធម៌។ ជាងនេះទៀត សិស្សទាំងអស់នេះមានសង្ឃឹមយ៉ាងខ្លាំងថាតាមការសិក្សាឡើងវិញ នៅក្នុងឆ្នាំសិក្សាថ្មីនេះនឹងធ្វើឱ្យពួកគេប្រឡងជាប់ជាស្ថាពរ (រូបទី៦)។




រូបទី៦៖ កត្តាជះឥទ្ធិពលលើការសិក្សា

ដូចនេះ សិស្សភាគច្រើន (ជាង៩៨%) ហាក់បង្ហាញភាពមិនច្បាស់លាស់ថាកត្តាទាំងអស់ខាងលើបានមានឥទ្ធិពលលើការសិក្សារបស់ពួកគេ (មធ្យមភាគសរុប ២.៧៩)។

### ៣.៣ ស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាល

ជាទូទៅ គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិត្រូវទទួលបានការហ្វឹកហាត់បំប៉នសមត្ថភាពទាំងឯកទេស វិធីសាស្ត្រ និងគរុកោសល្យក្នុងការបង្រៀនពីគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដែលមានការទទួលស្គាល់ដោយក្រសួងអប់រំ

យុវជន និងកីឡា។ ហេតុនេះ គុណភាពនៃការបង្រៀនរបស់គ្រូ ក៏ជាចំណែកមួយជាប់ពាក់ព័ន្ធនឹងស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាល គ្រូមធ្យមសិក្សាទុតិយភូមិផងដែរ។ តាមលទ្ធផលនៃកម្រងសំណួរ និងការពិភាក្សាក្រុមគោលដៅ បង្ហាញថា គ្រូមធ្យមសិក្សាទុតិយភូមិភាគច្រើនឯកភាពលើកម្មវិធីបណ្តុះបណ្តាល កម្រិតសមត្ថភាពគ្រូឧទ្ទេស គុណភាព ប្រសិទ្ធភាព ការដឹកនាំ និងការគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធ របស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ (តារាងទី៣)។

តារាងទី៣៖ ស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

| ស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ | មធ្យមភាគសរុប |
|---|---|
| កម្មវិធីបណ្តុះបណ្តាល | 4.03 |
| សមត្ថភាពគ្រូឧទ្ទេស | 4.13 |
| គុណភាពប្រសិទ្ធភាពការដឹកនាំ និងការគ្រប់គ្រង | 4.05 |
| ហេដ្ឋារចនាសម្ព័ន្ធ | 3.15 |

*សម្គាល់៖ (១)មិនឯកភាពទាំងស្រុង (២)មិនឯកភាព (៣)មិនច្បាស់លាស់ (៤)ឯកភាព (៥)ឯកភាពទាំងស្រុង*

ពួកគាត់យល់ឃើញថា កម្មវិធីបណ្តុះបណ្តាលមានប្រយោជន៍សម្រាប់ការបង្រៀននិងរៀន រយៈពេលបណ្តុះបណ្តាល និងកម្មសិក្សាប្រតិបត្តិគរុកោសល្យសមស្រប ព្រមទាំងមានការពង្រឹងសមត្ថភាព តាមរយៈការបំប៉នបន្ថែមលើចំណេះដឹងស្តីពីការអប់រំ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព (ESD) ដ៏មានប្រយោជន៍ផងដែរ។ ចំពោះសមត្ថភាពគ្រូឧទ្ទេស ពួកគាត់យល់ឃើញថាគ្រូឧទ្ទេសមានគុណវុឌ្ឍិខ្ពស់ មានសមត្ថភាពពេញលេញលើមុខវិជ្ជាឯកទេស និងវិធីសាស្ត្របង្រៀនគ្រប់គ្រាន់។ លើសពីនេះទៀត ចំពោះគុណភាព ប្រសិទ្ធភាព ដឹកនាំ និងការគ្រប់គ្រង ពួកគាត់យល់ឃើញថា ការរៀបចំប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃ ការរៀបចំតារាងបញ្ជីធ្វើអធិការកិច្ច ការចុះត្រួតពិនិត្យតាមដាននិងវាយតម្លៃកម្មសិក្សាប្រតិបត្តិគរុកោសល្យ ការលើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រង ការលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ និងការដោះស្រាយទំនាស់មានតម្លាភាព និងយុត្តិធម៌ មានគុណភាពទទួលយកបាន។ ប៉ុន្តែពួកគាត់បង្ហាញពីភាពមិនច្បាស់លាស់លើការធ្វើអធិការកិច្ចកម្មសិក្សាប្រតិបត្តិគរុកោសល្យនៅតាមសាលារៀន ការអនុវត្តច្បាប់ស្តីពីកំណែទម្រង់ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងការរៀបចំ និងការពង្រឹងប្រព័ន្ធនៃការលើកទឹកចិត្តគ្រូឧទ្ទេស ប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌យ៉ាងណានោះទេ។ ពួកគាត់បានលើកឡើងថា «ការវាយតម្លៃលទ្ធផលនៃការបណ្តុះបណ្តាលគ្រូកម្រិតឧត្តម មានលក្ខណៈសមស្រប ប៉ុន្តែមិនទាន់សុក្រឹតនៅឡើយ»។ លើសពីនេះ ពួកគាត់បន្ថែមទៀតថា «មានភាពស៊ីសង្វាក់គ្នារវាងការងារ ប៉ុន្តែការសម្របសម្រួលការងារមិនសូវល្អ ដូចជា បុគ្គលិកការិយាល័យមួយចំនួនមិនផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់អតិថិជន ផ្តល់សេវាមិនទាន់ពេលវេលា និងមានពាក្យសំដីមិនសមរម្យ ជាដើម។

បន្ថែមលើនេះ ពួកគាត់ភាគច្រើនក៏បង្ហាញភាពមិនច្បាស់លាស់លើផ្នែកហេដ្ឋារចនាសម្ព័ន្ធ របស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិថា មានភាពគ្រប់គ្រាន់ ឬយ៉ាងណានោះទេ ដូចជា បន្ទប់ទឹក និងមានបង្គន់អនាម័យ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រប្រកបដោយសម្ភារបរិក្ខារគ្រប់គ្រាន់ ព្រមទាំងបណ្ណាល័យមានសៀវភៅគ្រប់គ្រាន់សម្រាប់បម្រើការស្រាវជ្រាវ ពីព្រោះពួកគាត់ប្រហែល ៥០%មិនធ្លាប់ បានឆ្លងកាត់ការបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូកម្រិតឧត្តម សម្រាប់បម្រើការនៅសាលារៀនមធ្យមសិក្សាទុតិយភូមិបច្ចុប្បន្ននេះទេ។ ពួកគាត់តាមក្រុមគោលដៅមួយចំនួនបានលើកឡើងថា «ទោះជាហេដ្ឋារចនាសម្ព័ន្ធ របស់គ្រឹះស្ថានបណ្តុះបណ្តាលនេះល្អសមរម្យតែមិនទាន់គ្រប់គ្រាន់នៅឡើយ ហើយពួកគាត់បានសំណូមពរថា គួរតែបន្ថែមកន្លែងស្នាក់នៅសម្រាប់គរុនិស្សិត និងធ្វើបន្ទប់រៀនទាំងអស់ឱ្យកាន់តែមានផាសុខភាព»។

ជារួម ស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម អាចបង្កលក្ខណៈងាយស្រួលក្នុងការបណ្តុះបណ្តាលគ្រូ ទាំងសមត្ថភាពចំណេះដឹង ជំនាញ ក្នុងការបង្រៀនប្រកបដោយគរុកោសល្យ។

## ៤. សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះ វិភាគគុណភាពនៃការបង្រៀនរបស់គ្រូមធ្យមសិក្សាទុតិយភូមិ តាមរយៈការពិនិត្យមើលស្ថានភាពគ្រូកំពុងបង្រៀនថ្នាក់ទី១២ និងសិស្ស

រៀនត្រួតថ្នាក់ទី១២ ព្រមទាំងកត្តាជះឥទ្ធិពលលើការសិក្សារបស់ពួកគាត់។ ការសិក្សានេះបានបង្ហាញថាស្ថានភាពនៃការបំពេញកិច្ចការរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិមិនទាន់មានកម្រិតប្រសើរឡើយ ដោយសារការបំប៉នសមត្ថភាពវិជ្ជាជីវៈ មានចំនួនតិចតួច (០.៥ដងក្នុង១ឆ្នាំ) និងមិនឆ្លើយតបតាមជំនាញដែលពួកគាត់ត្រូវការ ជាពិសេស គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។ ការប្រជុំបច្ចេកទេសពិតជាមានសារៈសំខាន់សម្រាប់ជួយពង្រឹងសមត្ថភាពបង្រៀន ប៉ុន្តែដំណើរការនៃការប្រជុំមិនច្បាស់លាស់ ដោយសារមិនបានបញ្ជាក់ពីវត្ថុបំណងនៃការប្រជុំ ព្រមទាំងមិនបានធ្វើជាប្រចាំតាមផែនការ។ ដោយសារការលើកទឹកចិត្តនៅមានកម្រិត ការបង្រៀន និងរៀននៅមានលក្ខណៈបែបទម្លាប់ ការបង្រៀនច្រើនកម្រិតថ្នាក់គ្រូត្រូវចំណាយពេលវេលាច្រើន ដើម្បីធ្វើកិច្ចតែងការបង្រៀន និងរៀបចំ ឬផលិតសម្ភារបង្រៀននិងរៀនតាមគ្រប់កម្រិតថ្នាក់។ ចំណែកឯរបៀបវាយតម្លៃលទ្ធផលសិក្សាហាក់ដូចជា មិនមានផលប៉ះពាល់លើលទ្ធផលសិក្សារបស់សិស្សឡើយ សូម្បីតែលទ្ធផលប្រឡងថ្នាក់ជាតិ។ ចំណុចគួរឱ្យកត់សម្គាល់នោះអ្នកចូលរួមឆ្លើយគឺជាសិស្ស ដែលបានប្រឡងធ្លាក់កាលពីឆ្នាំសិក្សាកន្លងទៅ ហើយពួកគាត់ភាគច្រើន (ជាង៩៨%) បង្ហាញថាកត្តាទាំងអស់មិនសូវជះឥទ្ធិពលលើការសិក្សារបស់សិស្សឡើយ។

ផ្នែកស្ថានភាព គ្រឹះស្ថានបណ្តុះបណ្តាលគ្រូកម្រិតឧត្តមមានលក្ខណៈសមស្រប និងទទួលស្គាល់នៅក្នុងបរិបទប្រទេស (មធ្យមភាគ=៤.០)។ ផ្នែកអធិការកិច្ចកម្មសិក្សាប្រតិបត្តិគរុកោសល្យ ការអនុវត្តច្បាប់ស្តីពីកំណែទម្រង់ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងការពង្រឹងប្រព័ន្ធ នៃការលើកទឹកចិត្តគ្រូឧទ្ទេសមានភាពមិនច្បាស់លាស់។

## ៥. សំណូមពរ

យោងតាម របកគំហើញនៃការសិក្សាស្រាវជ្រាវនេះ មានបញ្ហាមួយចំនួនត្រូវយកចិត្តទុកដាក់ ដូចជា៖

- ការផ្តល់វគ្គបំប៉នសមត្ថភាពគ្រូ ឱ្យត្រូវតាមជំនាញ និងតម្រូវការ។
- មុនពេលផ្តល់វគ្គបំប៉ន ត្រូវវាយតម្លៃតម្រូវការទៅតាមកម្រិតរបស់អ្នកអនុវត្ត។
- គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម គួរតែត្រូវបានយកចិត្តទុកដាក់ ក្នុងការផ្តល់វគ្គបំប៉នលើផ្នែកវិធីសាស្ត្របង្រៀនបែបទំនើប ដើម្បីឱ្យពួកគាត់អាចបង្រៀន ដោយអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលបានជោគជ័យ។
- ការប្រជុំបច្ចេកទេស ដែលបានលទ្ធផលល្អគួរតែធ្វើឡើងតាមផែនការ វត្ថុបំណង និងរបៀបវារៈប្រជុំច្បាស់លាស់។
- កត្តាលើកទឹកចិត្តគ្រូបង្រៀន គួរត្រូវបានយកមកពិចារណាជារបៀបវារៈមួយយ៉ាងសំខាន់។ ការលើកទឹកចិត្តគួរធ្វើ ឡើងតាមគោលការណ៍ច្បាស់លាស់ ដើម្បីជំរុញសកម្មភាពចូលរួមបំពេញការងាររបស់គ្រូឱ្យមានប្រសិទ្ធភាព។
- ស្ថានភាពគ្រឹះស្ថាន បណ្តុះបណ្តាលគ្រូកម្រិតឧត្តមទោះជាមានលក្ខណៈសមស្របក៏ដោយ ក៏គួរយកចិត្តទុកដាក់ ទៅលើការបម្រើសេវាអតិថិជន ជាពិសេសគួរតែយកចិត្តទុកដាក់លើការធ្វើអធិការកិច្ចកម្មសិក្សាប្រតិបត្តិគរុកោសល្យ ឱ្យមានភាពច្បាស់លាស់។

## ៦. ឯកសារយោង


1. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ. (២០១៤-២០១៥). របាយការណ៍ស្តីពីលទ្ធផលប្រឡងមធ្យមសិក្សាទូទាំងប្រទេស. ភ្នំពេញ: អ យ ក.
2. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ. (២០១៥-២០១៦). របាយការណ៍ស្តីពីលទ្ធផលប្រឡងមធ្យមសិក្សាទូទាំងប្រទេស . ភ្នំពេញ: អ យ ក.
3. អ យ ក, . (២០១៣). គោលនយោបាយស្តីពីគ្រូបង្រៀន. ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា.
4. Anton, G. D. (2009). Without Capacity, there is no development. Paris: IIEP- UNESCO.
5. Benveniste L., MarshallJ., & Araujo M. Caridad. (2008). Teaching in Cambodia. Phnom Penh: world Band & Moeys.
6. Boyd D., Lankford H., Leob s., Ronfeldt S., & Wyckoff J. (2011). The Role of Teacher Quality in Retention and Hiring: Using Applications to Transfer to Uncover

Preferences of Teachers and Schools. Journal of Policy Analysis and Management, 97-99.

7. Education, D. o. (2016). National Examination result of Grade 12 2015-16. Phnom Penh: Moeys.
8. Forum, w. (2016). Education 2030 Incheon Declearation. Incheon: Republic of Korea.
9. Gannicott. (2009). Secondary Teacher Policy Research in Asia: Teacher Number, Teacher Quality: leson from Secondary Education in Asia. Bangkok: UNESCO Bangkok.
10. Joo Hyun-Jun , Lee Ssang-cheol , Jung Sung-soo. (2010). Performance-based reward for teachers: teacher's perception of their motivation. Research In Higher Education Journal, 1-9.
11. Lankford H., Loeb S., & Wyckoff J. (2002). Teacher Sorting and the Plight of Urban Schools:A Descriptive Analysis. Educational Evaluation and Policy Analysis, pp. 37-62.
12. Mohan Menon K. Rama K., LakshmiT. K. S., & Bhat Vasant D. (2007). Quality Indicators For Teacher Education. Nagarabhabai Bangalore,: National Printing Press.
13. NEP. (2008). Teaching Matters: A policy report on the motivation and morale of teacher in Cambodia. Phnom Penh: NEP & VSO.
14. OECD. (September, 2011). Teachers Matter: Attracting, Developing and Retraining Effective teachers; Pointers for policy development. Directorate for Education, Education and Training policy Devision, 1-18.
15. Slavin Robert E. (2006). Educational Psychology: Theory and Practice. New York: Pearson Education. Inc.
16. UNESCO. (2015-2016). Teaching and Learning: achieving the quality of education for all. Paris; France: 2014.
17. Wan Guofang & Gut Dannie M. (2011). Bringing Schools into the 21st century. Exploration of Education Purpose, 113.
18. Woolfolk A., (2004) *Educational Psychology.* Pearson Education, In

# កត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស ផ្នែកគណិតវិទ្យា និង វិទ្យាសាស្ត្រនៅមធ្យមសិក្សាទុតិយភូមិក្នុងប្រទេសកម្ពុជា


សិត សេង សាំង សុចិន្តា លុយ អោក ចេង ថុន គឹម លាង ថៃ ហេង គឹម ចំរើនវុឌ្ឍី ស៊ឹម វិសុទ្ធ ឈឹម ភារី យាង ប៉េងលី

វិទ្យាស្ថានជាតិអប់រំ

សារអេឡិចត្រូនិចទំនាក់ទំនង៖ setseng2014@gmail.com



***មូលន័យសង្ខេប៖*** *ការស្រាវជ្រាវនេះ នឹងបង្ហាញឱ្យឃើញពីកត្តាទាំងឡាយដែលជះឥទ្ធិពលទៅលើលទ្ធផលសិក្សារបស់សិស្ស។ ការសិក្សានឹងផ្តោតទៅលើសិស្សថ្នាក់ទី១២ និងលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ដែលជាមុខវិជ្ជាសំខាន់ និងកំពុងត្រូវបានទទួលការយកចិត្តទុកដាក់ពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡានៃប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសក្នុងតំបន់ និងសាកលលោក។ ទិន្នន័យដែលបានប្រមូលពីសិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនជាច្រើននៅក្នុងប្រទេសកម្ពុជាតាមរយៈការបំពេញកម្រងសំណួរ ការសម្ភាស និងការសិក្សាលើឯកសារផ្សេងៗទៀតត្រូវបានវិភាគ រកមើលពីទំនាក់ទំនងរវាងលទ្ធផលសិក្សារបស់សិស្ស ជាមួយនឹងកត្តាពាក់ព័ន្ធផ្សេងៗដូចជាកត្តាសាលារៀន កត្តាគ្រូបង្រៀន កត្តាគ្រួសារ កត្តាសិស្សខ្លួនឯង និងកត្តាសង្គម។ ជារួមលទ្ធផលស្រាវជ្រាវបានបង្ហាញថា លទ្ធផលសិក្សារបស់សិស្សពិតជាមានទំនាក់ទំនងគ្នាយ៉ាងច្បាស់លាស់ជាមួយនឹងកត្តាមួយចំនួនទាំងនោះដូចជាកត្តាគ្រូ កត្តាសាលារៀន និងកត្តាសិស្សខ្លួនឯង។ ចំណែកឯកត្តាមួយចំនួនផ្សេងទៀតដូចជាកត្តាជីវភាពគ្រួសារ កត្តាចំណេះដឹងឪពុកម្តាយ និងកត្តាមជ្ឈដ្ឋានរស់នៅរបស់សិស្សពុំឃើញមានឥទ្ធិពលទៅដល់លទ្ធផលសិក្សារបស់សិស្សទេ។*



***ពាក្យគន្លឹះ៖*** *៖ កត្តាសិក្សា លទ្ធផលសិក្សារបស់សិស្ស មុខវិជ្ជាគណិតវិទ្យា មុខវិជ្ជាវិទ្យាសាស្ត្រ*


## ១.សេចក្តីផ្តើម

មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រត្រូវបានគេគិតថាជាមុខវិជ្ជាស្នូលក្នុងការបណ្តុះធនធានមនុស្ស សម្រាប់អភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន។ នេះគឺដោយសារការអប់រំគណិតវិទ្យា និងវិទ្យាសាស្ត្រដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពជំនាញជាក់លាក់ដល់អ្នកសិក្សា នៅក្នុងសង្គមបច្ចេកវិទ្យា ដែលកំពុងមានការវិវត្តយ៉ាងលឿនក្នុងពេលបច្ចុប្បន្ននេះ (Ginns & Watter, 1995[១]; Watter & Ginns, 2000[២])។ លោក McGinn និងRoth(1999)[៣] បានបញ្ជាក់យ៉ាងច្បាស់ថា បើការរៀបចំ និងគាំទ្រការអប់រំ គណិតវិទ្យា និងវិទ្យាសាស្ត្រប្រកបដោយលក្ខខណ្ឌសិក្សាល្អ នោះអ្នកសិក្សាអាចទទួលបាននូវចំណេះដឹងដ៏ប្រសើរបំផុត និងអាចបកស្រាយបានយ៉ាងល្អស្តីពីបាតុភូតធម្មជាតិ និងបាតុភូតវិទ្យាសាស្ត្រទាំងឡាយ ព្រមទាំងអាចអភិវឌ្ឍបំណិនដោះស្រាយបញ្ហាសម្រាប់ការរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេប្រកបដោយសុខដុមរមនា និងមានការរីកចម្រើន។

ទោះជាយ៉ាងណាក៏ដោយ មានការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា គុណភាពនៃការសិក្សារបស់សិស្សនៅប្រទេសកម្ពុជា ជាពិសេសលើមុខវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រ គឺស្ថិតនៅកម្រិតមួយទាបនៅឡើយ បើធៀបទៅនឹងកម្រិត ស្តង់ដាអន្តរជាតិឬធៀបជាមួយនឹងប្រទេសក្នុងតំបន់។ កាលពីឆ្នាំ ២០០១អង្គការ UNESCO[៤]បានរកឃើញលទ្ធផលដូចទៅនឹងលោក Neth Barom និងលោក Wakabayashi (១៩៩៩)[៥] ដែលបង្ហាញថាសិស្សនិស្សិតវិទ្យាសាស្ត្រ និងគណិតវិទ្យាជាច្រើនដែលបានបញ្ចប់ការសិក្សារបស់គេ នៅក្នុងប្រព័ន្ធអប់រំនៃប្រទេសកម្ពុជា គឺនៅពុំទាន់មានចំណេះដឹង និងបំណិនច្បាស់លាស់សម្រាប់អនុវត្តការងាររបស់ពួកគេនៅឡើយ។ នៅឆ្នាំ ២០០៣ លោកស្រី Maeda Mitsuko[៦]បានបន្តវាស់សមត្ថ

ភាពនិស្សិតផ្នែកគីមីវិទ្យានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយប្រើប្រាស់តេស្តស្តង់ដាអន្តរជាតិ ដែលខ្លឹមសារតេស្ត មានកម្រិតត្រឹមតែអនុវិទ្យាល័យ។ លទ្ធផលក៏បានបង្ហាញស្រដៀងគ្នាដែរថា និស្សិតដែលបានចូលរួមធ្វើតេស្តទាំងនោះមិនទទួលបានពិន្ទុខ្ពស់ជាទីពេញចិត្តនៅឡើយ។

កម្រិតទាបនៃលទ្ធផលសិក្សារបស់និស្សិត ដែលបានរក ឃើញដោយអ្នកស្រាវជ្រាវដូចរៀបរាប់ខាងលើ ធ្វើឱ្យមានមន្ទិលសង្ស័យថា វាបណ្តាលមកពីពួកគេពុំមានមូលដ្ឋានគ្រឹះរឹងមាំពីថ្នាក់ក្រោមៗមក។ ពួកគេអាចរៀនខ្សោយតាំងពីនៅកម្រិតបឋមសិក្សា ឬកម្រិតមធ្យមសិក្សាមកម្ល៉េះ។ បញ្ហានេះ គឺអាចបណ្តាលមកពីសមត្ថភាពគ្រូបង្រៀននៅកម្រិតក្រោមៗ នៅមានកម្រិតទាបនៅឡើយ។ ដូច្នេះបានជានៅក្នុងឆ្នាំ ២០០៩ អ្នកស្រាវជ្រាវ និងក្រុមការងាររបស់គម្រោង STEPSAM2⁽⁷⁾ បានធ្វើតេស្តស្ទាបស្ទង់មួយផ្សេងទៀត ដើម្បីវាស់សមត្ថភាពវិទ្យាសាស្ត្ររបស់គ្រូ វិទ្យាសាស្ត្រនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ។ ការស្រាវជ្រាវនេះបានបង្ហាញច្បាស់ថា គ្រូឧទ្ទេសនៅតាមសាលាបណ្តុះបណ្តាលគ្រូក្នុងប្រទេសកម្ពុជា ព្រមទាំងគរុសិស្សដែលនឹងចេញទៅធ្វើជាគ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យនៅមានចំណេះដឹង និងជំនាញវិទ្យាសាស្ត្រទាបនៅឡើយ។ លោក Walle, Uon, Cnudde និង Keo (2010)(៨) និងលោក Chantha (2013)(៩) ក៏បានរកឃើញលទ្ធផលស្រដៀងគ្នានេះផងដែរ។

ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា ជាពិសេសការអប់រំគណិតវិទ្យា និងវិទ្យាសាស្ត្រ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការដៃគូអភិវឌ្ឍមួយចំនួនដូចជា JICA/STEPSAM, VVOB, និង VSO ជាដើម ដើម្បីរៀបចំសម្ភារបង្រៀន និងរៀន ធ្វើការបណ្តុះបណ្តាលដល់គ្រូបង្រៀននូវជំនាញធ្វើពិសោធ និងវិធីសាស្ត្របង្រៀន ចាប់តាំងពីកំឡុងឆ្នាំ២០០០មក។ លើសពីនេះ ក្រសួងបានកំពុងដំណើរការកំណែទម្រង់លើ ១៥ ចំណុច ដែលក្នុងនោះមានការកែលម្អកម្មវិធីសិក្សា សៀវភៅសិក្សា សាងសង់អាគារសិក្សា និងសាលាធនធានដែលមានមន្ទីរពិសោធវិទ្យាសាស្ត្រ និងបានបំពាក់សម្ភារពិសោធនៅតាមសាលារៀនកម្រងគ្រប់រាជធានី-ខេត្ត និងបន្តលើកកម្ពស់សមត្ថភាពគ្រូបង្រៀនតាមរយៈកម្មវិធីវិក្រឹតការគ្រូបង្រៀន ជាបន្តបន្ទាប់ក្រោមការគាំទ្រថវិការបស់រដ្ឋ និងរបស់ដៃគូអភិវឌ្ឍនានា។នៅក្នុងឆ្នាំ២០១៦នេះ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកំណែទម្រង់របស់ខ្លួន ដោយបានបង្កើតឱ្យមានគោលនយោបាយលើកកម្ពស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាហៅកាត់ថា STEM (Science Technology Engineering and Mathemathics)។

ទោះបីជាយ៉ាងនេះក្តី គុណភាពនៃការអប់រំហាក់នៅមិនទាន់បានប្រសើរឡើងជាងមុនប៉ុន្មានទេ។ បើតាមលទ្ធផលស្រាវជ្រាវរបស់លោក Set. S.នៅឆ្នាំ ២០១៥(១០)ថ្មីៗនេះបានបង្ហាញថា សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាបឋមភូមិប្រមាណត្រឹមតែ៣១.៩៥%ប៉ុណ្ណោះ ដែលអាចឆ្លើយសំណួរតេស្តស្តង់ដាអន្តរជាតិ (TIMMS-2011) លើមុខវិជ្ជាគីមីវិទ្យាបានល្អ។ បើទោះបីជាលទ្ធផលនេះបានបង្ហាញនូវកម្រិតប្រហាក់ប្រហែលគ្នា ជាមួយនឹងប្រទេសជិតខាងដូចជាប្រទេសថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ីក៏ដោយ ប៉ុន្តែវានៅមានកម្រិតទាបជាងខ្លាំងបើប្រៀបធៀបនឹងមធ្យមភាគក្នុងតំបន់ និងអន្តរជាតិ។ លទ្ធផលនេះប្រហាក់ប្រហែលគ្នាទៅនឹងលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរបស់ក្រសួងអប់រំ យុវជន និងកីឡាកាលពីឆ្នាំ ២០១៥ កន្លងទៅដែលបានបង្ហាញថា ក្រុមសិស្សវិទ្យាសាស្ត្រទទួលបានពិន្ទុជាប់មធ្យមភាគត្រឹមតែ ២៥.៩២% សម្រាប់មុខវិជ្ជាគណិត វិទ្យា ៦១.១៥% សម្រាប់មុខវិជ្ជារូបវិទ្យា ៥៦.៥៩%សម្រាប់មុខវិជ្ជាគីមីវិទ្យា និង ៤៤.៨៤% សម្រាប់មុខវិជ្ជាជីវវិទ្យាហើយបើគិតជារួមសិស្សប្រឡងជាប់ត្រឹមតែជាង៥០% និងនៅក្នុងឆ្នាំ២០១៦នេះសិស្សប្រឡងជាប់បានកើន ឡើងជាងពីឆ្នាំមុនបន្តិចគឺត្រឹមតែជាង៦០%ប៉ុណ្ណោះ(១១)។ លទ្ធផលតេស្តស្តង់ដាថ្នាក់ទី៨ នៅក្នុងដើមឆ្នាំ២០១៦ថ្មីៗនេះរបស់នាយកដ្ឋានធានាគុណភាពអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡាក៏បានបង្ហាញលទ្ធផលស្រដៀងគ្នានេះដែរ ដែលមានសិស្សត្រឹមតែ ៤៤.00% សម្រាប់មុខវិជ្ជាគណិត វិទ្យា និង ៥២.៧0% សម្រាប់មុខវិជ្ជារូបវិទ្យាប៉ុណ្ណោះដែលអាចមានពិន្ទុចាប់ពីមធ្យមភាគឡើង(១២)។

បើយោងតាមលទ្ធផលស្រាវជ្រាវ និងលទ្ធផលដែលបានបង្ហាញដោយក្រសួងអប់រំ យុវជន និងកីឡា ដូចបានរៀបរាប់ខាងលើ ប្រទេសកម្ពុជាអាចនឹងជួបបញ្ហាប្រឈមផ្នែកធនធានមនុស្សជាពិសេសនៅពេលសមាហរណកម្មអាស៊ានត្រូវបានអនុវត្តពេញលេញនាពេលដ៏ខ្លីខាងមុខ។ ជាងនេះទៅទៀត ប្រទេសកម្ពុជានៅត្រូវការធនធានមនុស្សប្រកបដោយគុណភាពជាចាំបាច់ ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលដែលបានកំណត់ថា នឹងប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ចាប់ពីឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០[១៣]។

មានការលើកឡើងក្រៅផ្លូវការជាច្រើន បានបញ្ចេញទស្សនៈថា សិស្សកម្ពុជាដែលរៀនពូកែ និងសិស្សដែលរៀនខ្សោយគឺបណ្តាលមកពីកត្តាជាច្រើន។ អ្នកខ្លះយល់ថាវាបណ្តាលមកពីកត្តាសង្គមខ្លះថាមកពីកត្តាសាលារៀនខ្លះថាមកពីកត្តាគ្រួសារ និងខ្លះទៀតថាមកពីកត្តាខ្លួនឯងគឺសំខាន់ជាងគេ។ល។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅពុំទាន់មានការសិក្សាណា ដែលបង្ហាញពីមូលហេតុច្បាស់លាស់នៅឡើយទេ។

### វត្ថុបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងលំនាំបញ្ហា ដូចរៀបរាប់ខាងលើ ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងរកឱ្យឃើញនូវហេតុផលពាក់ព័ន្ធទាំងឡាយ ដែលជះឥទ្ធិពលលើការសិក្សារបស់សិស្សមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅមធ្យមសិក្សាទុតិយភូមិក្នុងប្រទេសកម្ពុជា។

### សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅ នឹងវត្ថុបំណងស្រាវជ្រាវនេះ សំណួរស្រាវជ្រាវត្រូវបានកំណត់ដូចខាងក្រោម៖

១. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពល ដល់លទ្ធផលសិក្សារបស់សិស្ស លើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅកម្រិតមធ្យមសិក្សាទុតិយភូមិ?

២. តើកត្តាទាំងនោះមានឥទ្ធិពលខុសគ្នាយ៉ាងណាខ្លះ?

### ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះ ផ្តោតជាចម្បងទៅលើលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី១២ ដែលជាកម្រិតចុងក្រោយនៅមធ្យមសិក្សាលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្ររួមមាន រូប-វិទ្យា គីមីវិទ្យា និងជីវវិទ្យា។ ការកំណត់បែបនេះគឺដោយសារ ក្រុមស្រាវជ្រាវយល់ឃើញថា មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រជាមុខវិជ្ជាសំខាន់ ក្នុងការអភិវឌ្ឍបំណិនផ្សេងៗទៀត។ ម្យ៉ាងទៀត មុននឹងរៀនដល់កម្រិតថ្នាក់ទី១២នេះ សិស្សបានឆ្លងកាត់បទពិសោធជាច្រើន ពីថ្នាក់ក្រោមៗមក ដែលបទពិសោធទាំងនោះអាចផ្តល់ជាចម្លើយជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណង និងសំណួរស្រាវជ្រាវ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឱ្យទិន្នន័យកាន់តែមានភាពសុក្រឹត និងជឿជាក់ វិធីសាស្ត្រតាមបែបបរិមាណវិស័យ និងគុណវិស័យត្រូវបាន ប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវនេះ។ ទិន្នន័យ បែបបរិមាណវិស័យគឺត្រូវបានប្រមូលដោយប្រើកម្រងសំណួរ រីឯទិន្នន័យបែបគុណវិស័យគឺត្រូវបានប្រមូលដោយការសម្ភាស។

### ២.១ ការរៀបចំកម្រងសំណួរ និងសំណួរសម្ភាស

កម្រងសំណួរដែលបានរៀបចំឡើងជា ពាក់កណ្តាលទម្រង់ដែលមានចម្លើយស្រាប់ ដើម្បីឱ្យអ្នកឆ្លើយជ្រើសរើស និងមានសំណួរបើក ដើម្បីឱ្យអ្នកឆ្លើយបានបញ្ចេញនូវគំនិតផ្ទាល់ខ្លួន។ កម្រងសំណួរមួយចំនួនត្រូវបានផលិតឡើងដោយសំយោគចេញពីសំណួរស្តង់ដាអន្តរជាតិ TIMSS-2011 ឱ្យត្រូវនឹងបរិបទកម្ពុជា និងមួយចំនួនទៀតត្រូវបានបង្កើតឡើង ដោយក្រុមអ្នកសិក្សាស្រាវជ្រាវផ្ទាល់ដោយផ្អែកទៅលើស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជាដូចជា ស្ថានភាពសង្គម សាលារៀន គ្រួសារ និងការសិក្សារបស់សិស្សផ្ទាល់ខ្លួន។ ជាមួយគ្នានេះដែរ កម្រងសំណួរសម្ភាសក៏ត្រូវបានបង្កើតឡើង សម្រាប់អ្នកចូលរួមផ្តល់ទិន្នន័យក្នុងការសិក្សាស្រាវជ្រាវនេះ ដើម្បីឱ្យកាន់តែមានភាពជឿជាក់ទៅលើអ្វីដែលពួកគាត់បានបំពេញនៅក្នុង

កម្រងសំណួរ និងដើម្បីប្រមូលបាននូវព័ត៌មានកាន់តែស៊ីជម្រៅ ជាក់ច្បាស់ ឆ្លើយតបទៅនឹងវត្ថុបំណង និងសំណួរស្រាវជ្រាវដែលបានកំណត់។ កម្រងសំណួរទាំងអស់ដែលបានផលិតរួច ត្រូវបានប្រើប្រាស់សាកល្បងនៅវិទ្យាល័យកំពង់ស្ពឺក្នុងខេត្តកំពង់ស្ពឺ ដើម្បីរកឱ្យឃើញនូវភាពដែលរាចជឿទុកចិត្តបាន និងភាពមិនសមស្របនៃសំណួរនីមួយៗ ដើម្បីកែតម្រូវនៅមុនពេលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យផ្លូវការ។

## ២.២ ការជ្រើសរើសភាគសំណាក

ដោយសារថវិកានិងពេលវេលាកំណត់ ខេត្តចំនួន៥ត្រូវបានជ្រើសរើសជាខេត្តតំណាងក្នុង ការប្រមូលទិន្នន័យ។ ខេត្តនីមួយៗតំណាងឱ្យតំបន់ផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា ក្នុងនោះខេត្តកំពង់ចាមតំណាងឱ្យតំបន់ភាគកណ្តាល ខេត្តស្វាយរៀងតំណាងឱ្យតំបន់ភាគអាគ្នេយ៍ ខេត្តកំពតតំណាងឱ្យតំបន់ភាគនិរតីជាប់មាត់សមុទ្រ ខេត្តបាត់ដំបងតំណាងឱ្យតំបន់ពាយព្យ និងខេត្តមណ្ឌលគិរីតំណាងឱ្យតំបន់ខ្ពង់រាបប៉ែកឦសាន។

ខេត្តនីមួយៗ ត្រូវបានជ្រើសរើសយកសាលារៀនចំនួនពី៣ ទៅ៥ ក្នុងតំបន់២ផ្សេងគ្នា គឺតំបន់ទីប្រជុំជន និងតំបន់ដាច់ស្រយាល។ សាលារៀនសរុបចំនួន១៩ ត្រូវបានជ្រើសរើសដោយចៃដន្យសម្រាប់ការប្រមូលទិន្នន័យ។

សម្រាប់សាលានីមួយៗ សិស្សថ្នាក់ទី១២ ដែលរៀនពូកែចំនួន២០នាក់ និងសិស្សដែលរៀនខ្សោយ២០នាក់ ត្រូវបានជ្រើសរើសឱ្យបំពេញកម្រងសំណួរដូចគ្នា និងបន្តជ្រើសយក៥នាក់ ក្នុងចំណោមក្រុមនីមួយៗដើម្បីធ្វើសម្ភាសបន្ថែម។ ការជ្រើសរើសយកសិស្សពូកែ និងសិស្សខ្សោយគឺដោយផ្អែកលើលទ្ធផលពិន្ទុប្រចាំឆមាសទី១ ក្នុងឆ្នាំសិក្សា២០១៦ មានន័យថា សម្រាប់សិស្សពូកែត្រូវបានជ្រើសរើសយកសិស្សដែលមានចំណាត់ថ្នាក់ចាប់ពីលេខ១រហូតដល់បានគ្រប់ចំនួន២០នាក់ រីឯសិស្សខ្សោយត្រូវបានជ្រើសរើសយកសិស្សដែលមានចំណាត់ថ្នាក់ចាប់ពីក្រោមគេបង្អស់រហូតបានចំនួន២០នាក់ដែរ។

ក្រៅពីក្រុមសិស្សថ្នាក់ទី១២ដែលរៀនពូកែ និងរៀនខ្សោយ អ្នកសិក្សាក៏បានប្រមូលព័ត៌មាន ពីគណៈគ្រប់គ្រងសាលារៀន (នាយក នាយករង) ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនតាមមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា តាមរយៈការបំពេញកម្រងសំណួរ និងសម្ភាសជាក្រុមរួមគ្នារវាងអ្នកទាំងអស់នោះ។ ព័ត៌មានដែលទទួលបាននឹងត្រូវយកមកសិក្សា ស្តីពីស្ថានភាពសិក្សារៀនសូត្ររបស់សិស្ស និងស្ថានភាពពាក់ព័ន្ធផ្សេងៗទៀត ដែលទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាសិក្សាពីស្ថានភាពសាលារៀនផងដែរ។ ចំនួននៃអ្នកចូលរួមក្នុងការផ្តល់កម្រងសំណួរ និងបទសម្ភាសក្នុងដំណាក់កាលនេះ គឺអាស្រ័យលើលទ្ធភាពតាមសាលារៀន ដោយពុំបានកំណត់ចំនួនជាក់លាក់ សម្រាប់សាលារៀននីមួយៗឡើយ។

សរុបរួម ចំនួនសិស្សថ្នាក់ទី១២ ដែលបានចូលរួមឆ្លើយកម្រងសំណួរមានចំនួន៦៧៥នាក់ (ស្រី៣៦១នាក់) ក្នុងនោះមានសិស្សចំនួន១៩ក្រុមជាសិស្សរៀនពូកែ និង១៩ក្រុមទៀតជាសិស្សរៀនខ្សោយ។ ដោយឡែកការសម្ភាសសិស្សតាមវិទ្យាល័យនីមួយៗ ចែកចេញជាពីរក្រុមរួមមានក្រុមសិស្សរៀនពូកែ និងក្រុមសិស្សរៀនខ្សោយ ហើយក្នុងមួយក្រុមៗមានសិស្សពី ៥ ទៅ ៦នាក់។ ជាមួយគ្នានេះដែរ ការឆ្លើយកម្រងសំណួរ និងការផ្តល់បទសម្ភាសសម្រាប់ការស្រាវជ្រាវនេះមានការចូលរួមពីនាយក នាយករងចំនួន ២៣នាក់ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមុខវិជ្ជា គណិតវិទ្យាចំនួន១៩នាក់រូបវិទ្យាចំនួន១៩នាក់ មុខវិជ្ជាគីមីវិទ្យាចំនួន១៩នាក់ និងជីវវិទ្យាចំនួន១៦នាក់ សរុបទាំងអស់ចំនួន៧៣នាក់។

ទោះជាយ៉ាងនេះក្តី ការជ្រើសរើសខេត្ត និងសាលារៀននៅតំបន់ខុសៗគ្នានេះ គឺក្នុងគោលបំណងទទួលបានរបាយទិន្នន័យតំណាងឱ្យស្ថានភាព សិក្សារបស់សិស្ស គ្រួសារ ការរស់នៅ និងសាលារៀនផ្សេងៗគ្នា ដើម្បីឈានទៅរកការទាញសន្និដ្ឋាន រួមជាទូទៅសម្រាប់ប្រទេសកម្ពុជាទាំងមូលប៉ុណ្ណោះ។ ការសិក្សានេះមិនបានធ្វើការប្រៀបធៀបរវាងខេត្ត និងខេត្ត ឬរវាងតំបន់ និងតំបន់ ឬសាលារៀន និងសាលារៀនទេ។

## ២.៣ វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យទាំងអស់ ដែលទទួលបានពីកម្រងសំណួរ ត្រូវបានធ្វើវិភាគតាមបែបបរិមាណវិស័យ ដោយចងជាកូដនូវ អថេរនីមួយ និងបញ្ចូលក្នុងកម្មវិធី SPSS ដើម្បីវិភាគរកមើលពីទំនាក់ទំនងរវាងកត្តានីមួយៗ ជាមួយនឹងលទ្ធផលសិក្សា (ពិន្ទុប្រចាំឆមាសទី១) របស់សិស្ស។ ការវិភាគនេះ ត្រូវបានធ្វើឡើងដោយប្រើកម្មវិធីផ្សេងៗដូចជា៖ T-test, One-way ANOVA, crosetape, ដើម្បីរកតម្លៃបង្ហាញពីការពណ៌នាទិន្នន័យ (data descriptive), កម្រិតទំនាក់ទំនងគ្នារវាងអថេរនីមួយៗ (correlation), កម្រិតជាក់លាក់ (Significant) និងចំនួនប្រេកង់ចម្លើយ របស់ភាគ សំណាក។ ទិន្នន័យដែលវិភាគរួចត្រូវបានបង្ហាញតាមរយៈក្រាហ្វផ្សេងៗដោយប្រើ MSExcell។ ចំពោះទិន្នន័យ ដែលទទួលបានពីការធ្វើសម្ភាសជាមួយសិស្សខ្សោយ សិស្សពូកែ គ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស និងគណៈគ្រប់គ្រងសាលារៀន ត្រូវបានធ្វើវិភាគតាមបែបគុណវិស័យ ដោយអានសាចុះសាឡើង និងចម្រោះយកនូវព័ត៌មានគោលសំខាន់ៗ (Screening) ដើម្បីបញ្ជាក់បន្ថែមទៅនឹងទិន្នន័យបែបបរិមាណ ដែលទទួលបានពីកម្រងសំណួរ។ លទ្ធផលសម្ភាសក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីរកមើលកត្តាផ្សេងៗទៀត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្ស ហើយដែលកត្តាទាំងនោះពុំបានបញ្ចូលនៅក្នុងកម្រងសំណួរ។

## ៣. លទ្ធផល និងការពិភាក្សា

ការសិក្សានឹងធ្វើការពិភាក្សាដោយផ្តោតសំខាន់ទៅលើកត្តាគោលមួយចំនួន ដែលអ្នកអប់រំ ឬប្រជាពលរដ្ឋទូទៅតែងតែធ្វើការប៉ាន់ស្មាន។ កត្តាដែលត្រូវលើកមកពិភាក្សាទាំងនោះរួមមានកត្តាគ្រួសារ កត្តាសាលារៀន កត្តាគ្រូបង្រៀន កត្តាសង្គម និងកត្តាសិស្សខ្លួនឯង។

### ៣.១ កត្តាគ្រូបង្រៀន

#### *ក. កត្តាចរិតលក្ខណៈ*

លទ្ធផលសិក្សារបស់សិស្សបានល្អ ឬមិនល្អ ជាទូទៅគេតែងតែផ្តោតសំខាន់ ទៅលើកត្តាគ្រូបង្រៀនជាចម្បង។ មតិជាច្រើនតែងលើកឡើងថា បើគ្រូបង្រៀនមានសមត្ថភាពទាំងមុខវិជ្ជាឯកទេស វិធីសាស្ត្របង្រៀន និងបង្រៀនដោយយកចិត្តទុកដាក់ នោះសិស្សនឹងទទួលបានលទ្ធផលសិក្សាកាន់តែប្រសើរ។ ដូច្នេះនៅក្នុងផ្នែកនេះ ការពិភាក្សាផ្តោតសំខាន់ ទៅលើទំនាក់ទំនងរវាងលទ្ធផលសិក្សារបស់សិស្ស ទៅនឹងលក្ខខណ្ឌផ្សេងៗរបស់គ្រូបង្រៀន ដូចជាសមត្ថភាពពន្យល់បកស្រាយមេរៀន សកម្មភាពបង្រៀននិងរៀន និងភាពញឹកញាប់នៃការដាក់កិច្ចការ និងកែកិច្ចការឱ្យសិស្ស។

ការសិក្សាបានបង្ហាញថា លទ្ធផលសិក្សារបស់សិស្ស ពិតជាមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រូបង្រៀន។ ចរិតលក្ខណៈគ្រូបង្រៀនខុសៗគ្នា ដែលរួមមាន ការយកចិត្តទុកដាក់បង្រៀន ឥរិយាបថ ទំនាក់ទំនង ការគោរពពេលវេលា ភាគច្រើនបានធ្វើឱ្យពិន្ទុសិក្សាលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រមានការប្រែប្រួល ទៅតាមកម្រិតនៃការអនុវត្តរបស់គ្រូបង្រៀន (Correlation Sig.<0.05)។ ទិន្នន័យបានបង្ហាញថា ជាទូទៅសិស្សទទួលបានពិន្ទុកាន់តែប្រសើរ កាលណា គ្រូបង្រៀនមានទេពកោសល្យល្អ ក្នុងការពន្យល់មេរៀន មានទំនាក់ទំនងជាមួយសិស្ស ប្រកបដោយឥរិយាបថវិជ្ជមាន និងគោរពក្រមសីលធម៌គ្រូបង្រៀនខ្ជាប់ខ្ជួន (Sig.=0.00<0.05) (រូបទី១)។ ទោះជាយ៉ាងណាក៏ដោយ កត្តាគោរពពេលវេលាទៀងទាត់របស់គ្រូបង្រៀនហាក់ដូចជាមិនបានធ្វើឱ្យពិន្ទុសិស្សប្រែប្រួលខ្លាំងនោះទេ សម្រាប់មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា (ANOVA: Math-Sig.=0.193; Phy-Sig.=0.168 & Chem-Sig.=0.087)។ ដូចគ្នាដែរ ចំពោះមុខវិជ្ជាជីវវិទ្យា កត្តាពន្យល់មេរៀនរបស់គ្រូក៏ពុំបានធ្វើឱ្យពិន្ទុសិស្សមានការប្រែប្រួលខ្លាំងដែរ(Sig.=0.254)។




រូបទី១៖ ឥទ្ធិពលគ្រូបង្រៀនលើមធ្យមពិន្ទុរបស់សិស្សតាមមុខវិជ្ជា

លទ្ធផលនេះបានបញ្ជាក់ថា ក្នុងចំណោមមុខវិជ្ជាដែលសិក្សានៅក្នុងការស្រាវជ្រាវនេះ មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ទាមទារឱ្យគ្រូបង្រៀនធ្វើការពន្យល់សិស្សល្អិតល្អន់ទៅលើខ្លឹមសារមេរៀន ពាក្យគន្លឹះ រូបមន្ត ឬបាតុភូតពាក់ព័ន្ធនានា។ លទ្ធផលស្រាវជ្រាវបន្ថែមបានបង្ហាញថា ការសិក្សាគណិតវិទ្យា អាស្រ័យទៅលើកត្តាចំនួនរួមមាន ស្វ័យសិក្សា(Sig.=0.00) រៀនគួរបន្ថែម (Sig.=0.00) និងកត្តាវិធីសាស្ត្របង្រៀនរបស់គ្រូនៅក្នុងថ្នាក់ ដែលនឹងពិភាក្សានៅចំណុចខាងក្រោម។ មិនខុសគ្នាប៉ុន្មាននឹងមុខវិជ្ជាគណិតវិទ្យាទេ ការសិក្សាមុខវិទ្យាវិទ្យាសាស្ត្រក៏វាអាស្រ័យនឹងកត្តាសំខាន់មួយចំនួនទៀត បន្ថែមពីលើការមកបង្រៀនទៀងទាត់ពេលវេលារបស់គ្រូ។ លើសពីនេះទៅទៀត ការសិក្សាមុខវិជ្ជាទាំងនេះ ជាមុខវិជ្ជាដែលតម្រូវឱ្យសិស្សត្រូវមានមូលដ្ឋានគ្រឹះរឹងមាំ ទាំងចំណេះដឹងមូលដ្ឋានផ្នែកលេខនព្វន្ត ចំណេះដឹងផ្នែកបាតុភូតធម្មជាតិ និងការអនុវត្ត។ ដូច្នេះ ការគាស់រំលើងមូលដ្ឋានគ្រឹះពាក់ព័ន្ធនានានឹងបញ្ញត្តិថ្មី គឺជាកាតព្វកិច្ចចាំបាច់សម្រាប់គ្រូបង្រៀនត្រូវអនុវត្តជារឿយៗ ចំពោះសិស្ស នៅពេលបង្រៀន។ ទាំងនេះបង្ហាញថា ទោះបីគ្រូបង្រៀនព្យាយាមគោរពពេលវេលាទៀងទាត់ក្នុងការបង្រៀនសិស្សក៏ដោយ តែបើវិធីសាស្ត្របង្រៀនរបស់គ្រូពុំបានផ្តល់ឱកាស និងជំរុញទឹកចិត្តសិស្សក្នុងការសិក្សាគ្រប់គ្រាន់ នោះនឹងពុំបានធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើងបានដែរ។

## ខ. គន្លឹះវិធីសាស្ត្របង្រៀន

បន្ទាប់ពីចំណេះដឹងជ្រៅជ្រះ លើមុខវិជ្ជាឯកទេស ដែលជាគុណវុឌ្ឍិចម្បងរបស់គ្រូបង្រៀន ការចេះប្រើវិធីសាស្ត្របង្រៀន ប្រកបដោយភាពទាក់ទាញសម្រាប់សិស្ស គឺជាសមត្ថភាពសំខាន់មួយទៀត ដែលគ្រូបង្រៀនត្រូវតែមាន។ តាមលទ្ធផលស្រាវជ្រាវនេះបានបង្ហាញថា វិធីសាស្ត្របង្រៀនមួយចំនួន ដែលគ្រូតែងប្រើនៅក្នុងថ្នាក់ អាចជួយបង្កើនការសិក្សាសិស្សយ៉ាងមានប្រសិទ្ធភាព និងសមស្របសម្រាប់ការបង្រៀន និងរៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ។ ដូចបង្ហាញក្នុងរូបទី២ វិធីសាស្ត្របង្រៀនទាំងនោះរួមមាន ការពន្យល់ខ្លឹមសារមេរៀនយ៉ាងច្បាស់លាស់ ដោយផ្សារភ្ជាប់ខ្លឹមសារទាំងនោះ ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ការផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យសិស្ស ដើម្បីរៀនដោះស្រាយលំហាត់ដោយខ្លួនឯង ដោយចាប់ផ្តើមអនុវត្តពីមូលដ្ឋានរូបមន្តឡើងទៅ និងការរៀបចំឱ្យសិស្សធ្វើការពិភាក្សាជាក្រុមជាដើម។ ផ្ទុយទៅវិញ សកម្មភាពបង្រៀនមួយចំនួន ហាក់ដូចជាពុំបានធ្វើឱ្យលទ្ធផលសិក្សារបស់សិស្ស បានប្រសើរឡើងទេ ដូចជាការបង្រៀនដោយឱ្យសិស្សអានសៀវភៅគោលនិងឆ្លើយសំណួរ គ្រូម្នាក់ឯងជាអ្នកដោះស្រាយលំហាត់លើក្តារខៀន ដោយឱ្យសិស្សអង្គុយចាំមើល និងចាំតែកត់ត្រាចូលក្នុងសៀវភៅ ការបង្រៀនដោយឱ្យសិស្សទន្ទេញចាំមាត់នូវខ្លឹមសារ រូបមន្ត ឬបញ្ញត្តិវិទ្យាសាស្ត្រដោយមិនបានពិភាក្សាឈ្វេងយល់ស៊ីជម្រៅជាដើម។




រូបទី២៖ ឥទ្ធិពលនៃសកម្មភាពបង្រៀន និងរៀននានាទៅលើលទ្ធផលសិក្សារបស់សិស្ស

ករណីមុខវិជ្ជាគណិតវិទ្យា លទ្ធផលស្រាវជ្រាវបានបង្ហាញថា ក្នុងចំណោមវិធីសាស្ត្របង្រៀនជាច្រើនដែលគ្រូបង្រៀនបានប្រើក្នុងការបង្រៀនសិស្ស មានតែមួយចំនួនប៉ុណ្ណោះ ដែលមានឥទ្ធិពលទៅលើលទ្ធផលសិក្សារបស់សិស្ស ដូចជា ការពន្យល់របស់គ្រូដោយផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ(Sig. =0.00) ភាពញឹកញាប់នៃការដោះស្រាយលំហាត់បង្ហាញដល់សិស្ស(Sig.=0.02) ឱ្យឱកាសសិស្សដោះស្រាយលំហាត់ដោយខ្លួនឯង (Sig.=0.001) រៀនដោយសហការនិងពិភាក្សាក្រុម(Sig.0.001) និងឡើងដោះស្រាយលំហាត់នៅលើក្តារខៀន(Sig.0.048) (រូបទី៣)។

ករណីមុខវិជ្ជាវិទ្យាសាស្ត្រហាក់មានលក្ខណៈខុសពីមុខវិជ្ជាគណិតវិទ្យា។ ខណៈដែលការឱ្យសិស្សរៀនដោយពិភាក្សាក្រុមនូវមុខវិជ្ជាគណិតវិទ្យា អាចជួយសិស្សក្នុងការសិក្សាយ៉ាងមានប្រសិទ្ធភាព ដើម្បីទទួលបានលទ្ធផលសិក្សាកាន់តែប្រសើរ សកម្មភាពបង្រៀន និងរៀនបែបនេះហាក់ពុំទទួលបានផលល្អទេសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ។ ដូចបង្ហាញក្នុងរូបទី៣ មានតែវិធីបង្រៀន និងរៀនដោយឱ្យ

សិស្សដោះស្រាយសំណួរ ឬលំហាត់ដោយខ្លួនឯងប៉ុណ្ណោះ ដែលមានប្រសិទ្ធភាព ដោយធ្វើឱ្យសិស្សទទួលបានមធ្យមពិន្ទុកាន់ខ្ពស់កាលណាពួកគេអនុវត្តវិធីបែបនេះកាន់តែញឹកញាប់។ ដោយឡែក ការរៀនតាមបែបការសង្កេតពិសោធបង្ហាញដោយគ្រូ រៀបគម្រោងពិសោធ និងធ្វើពិសោធដោយខ្លួនឯង បង្ហាញឱ្យឃើញថាមានទំនាក់ទំនងជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស (Sig.<0.05)។ ប៉ុន្តែ បើយើងពិនិត្យមើលទៅលើមធ្យមពិន្ទុរបស់សិស្ស បែជាមានការថយចុះទៅវិញ កាលណាវិធីរៀនបែបនេះត្រូវបានអនុវត្តកាន់តែញឹកញាប់។ លទ្ធផលនេះ អាចបណ្តាលមកពីការអនុវត្តសកម្មភាពក្រុមនីមួយៗរបស់សិស្ស គ្មានប្រសិទ្ធភាព។ នៅពេលពិភាក្សា ឬធ្វើការងារក្នុងក្រុម សិស្សម្នាក់ៗអាចពុំបានចូលរួមផ្តល់យោបល់ផុសផុល ក្នុងការរកចម្លើយនៅក្នុងក្រុមខ្លួនទេ ខណៈដែលមានតែសិស្សពូកែតែម្នាក់ ឬពីរនាក់ប៉ុណ្ណោះបានផ្តល់យោបល់លើសលុប។ លក្ខណៈបែបនេះអាចនាំឱ្យសិស្សភាគច្រើន ដែលមិនបានចូលរួមពិភាក្សាបញ្ចេញយោបល់ បានត្រឹមតែអង្គុយមើល ឬស្តាប់យោបល់របស់សិស្សពូកែ ដោយពុំបានយល់អ្វីទាំងអស់។ ប្រសិទ្ធភាពនៃការអនុវត្តការងារក្រុមនៅក្នុងថ្នាក់រៀនវិទ្យាសាស្ត្រនៅកម្ពុជា ដូចបានពណ៌នាខាងលើនេះ ត្រូវបានគេមើលឃើញជាញឹកញាប់ និងមានបង្ហាញផងដែរ នៅក្នុងរបាយការណ៍ស្ទាបស្ទង់ជាមូលដ្ឋានរបស់គម្រោង STEPSAM2[៧]។ ករណីស្រដៀងគ្នានេះដែរ ជាញឹកញាប់កើតមាននៅពេលគ្រូឱ្យសិស្សធ្វើ និងសង្កេតពិសោធតាមក្រុម អានសៀវភៅគោលនិងឆ្លើយសំណួរ ទន្ទេញមេរៀន និងរូបមន្ត និងមើលគ្រូដោះស្រាយលំហាត់។ លទ្ធផលសម្ភាសន៍គ្រូបង្រៀនបានបង្ហាញថា សកម្មភាពទាំងនេះ សិស្សភាគច្រើនបានត្រឹមតែមើល និងកត់ត្រាតាមគ្រូ ដោយពុំបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀនបែបនេះទេ។ ម្យ៉ាងទៀត ការស្រាវជ្រាវក៏បានបង្ហាញថាចំនួនសិស្សមានច្រើននៅក្នុង១ថ្នាក់ៗ (លើសពី ៤០ នាក់ក្នុង១ថ្នាក់) ជាពិសេសសាលានៅទីជនបទ។ ចំនួនសិស្សច្រើននៅក្នុងថ្នាក់មានលក្ខណៈមិនសមស្របសម្រាប់សកម្មភាពសិស្សជាក្រុមទេ តែវាអាចមានលក្ខណៈសមស្របជាមួយការរៀនដោយស្តាប់គ្រូពន្យល់លើក្តារខៀនជាង។ លើសពីនេះទៀត សំណួរ ឬលំហាត់ដែលសិស្សប្រឡងយកពិន្ទុភាគច្រើនជាលំហាត់ និងមិនសូវទាក់ទងទៅនឹងអ្វីដែលពួកគេបានអនុវត្ត សង្កេត ឬធ្វើពិសោធនោះទេ។ ដោយសារស្ថានភាពសិក្សាក្រុមមានលក្ខណៈបែបនេះហើយ ទើបធ្វើឱ្យពួកគេពុំទទួលបានពិន្ទុរង្វាយតម្លៃប្រចាំឆមាសខ្ពស់ ដូចបង្ហាញក្នុងលទ្ធផលស្រាវជ្រាវនេះ បើទោះជាវិធីសាស្ត្របង្រៀនវិទ្យាសាស្ត្របែបពិភាក្សាក្រុម និងផ្តល់ឱកាសឱ្យសិស្សធ្វើពិសោធនៅក្នុងថ្នាក់ ត្រូវបានគេទទួលស្គាល់ថាវាមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀនក៏ដោយ។

### គ. កត្តាគុណវុឌ្ឍិគ្រូបង្រៀន

ការសិក្សាក៏បានបង្ហាញផងដែរថា ក្នុងចំណោមគ្រូបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រដែលបានសិក្សា មានគ្រូបង្រៀនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ពោលគឺមានបរិញ្ញាបត្រជំនាញត្រូវឯកទេស។ លើសពីនេះទៅទៀត ពួកគាត់ទាំងនោះក៏ធ្លាប់បានទទួលការបណ្តុះបណ្តាលបន្តពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងសមត្ថភាពខ្លួនបន្ថែម។ លើសពីនេះទៅទៀត ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មានជាង ៨០% ធ្លាប់បានទទួលការបំប៉នស្តីពីខ្លឹមសារមេរៀន ប្រមាណ ៧០% ធ្លាប់បានទទួលការបំប៉នស្តីពីវិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សា។ ទោះជាយ៉ាងណាក៏ដោយកង្វះគ្រូវិទ្យាសាស្ត្រ និងគណិតវិទ្យានៅតែជាបញ្ហានៅឡើយ។ មានសាលារៀនរហូតដល់ប្រមាណជា៧០% ក្នុងចំណោមសាលារៀន ដែលចូលរួមក្នុងការស្រាវជ្រាវនេះបានបង្ហាញថា ពុំមានគ្រូបង្រៀនឯកទេសនេះគ្រប់គ្រាន់ទេ ជាពិសេសសាលារៀនដែលនៅតំបន់ជនបទ។ នៅពេលធ្វើសម្ភាសន៍នាយកសាលារៀនជនបទភាគច្រើនបានត្អូញត្អែរថា មន្ទីរ ឬក្រសួងពុំបានផ្គត់ផ្គង់គ្រូទៅតាមតម្រូវការ ឬការស្នើសុំរបស់ពួកគាត់ទេ។ លើសពីនេះទៅទៀត គ្រូដែលមានគុណវុឌ្ឍិមួយចំនួនបានបន្តផ្លាស់ចេញពីសាលារៀនរបស់គាត់ទៀត ទៅសាលារៀនផ្សេងនៅទីប្រជុំជន។ កត្តានេះបានជំរុញឱ្យពួកគាត់ត្រូវសម្រេចចិត្តប្រើប្រាស់គ្រូបង្រៀនខុសមុខវិជ្ជាឯកទេស ឬគ្រូបង្រៀនដែលពុំមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧទាហរណ៍ ប្រើគ្រូបឋមភូមិឱ្យបង្រៀននៅ

ទុតិយភូមិ)។ ដូច្នេះលទ្ធផលសិក្សារបស់សិស្ស ក៏អាចទទួលរងនូវឥទ្ធិពលបញ្ហាកង្វះខាតគ្រូ ដែលមានគុណវុឌ្ឍិផងដែរ។

## ២.៣ កត្តាសាលារៀន

កត្តាសាលារៀនក៏ជាកត្តាមួយសំខាន់ ក្នុងចំណោមកត្តាផ្សេងៗទៀត ការពិភាក្សានឹងផ្តោតសំខាន់ទៅលើលក្ខខណ្ឌផ្សេងៗដែលផ្តល់ដោយសាលារៀនសម្រាប់ការសិក្សារៀនសូត្ររបស់សិស្សរួមមានកត្តាតំបន់ បរិស្ថានសាលារៀន បរិស្ថានថ្នាក់រៀន សម្ភារសិក្សា និងការគ្រប់គ្រងជាដើម។

### ក.បរិស្ថាន និងការគ្រប់គ្រងសាលារៀន

ការសិក្សាបានបង្ហាញថា លទ្ធផលសិក្សារបស់សិស្សហាក់បីដូចជាពុំមានទំនាក់ទំនងជាមួយនឹង លក្ខណៈបរិស្ថានរបស់សាលារៀន ឬបរិស្ថានថ្នាក់រៀនទេ។ សិស្សដែលវាយតម្លៃថាសាលារៀនរបស់ខ្លួន មានបរិស្ថានល្អ សម្រាប់ការសិក្សា ដូចជាជាទីកន្លែងដែលមានសុវត្ថិភាពមានបរិស្ថានទីធ្លាស្អាត បរិស្ថានក្នុងថ្នាក់រៀនល្អ ជាទីដែលគ្មានការរំខានពីមជ្ឈដ្ឋានខាងក្រៅ ទទួលបានលទ្ធផលពិន្ទុទាំងមុខវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រមិនខុសគ្នាពីសិស្សរៀននៅសាលារៀនដែលមានបរិស្ថានមិនសូវល្អនោះទេ។ ជាទូទៅតម្លៃស្ថិតិ នៃការប្រៀបធៀបពិន្ទុរវាងក្រុមសិស្សដែលមកពីបរិស្ថានសាលារៀនខុសៗគ្នា ដូចបានរៀបរាប់ខាងលើមានតម្លៃ Sig.>0.05 (តារាងទី១)។

ជាការពិត លទ្ធផលនេះបានបញ្ជាក់ថា សម្ភារបរិក្ខា មន្ទីរពិសោធ បណ្ណាល័យ សោភណភាពសាលារៀន គ្រាន់តែជាឧបករណ៍រូបីដែលគ្មានវិញ្ញាណប៉ុណ្ណោះ។ វានឹងក្លាយជាមានប្រយោជន៍សម្រាប់សិស្សប្រសិនបើ សិស្សបានប្រើប្រាស់វា។ ករណីសួនច្បារស្អាត បន្ទប់រៀនស្អាត សុវត្ថិភាពសាលារៀន វាជាផ្នែកមួយ ដែលអាចជួយអប់រំចិត្ត សីលធម៌រស់នៅ និងធ្វើឱ្យសិស្សមានភាពស្ងប់ មិនភ័យខ្លាចនៅក្នុងពេលគេកំពុងសិក្សាក្នុងសាលារៀន។ ប៉ុន្តែវាមិនមានឥទ្ធិពលផ្ទាល់ ទៅលើលទ្ធផលសិក្សារបស់សិស្សនោះទេ។ ករណីមន្ទីរពិសោធ និងបណ្ណាល័យក៏ដូច្នោះដែរ បើទោះជាសាលារៀនមានមន្ទីរពិសោធវិទ្យាសាស្ត្រ បណ្ណាល័យដែលមានបំពាក់សម្ភារសិក្សាគ្រប់គ្រាន់ ប៉ុន្តែបើសាលារៀនពុំមានកម្មវិធីច្បាស់លាស់ ក្នុងការបើកឱកាស គ្រប់គ្រាន់ដើម្បីឱ្យសិស្សបានប្រើប្រាស់ និងអនុវត្ត នោះវាក៏មិនអាចនាំឱ្យលទ្ធផលសិក្សាសិស្សប្រែប្រួលបានដែរ។

តារាងទី១៖ តម្លៃជាក់លាក់រវាងមធ្យមពិន្ទុគណិតវិទ្យា និងវិទ្យាសាស្ត្ររបស់សិស្ស

| | កម្រិតខុសគ្នាមធ្យមពិន្ទុ (Significant Value.) |
|---|---|
| ខ្ញុំមានអារម្មណ៍ថា មានសុវត្ថិភាព ពេលខ្ញុំនៅក្នុងសាលារៀន | 0.999 |
| ខ្ញុំចង់រៀននៅក្នុងសាលារៀននេះ | 0.243 |
| សាលារៀនខ្ញុំមានបរិស្ថាន ទីធ្លា ថ្នាក់រៀនល្អ | 0.819 |
| សាលារៀនខ្ញុំគ្មានការរំខានពីមជ្ឈដ្ឋានខាងក្រៅ | 0.453 |
| សាលារៀនខ្ញុំមានមន្ទីរពិសោធវិទ្យាសាស្ត្រ | 0.249 |
| សាលារៀនខ្ញុំមានសម្ភារពិសោធ ឬសម្ភារឧបទេសគ្រប់គ្រាន់ | 0.104 |
| សាលារៀនខ្ញុំមានបណ្ណាល័យ ដែលខ្ញុំអាចរកបាននូវឯកសារសិក្សាបន្ថែមគ្រប់គ្រាន់ | 0.132 |
| នាយកសាលាតែងតែជំរុញគ្រូឱ្យបង្រៀនពិសោធ ឬប្រើសម្ភារឧបទេស | 0.172 |
| នាយកសាលា និងគ្រូតែងជំរុញលើកទឹកចិត្តខ្ញុំឱ្យចូលបណ្ណាល័យ | 0.73 |

ស្របតាមកម្រងសំណួរ និងការសម្ភាសន៍ គណៈគ្រប់គ្រង គ្រូបង្រៀន នៅសាលារៀនភាគច្រើនពុំមានមន្ទីរពិសោធ និងបណ្ណាល័យទេ។ នៅជនបទមានសាលារៀនប្រមាណជាង ៦០% ពុំមានមន្ទីរពិសោធ និងប្រមាណ ៥០% ពុំមានបណ្ណាល័យទេ ខណៈដែលសាលារៀននៅទីប្រជុំជន មានចំនួនច្រើនជាង ៥០%។ ទោះបីជាសាលារៀនមួយចំនួនដែលមានមន្ទីរពិសោធ និងបណ្ណាល័យ ប៉ុន្តែពុំមានសម្ភារពិសោធ សារធាតុគីមី និងមិនមានសៀវភៅគ្រប់គ្រាន់សម្រាប់សិស្សសិក្សាស្រាវជ្រាវបន្ថែមទេ។ លើសពីនេះទៅទៀត សិស្សមានឱកាសតិចតួចដើម្បីប្រើប្រាស់បណ្ណាល័យ ឬមន្ទីរពិសោធវិទ្យាសាស្ត្រ ដោយសារសាលារៀនពុំមានកម្មវិធី និងយន្តការគ្រប់គ្រងច្បាស់លាស់។ ដូចបានរៀបរាប់មកខាងលើនេះ អាចជាមូលហេតុសម្រាប់សាលារៀនដែលបានសិក្សាស្រាវជ្រាវ ទោះមាន ឬមិនមានមន្ទីរពិសោធ និងបណ្ណាល័យ ក៏ពុំបានបង្ហាញឱ្យឃើញថាមាន លទ្ធផលសិក្សារបស់សិស្សខុសគ្នានោះដែរ។ មានន័យថា គុណភាពសិក្សារបស់សិស្សប្រសើរឡើង លុះត្រាតែសម្ភារបរិក្ខាសិក្សាទាំងនោះត្រូវបានប្រើប្រាស់ ឬមានដំណើរការប្រកបដោយប្រសិទ្ធភាព សម្រាប់ការសិក្សារបស់សិស្ស។

## ខ.កត្តាតំបន់ភូមិសាស្ត្រសាលារៀន

ជាទូទៅ សិស្សនៅសាលារៀនទីប្រជុំជន មានលទ្ធផលសិក្សាប្រសើរជាងសិស្សនៅសាលារៀនទីជនបទ។ នេះបញ្ជាក់ថាសាលារៀនដែលស្ថិតនៅទីប្រជុំជន ផ្តល់សេវាសិក្សាបានច្រើន និងមានប្រសិទ្ធភាពជាងសាលារៀនដែលស្ថិតនៅទីជនបទ។ ដូចបង្ហាញក្នុងរូបទី៣ សិស្សដែលរៀននៅសាលារៀនក្នុងតំបន់ប្រជុំជន មានមធ្យមភាគពិន្ទុខ្ពស់ជាងបើប្រៀបធៀបទៅនឹងសិស្ស ដែលរៀននៅសាលារៀនក្នុងតំបន់ជនបទ ជាពិសេសលើមុខវិជ្ជាវិទ្យាសាស្ត្រ ដែលទិន្នន័យស្ថិតិបានបង្ហាញថា មធ្យមពិន្ទុរវាងសិស្សទាំងពីរក្រុមនេះមានភាពខុសគ្នាខ្លាំង(Sig.<0.05)។

យោងតាមលទ្ធផលនៃការបំពេញកម្រងសំណួរ និងការសម្ភាសន៍ គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូបានបង្ហាញថា ការផ្តល់សេវាកម្មសិក្សានៅតាមសាលារៀនជនបទនៅមានការខ្វះខាតច្រើន បើប្រៀបធៀបនឹងទីប្រជុំជន។




រូបទី៣៖ លទ្ធផលសិក្សាសិស្សទីប្រជុំជន និងជនបទ

ដូចដែលបានពិភាក្សានៅចំណុចខាងលើរួចមកហើយ ភាគច្រើននៃសាលារៀន ដែលនៅទីជនបទពុំទាន់មានសម្ភារបង្រៀន និងរៀនគ្រប់គ្រាន់ គ្មានបណ្ណាល័យ គ្មានមន្ទីរពិសោធវិទ្យាសាស្ត្រ។ បន្ថែមលើនេះ គ្រូគណិតវិទ្យា និងវិទ្យាសាស្ត្រ ដែលមានសមត្ថភាពបង្រៀនល្អតែងតែធ្វើការផ្លាស់ប្តូរចេញទៅរកសាលារៀន ដែលស្ថិតនៅទីប្រជុំជន។ ម្យ៉ាងវិញទៀត លក្ខខណ្ឌរស់នៅរបស់សិស្សដែលនៅទីប្រជុំជន ជាទូទៅមានលក្ខណៈល្អជាងសិស្សនៅតាមជនបទ ទាំងជីវភាព និងការលើកទឹកចិត្តពីមាតាបិតា។ តាមការសម្ភាសន៍ នាយកសាលា ក៏ដូចជាគ្រូបង្រៀននៅសាលាជនបទ បានលើកឡើងស្រដៀងគ្នាថា សិស្សដែលរៀនខ្សោយ ភាគច្រើនពុំសូវទទួលបានការជំរុញលើកទឹកចិត្ត ឬតាមដានការសិក្សាជិតដល់ពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាលទេ។ ពួកគាត់មានការមមាញឹកខ្លាំង និងចំណាយពេលច្រើន ទៅលើការប្រកបមុខរបរចិញ្ចឹមជីវិត។ ពួកគាត់មួយចំនួនទៀតពុំមានចំណេះដឹងជ្រៅជ្រះ និងពុំយល់ពីសារៈសំខាន់នៃការអប់រំ។ មិនតែប៉ុណ្ណោះ ពួកគាត់មួយចំនួនបានប្រើកូនឱ្យជួយធ្វើការងារខ្លួន ដែលនាំឱ្យគេមិនបានមករៀនទៀងទាត់ទៀតផង។ ករណីដូចបានរៀបរាប់ខាងលើនេះ មានលក្ខណៈផ្ទុយគ្នាច្រើនចំពោះជីវិតសិក្សារបស់សិស្សនៅទីប្រជុំជន ដែលពួកគេទទួលបានការយកចិត្តទុកដាក់ពីឪពុកម្តាយ ឬសាច់ញាតិដែលភាគច្រើនជាអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់ មានមុខរបរ និង

ជីវភាពប្រសើរ មានម្ហូបអាហារមានជីវជាតិ រួមទាំងពួកគេអាចទទួលបាននូវការសិក្សាជាមួយគ្រូដែលមានសមត្ថភាព និងមានគុណវុឌ្ឍិ សាលារៀនមានសម្ភារបរិក្ខា សម្ភារឧបទេសច្រើនជាងសាលារៀនជនបទ។

## ៣.៣ កត្តាសិស្សខ្លួនឯង

បើទោះបីជាលទ្ធផលសិក្សារបស់សិស្សតែងមានទំនាក់ទំនងគ្នាជាមួយកត្តាគ្រូបង្រៀន និងកត្តាសាលារៀនក៏ដោយក៏នៅតែគេយល់ឃើញថា កត្តាសិស្សខ្លួនឯងជាកត្តាសំខាន់បំផុត។ ប្រសិនបើសិស្សមិនខិតខំសិក្សាឈ្វេងយល់ដោយខ្លួនឯង រួមគ្នាជាមួយនឹងការខិតខំបង្ហាត់បង្ហាញរបស់គ្រូ និងលក្ខខណ្ឌសិក្សានានាដែលសាលារៀនបានផ្តល់ឱ្យទេ នោះក៏មិនរំពឹងថានឹងទទួលបានលទ្ធផលល្អដែរ។ នៅក្នុងផ្នែកនេះ ការពិភាក្សាទំនាក់ទំនងរវាងលទ្ធផលសិក្សារបស់សិស្សទៅនឹងផ្តោតកត្តាសិស្សដូចជា យេនឌ័រ ចំណង់ចំណូលចិត្តលើការសិក្សាតាមមុខវិជ្ជា និងវិធីសិក្សារៀនសូត្ររបស់ពួកគេ។

### ក.កត្តាយេនឌ័រ

បើប្រៀបធៀបរវាងយេនឌ័រ ជាទូទៅសិស្សស្រីមានលទ្ធផលសិក្សាល្អប្រសើរជាងសិស្សប្រុស។ សិស្សស្រីហាក់ដូចជាមានទំនួលខុសត្រូវ យកចិត្តទុកដាក់ និងខិតខំសិក្សា ខណៈដែលសិស្សប្រុស ហាក់ដូចជាពុំបានចាប់អារម្មណ៍ប៉ុន្មានទេក្នុងការសិក្សា។ តាមការសម្ភាសន៍ នាយកសាលា និងគ្រូបង្រៀន សិស្សប្រុសភាគច្រើនចូលចិត្តដើរលេងច្រើន ភ្លើតភ្លើន ពុំសូវយកចិត្តទុកដាក់ក្នុងការរៀនសូត្រ និងមករៀនក៏ពុំសូវទៀងទាត់ដែរ។ ចំពោះសិស្សស្រីវិញ នៅក្នុងម៉ោងសិក្សា ក៏ដូចជាកិច្ចការផ្សេងៗដែលគ្រូដាក់ឱ្យពួកគេបានខិតខំ យកចិត្តទុកដាក់បំពេញការងារទាំងនោះដោយហ្មត់ចត់។ កត្តានេះ បានធ្វើឱ្យសិស្សស្រីមានឱកាសច្រើនក្នុងការសិក្សា ព្រមទាំងទទួលលទ្ធផលសិក្សាល្អជាងសិស្សប្រុស។ រូបទី៤ បានបង្ហាញច្បាស់ថា សិស្សស្រីទទួលបានមធ្យមពិន្ទុខ្ពស់ជាងសិស្សប្រុស (Sig.<0.05) លើមុខវិជ្ជាទាំង៤ ដែលបានសិក្សានៅក្នុងការស្រាវជ្រាវជ្រាវនេះ។




រូបទី៤៖ លទ្ធផលសិក្សាសិស្សប្រុស ធៀបនឹងសិស្សស្រី

ដូចគេតែងតែនិយាយថា «សិស្សដែលពូកែរៀន តែងតែរៀនពូកែ ខណៈដែលសិស្សដែលខ្ជិលរៀនពុំអាចទទួលបានលទ្ធផលសិក្សាល្អឡើយ។ បើទោះបីជាលក្ខខណ្ឌសាលារៀន ឬគ្រូល្អយ៉ាងណាក៏ដោយ បើសិស្សមិនចូលរួមមិនខំសិក្សារៀនសូត្របន្ថែមដោយខ្លួនឯង នោះជាការពិតនឹងនាំមកនូវលទ្ធផលសិក្សាមិនបានល្អនោះទេ។

### ខ.កត្តាចំណង់ចំណូលចិត្ត

ចំណង់ចំណូលចិត្តមុខវិជ្ជាសិក្សា ក៏ជាកត្តាមួយដែលអាចមានឥទ្ធិពលលើការសិក្សារបស់សិស្សដែរ។ ជាទូទៅ តាមរយៈការសម្ភាស សិស្សភាគច្រើនបានទទួលស្គាល់ថា ពួកគេតែងធ្វើបានល្អ និងទទួលពិន្ទុខ្ពស់លើមុខវិជ្ជាណាដែលគេចូលចិត្តរៀន។ ដោយឡែក មុខវិជ្ជាដែលពួកគេមិនចូលចិត្ត ពួកគេពុំសូវខិតខំរៀនទេ និងទទួលពិន្ទុក៏មិនសូវល្អដែរ។ រូបទី៥ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា លទ្ធផលសិក្សារបស់សិស្សតាមមុខវិជ្ជានីមួយៗ ពិតជាមានទំនាក់ទំនងគ្នាជាមួយនឹងការចូលចិត្តរបស់គេ។ សិស្សទទួលបានមធ្យមពិន្ទុកាន់តែខ្ពស់ កាលណាពួកកាន់តែចូលចិត្តរៀនសម្រាប់មុខវិជ្ជាសិក្សានីមួយៗ (Sig.=0.00<0.05) ខណៈដែលសិស្សដែលបង្ហាញពីការមិនចូលចិត្ត ពួកគេមិនត្រឹមតែមិនទទួលបានមធ្យមពិន្ទុខ្ពស់ទេ តែថែមទាំងធ្លាក់ក្រោមមធ្យមភាគទៀតផង។




រូបទី៥៖ លទ្ធផលសិក្សាសិស្សប្រុស ធៀបនឹងសិស្សស្រី

## គ.កត្តាវិធីសិក្សារៀនសូត្រ

ទន្ទឹមនឹងកត្តាភេទ និងកត្តាចំណង់ចំណូលចិត្តលើមុខវិជ្ជាសិក្សា វិធីសិក្សារបស់សិស្សក៏ជាកត្តាសំខាន់ផងដែរ។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការសិក្សាបន្ថែមក្រៅពីម៉ោងសិក្សានៅសាលារៀន ដូចជាការធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ ឬការព្យាយាមសិក្សាសិក្សាស្រាវជ្រាវបន្ថែមដោយខ្លួនឯង អាចជួយឱ្យសិស្សអភិវឌ្ឍសមត្ថភាពខ្លួនយ៉ាងមានប្រសិទ្ធភាពបំផុត (Cooper, Robinson, & Patall, 2006; Keith & Cool, 1992)[□□,□□]។

តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា សិស្សដែលធ្វើកិច្ចការផ្ទះគ្រូដាក់ឱ្យបានញឹកញាប់ ពួកគេទទួលមធ្យមពិន្ទុប្រចាំឆមាសកាន់តែខ្ពស់ (រូបទី៦)។ សិស្សដែលធ្វើកិច្ចការផ្ទះញឹកញាប់ទទួលបានមធ្យមពិន្ទុលើស ៧០% ខណៈដែលសិស្សដែលមិនសូវធ្វើកិច្ចការផ្ទះ ឬមិនធ្វើកិច្ចការផ្ទះសោះភាគច្រើនទទួលបានពិន្ទុក្រោម ៥០%។ លើសពីនេះទៅទៀត សិស្សទទួលបានចំណេះដឹងកាន់តែប្រសើរ កាលណាគេព្យាយាមធ្វើកិច្ចការទាំងនោះដោយខ្លួនឯង។ ប៉ុន្តែការព្យាយាមធ្វើកិច្ចការផ្ទះដោយចម្លងពីមិត្តភក្តិ ឬសួរគេឯង ហាក់ពុំបានជួយបង្កើតសមត្ថភាពយល់ដឹងដល់សិស្សទេ។ រូបទី៧ បង្ហាញថាសិស្សដែលឧស្សាហ៍ធ្វើកិច្ចការផ្ទះដោយខ្លួនឯង បានទទួលមធ្យមពិន្ទុប្រចាំឆមាសខ្ពស់ជាងអ្នកដែលធ្វើកិច្ចការផ្ទះដោយចម្លងពីគេ ឬសួរគេឯងឱ្យជួយធ្វើឱ្យ។ លើសពីនេះទៅទៀត សិស្សដែលតែងតែចម្លងកិច្ចការផ្ទះពីមិត្តភក្តិជាញឹកញាប់ ធម្យមពិន្ទុប្រចាំឆមាសរបស់ពួកគេក៏កាន់តែធ្លាក់ចុះដែរ។ ទាំងនេះបញ្ជាក់ថា ដើម្បីរៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្របានលទ្ធផលកាន់តែប្រសើរ លុះត្រាតែសិស្សព្យាយាមសិក្សា និងអនុវត្តដោះស្រាយសំណួរ និងលំហាត់បន្ថែមនៅផ្ទះ ឬក្រៅម៉ោងសិក្សានៅសាលារៀន ដោយខ្លួនឯងផ្ទាល់ និងឱ្យបានច្រើន និងញឹកញាប់។




រូបទី៦៖ ទំនាក់ទំនងនៃការធ្វើកិច្ចការផ្ទះជាមួយនឹងភាពញឹកញាប់នៃការធ្វើកិច្ចការផ្ទះ




រូបទី៧៖ វិធីធ្វើកិច្ចការផ្ទះរបស់សិស្ស

ក្រៅពីការធ្វើកិច្ចការផ្ទះ ឬរៀនបន្ថែមនៅផ្ទះបន្ថែម ការសិក្សាដែលពេញនិយមមួយទៀតដែល សិស្សភាគច្រើនតែងប្រតិបត្តនោះគឺ ការរៀនគួរជាមួយគ្រូបន្ថែមក្រៅម៉ោងសិក្សា ជាពិសេសមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ។ ការសិក្សាបានបង្ហាញថា សិស្សដែលរៀនគួរបន្ថែមជាប់

លាប់ ភាគច្រើនទទួលបានមធ្យមពិន្ទុខ្ពស់ជាងសិស្សដែលពុំបានរៀន។ រូបទី៨ បង្ហាញយ៉ាងច្បាស់ពីទំនាក់ទំនងនេះ (Sig.<0.05)។ តាមការសម្ភាស ទាំងគណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សសុទ្ធតែបានបង្ហាញគំនិតស្រដៀងគ្នាថា នៅសាលារៀនគួរ សិស្សមានឱកាសបានសិក្សា សំណួរ និងលំហាត់ជាច្រើន បន្ថែមពីលើទ្រឹស្តីទាំងឡាយដែលពួកគេរៀននៅក្នុងថ្នាក់។




ទាំងនាយក និងគ្រូបង្រៀនបានបន្ថែមថា ជាទូទៅនៅក្នុងថ្នាក់រៀន គ្រូបង្រៀនបានត្រឹមតែនិយមន័យ និងការបកស្រាយទ្រឹស្តី រួមជាមួយនឹងការដោះស្រាយលំហាត់អនុវត្តងាយៗតិចតួចប៉ុណ្ណោះ។ គ្រូភាគច្រើនបានបកស្រាយថា វាបណ្តាលមកពីម៉ោងបង្រៀនខ្លី ខណៈដែលមេរៀនវែង ដូច្នេះពួកគាត់ពុំមានពេលគ្រប់គ្រាន់ឱ្យសិស្សអនុវត្តសំណួរ ឬលំហាត់បានច្រើនទេ។ ដើម្បីបង្កើនចំណេះដឹងបន្ថែមដល់សិស្ស ពួកគាត់ចាំបាច់ត្រូវបើកបង្រៀនគួរក្រៅម៉ោង។ បើទោះបីជា សិស្សពុំបានចូលរៀនគួរក្រៅម៉ោងទាំងអស់គ្នា ដោយសារកត្តាផ្សេងៗក៏ដោយ គ្រូបង្រៀន និងសិស្សភាគច្រើនបានផ្តល់យោបល់តាមការសម្ភាសថា ការរៀនគួរបន្ថែមនេះ ពិតជាអាចជួយបង្កើនសមត្ថភាពសិស្សពិតប្រាកដ ពិសេសសមត្ថភាពដោះស្រាយលំហាត់ ដែលជាកត្តានាំឱ្យសិស្សទទួលបានមធ្យមពិន្ទុខ្ពស់ទាំងការប្រឡងប្រចាំឆមាស និងការប្រឡងបញ្ចប់ថ្នាក់ជាតិ។

ទោះជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវ ពុំបានរកឃើញថា លទ្ធផលសិក្សារបស់សិស្សគ្រប់មុខវិជ្ជាមានទំនាក់ទំនងខ្លាំងជាមួយនឹងភាពញឹកញាប់នៃការប្រើប្រាស់បណ្ណាល័យទេ។ សម្រាប់មុខវិជ្ជាគណិតវិទ្យា និងគីមីវិទ្យា បង្ហាញថាការចូលបណ្ណាល័យរបស់សិស្ស បានជះឥទ្ធិពលទៅលើមធ្យមពិន្ទុឆមាសរបស់សិស្ស[Sig.(Math)=0.000; Sig.(Chem)=0.000) ប៉ុន្តែសម្រាប់មុខវិជ្ជារូបវិទ្យាពុំសូវបង្ហាញពីទំនាក់ទំនងនេះទេ [Sig.(Phy)=0.046] ខណៈដែលមុខវិជ្ជាជីវវិទ្យាគឺរិតតែបង្ហាញថាពុំមានទំនាក់ទំនងគ្នាទៀត [Sig.(Bio)=0.504]។ ជាមួយគ្នានេះដែរ សិស្សដែលឆ្លើយថាបានចូលបណ្ណាល័យញឹកញាប់ ពុំឃើញទទួលបានមធ្យមពិន្ទុខុសគ្នាខ្លាំងជាមួយសិស្សដែលឆ្លើយថា ពុំដែលចូលបណ្ណាល័យនោះទេ ផ្ទុយទៅវិញមានមុខវិជ្ជាខ្លះហាក់ដូចជាបានមធ្យមពិន្ទុកាន់តែទាបទៅវិញដូចជា មុខវិជ្ជារូបវិទ្យា និងជីវវិទ្យា។ ចំណែកឯមុខវិជ្ជាគណិតវិទ្យា និងគីមីវិទ្យា ក៏ឃើញមានមធ្យមពិន្ទុកើនឡើងក្នុងកម្រិតតិចតួចប៉ុណ្ណោះ (រូបទី៨)។




រូបទី៨៖ មធ្យមពិន្ទុសិស្សធៀបនឹងការចូលបណ្ណាល័យ

